# មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

## កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ម ខេត្តស្ទឹងត្រែង
## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២
## ថ្ងៃអង្គារ ទី០៤ ខែមេសា ឆ្នាំ២០០៦
## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

**ទី១.** ចំណាប់អារម្មណ៏ស្វាគមន៍ដោយ លោក **ឡារី ស្រ្តេន្ទ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

**ទី២.** បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយ **លោក ឱក សេរី សោភក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

**ទី៣.** ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **ពុយ ចាន់ថាឡាក់** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង

**ទី៤.** មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តស្ទឹងត្រែង

**ទី៥.** សេចក្តីផ្សេងៗ

**លោក ឡារី ស្រ្តេន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI

ជាបឋមខ្ញុំបាទសូមគោរព អស់លោក លោកស្រី ដែលមានវត្តមាននៅទីនេះ។ ថ្ងៃនេះខ្ញុំមានកិត្តិយសណាស់ ដែលបានចូលរួមនៅក្នុងកម្មវិធីប្រជុំខប់សែលប្រ៉ម នៅក្នុងខេត្តស្ទឹងត្រែងនេះ។ ជាកិច្ចចាប់ផ្តើម នៅក្នុងព្រឹកនេះខ្ញុំបាទសូមថ្លែងអំណរគុណជាខ្លាំងចំពោះ លោក ពុយ ចាន់ថាឡាក់ ដែលជាប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែងយើងនេះ និងសូមថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះឯកឧត្តមអភិបាលខេត្តស្ទឹងត្រែង ដែលបានអនុញ្ញាតឱ្យវិទ្យាស្ថាន CDRI បានបើកកិច្ចប្រជុំខប់សែលប្រ៉មនៅថ្ងៃនេះ។ ខ្ញុំសូមបង្ហាញថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI បានរៀបចំនូវកម្មវិធីខប់សែលនេះឡើង? វិទ្យាស្ថាន CDRI ជាវិទ្យាស្ថានមួយដែលធ្វើការផ្នែកសិក្សាស្រាវជ្រាវឯករាជ្យធ្វើការពាក់ព័ន្ធទៅនឹងការងារផ្សេងៗ ជាពិសេសការងារអភិវឌ្ឍន៍។ ជាចំនុចមួយសំខាន់ផងដែរសំរាប់ការរៀបចំជាគោលនយោបាយសំរាប់កិច្ចអភិវឌ្ឍន៍សំរាប់អនាគតនៃប្រទេសកម្ពុជា។ វិទ្យាស្ថាន CDRI ធ្វើការស្រាវជ្រាវទៅលើវិស័យចំបងមានដូចជា ផ្នែកសេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្ម ផ្នែកអភិបាលកិច្ចប្រកបទៅដោយលក្ខណៈប្រជាធិតេយ្យ ការគ្រប់គ្រងធនធានធម្មជាតិ ផ្នែកអភិវឌ្ឍន៍កសិកម្មនិងជនបទ ជាពិសេសទៅទៀតនោះគឺការដោះស្រាយទំនាស់ និងការកសាងសន្តិភាព ។ វិទ្យាស្ថាន CDRI បានមើលឃើញយ៉ាងជាក់ច្បាស់ចំពោះរាល់ការអភិវឌ្ឍន៍ និងការជឿនលឿនទៅមុខផ្សេងៗទៀត គឺយើងចាំបាច់ត្រូវមានស្ថេរភាពផ្នែកនយោបាយ និងសន្តិភាពពិតប្រាកដសំរាប់ការអភិវឌ្ឍន៍នានានៅក្នុងប្រទេសកម្ពុជាយើង ។ យើងបានចាត់ទុកថាដំណើរការនៅក្នុងការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាដ៏ល្អនឹងទទួលបានជោគជ័យនេះ គឺជាក្បាលម៉ាស៊ីនមួយដែលជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍នានានៅក្នុងប្រទេសកម្ពុជា។ នៅក្នុងន័យនេះហើយដែលវិទ្យាស្ថាន CDRI មានឆន្ទៈនិងគោលបំណងយ៉ាងមុតមាំក្នុងការធ្វើការសហការណ៍ជាមួយសហគមន៍ ជាពិសេស អស់លោក លោកស្រី នៅក្នុងការដោះស្រាយជាពិសេសបញ្ហានានាដែលទាក់ទងទៅនឹងការបោះឆ្នោត ។ លោក ឱក សេរី សោភក្តិ៍ ដែលជាអ្នកសំរបសំរួលយន្តការខប់សែលនេះនឹងបង្ហាញជូន អស់លោក លោកស្រី ឱ្យបានលំអិតអំពីប្រវត្តិនៃកម្មវិធីខប់សែល និងគោលបំណងសំខាន់នៅក្នុងកម្មវិធីខប់សែលនេះ ។ ការលើកពីគោលបំណងដ៏សំខាន់នៃយន្តការខប់សែលនេះ គឺចង់ផ្តល់ឱកាសជូនទៅភាគីពាក់ព័ន្ធនានា ដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោតជាពិសេសទាក់ទងទៅនឹង NEC, PEC តំណាងគណបក្សនយោបាយនានា អង្គការសង្គមស៊ីវិល និងអាជ្ញាធរ ជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់នេះតែម្តង ។ យើងសង្ឃឹមថានៅក្នុងកិច្ចពិភាក្សាត្រង់ទៅត្រង់មកប្រកបដោយការ

គោរពគ្នាជាទីបំផុតនេះ គឺអាចនាំមកនូវសន្តិភាព និងអភិបាលកិច្ចប្រកបទៅដោយប្រជាធិតេយ្យពិតប្រាកដ។ ជាចុងក្រោយនេះខ្ញុំសូមជូនពរឱ្យកិច្ចប្រជុំសម្រាប់ព្រឹកនេះ ប្រកបទៅដោយផ្លែផ្កានឹងទទួលបានលទ្ធផលល្អជាទីបំផុត។

**លោក ឱក សេរី សោភក្តិ**

ខ្ញុំបាទសូមថ្លែងអំណរគុណជាទីបំផុតចំពោះ លោក ឡារីស្ត្រេន្ទ ដែលលោកមានប្រសាសន៍ប្រកបទៅដោយអត្ថន័យ ខ្លឹមសារអំពីអ្វីដែលវិទ្យាស្ថានយកចិត្តទុកដាក់ ជាពិសេសនៅក្នុងយន្តការបោះឆ្នោតនៅកម្ពុជា ដើម្បីធានាបាននូវការចូលរួមនៅក្នុងការបង្កើតនូវស្ថេរភាពនយោបាយតាមរយៈការបោះឆ្នោតនេះ។ ខ្ញុំបាទសូមជំរាបជូននូវប្រវត្តិ និងដើមកំណើតនៃយន្តការឧបសែលនេះ ហើយនេះជាមោទនភាពមួយរបស់ជាតិយើងតែម្តង។ ខ្ញុំបាទខ្លួនឯងមិនបាននៅជំនាន់ប៉ុលពតទេ ព្រោះខ្ញុំបាទចេញពីឆ្នាំ ១៩៧៣ ទៅស្រុកបារាំងទៅរៀនវិជ្ជាពេទ្យ ប៉ុន្តែបានរៀនសូត្រច្រើនណាស់ពីរឿងរបបប្រល័យពូជសាសន៍ ហើយនៅឆ្នាំ ១៩៨១ ខ្ញុំបាទក៏បានទៅខាងតស៊ូ នៅក្នុងអង្គការសេរី កាលនៅតាមជាយដែនជាមួយឯកឧត្តម ស៊ីន សាន រួចហើយបានមើលឃើញនូវប្រវត្តិធ្វើផ្ទាល់ទាំងនយោបាយទាំងផ្នែកសឹក បូកផ្សំជាមួយសង្គ្រាមប្រល័យពូជសាសន៍ ឃើញថាប្រជាពលរដ្ឋយើងស្លាប់ច្រើន ហើយអ្វីៗក៏ខ្ទេចខ្ទាំអស់នៅក្នុងប្រទេសកម្ពុ។ នៅក្នុងឆ្នាំ ១៩៩២ ខ្ញុំចូលមកទីក្រុងភ្នំពេញ ពេលនោះ ឯកឧត្តម ស ខេង បានជួបជជែកគ្នាជាមួយខ្ញុំបាទថា យើងសុទ្ធតែឃើញការប្រល័យពូជសាសន៍ ការខ្ទេចខ្ទាំរបស់ស្រុកទេសមកដូចៗគ្នា ដូច្នេះយើងត្រូវតែធ្វើការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ពេលនោះគាត់ស្នើសុំឱ្យខ្ញុំធ្វើជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យរបស់ឧបនាយករដ្ឋមន្ត្រី។ ខ្ញុំបាទសុខចិត្តធ្វើការ ៥ឆ្នាំ ជូនរាជរដ្ឋាភិបាល នៅក្នុងពេលដែលធ្វើការខ្ញុំបាទបានចូលរួមយ៉ាងសកម្មជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីធ្វើការរៀបចំយន្តការបោះឆ្នោតឆ្នាំ ១៩៩៨ ព្រោះឆ្នាំ ១៩៩៣ អ៊ុនតាក់ជាបរទេសគេរៀបចំឱ្យយើង ហើយឆ្នាំ១៩៩៤ រៀបចំយន្តការបោះឆ្នោតថ្នាក់ឃុំសង្កាត់ តាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ ព្រោះយើងថារៀបចំឆ្នាំ២០០២ តែដោយមានព្រឹត្តិការណ៍ឆ្នាំ ១៩៩៧ យើងរៀបចំតែឆ្នាំ១៩៩៨ ហើយបានរុញក្រុមប្រឹក្សាឃុំសង្កាត់ទៅ ឆ្នាំ២០០២ ។ នៅក្នុងការដែលធ្វើនោះខ្ញុំបាទបានទទួលនូវអាហាររូបករណ៍ក្នុងឋានៈជានាយកខុទ្ទកាល័យរបស់ ឧបនាយករដ្ឋមន្ត្រី ទៅរៀនសូត្រពីវប្បធម៌សន្តិភាព នៅអាមេរិក នៅប្រទេសអឺរ៉ុប នៅប្រទេសផ្សេងៗទៀតជាច្រើន ។

វិទ្យាស្ថាន CDRI នេះដែលកាលពីមុន លោកស្រី អេវ៉ា ជាប្រធាន ហើយបន្ទាប់មកលោក ឡារីស្ត្រេន្ទ មកទំនាក់ទំនងជាមួយខ្ញុំបាទ និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហើយវិទ្យាស្ថាន CDRI កាលជំនាន់នោះបានយកអភិបាលខេត្ត អភិបាលខេត្តរង ទាំងអស់ទូទាំង ព្រះរាជាណាចក្រកម្ពុជា មួយឆ្នាំម្តងៗយកទៅបំពាក់បំប៉ននូវការយល់ដឹងអំពីអ្វីដែលវិទ្យាស្ថានរកឃើញថ្មីៗទាំងខាងអភិវឌ្ឍន៍ ទាំងខាងសេដ្ឋកិច្ច ទាំងខាងស៊ីៗទាំងអស់ ដូចដែលខាងលោក ឡារីស្ត្រេន្ទ ជំរាបអញ្ចឹង ប៉ុន្តែខាងកម្មវិធីទាំងអស់មានកម្មវិធីមួយយើងខ្ញុំបានធ្វើជាមួយប្រទេសកាដាណាគឺវប្បធម៌សន្តិភាព ។ ពេលខ្ញុំបាទធ្វើ៥ឆ្នាំចប់មក ខ្ញុំបាទចេញពីរាជរដ្ឋាភិបាល ព្រោះស្គាល់រាជរដ្ឋាភិបាល ៥ឆ្នាំហើយចង់ស្គាល់អង្គការមិនមែនរដ្ឋាភិបាលថាជាអ្វី? ក៏ទៅធ្វើការនៅ CDRI បាន៥ឆ្នាំ ពី ឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០០៣ នៅ ពេលហ្នឹងហើយ ដែលខ្ញុំបាទគិតពិចារណាថា យើងឆ្លងកាត់ការបោះឆ្នោតឆ្នាំ១៩៩៨ យើងទំនាស់គ្នាខ្លាំងណាស់មានការបង្ហូរឈាម រហូតដល់មានថាជាទស្សនីយ៍ភាពបញ្ចាំងតាម CNN ជុំវិញសកលលោក គឺកំលាំងប្រដាប់អាវុធរ៉ៃ ធ្វើបាបព្រះសង្ឃនៅតាមផ្លូវធ្វើឱ្យ រូបភាពនៅប្រទេសរបស់យើងដែលកំពុងតែត្រូវការកសាងអ្វីៗឡើងវិញ និងជះឥទ្ធិពលទៅដល់សកលលោក។ អញ្ចឹងហើយបានជាខ្ញុំបាទធ្វើខ្លួនជាអ្នកសម្របសម្រួលកម្មវិធីសន្តិភាពនិងការអភិវឌ្ឍន៍នៅក្នុងវិទ្យាស្ថាន CDRI ។ ខ្ញុំបាទគិតថាកម្ពុជាគួរតែរកឃើញនូវយន្តការ ឬវិធីសាស្ត្រណាមួយ ដើម្បីឆ្លុះបញ្ចាំងឱ្យពិភពលោកឱ្យប្រទេសជិតយើងឃើញថាយើងមិនមែន ខ្លាំង

ពូកែតែការឈ្លោះគ្នាទេ គឺជជែកគ្នាក៏យើងចេះ នៅពេលហ្នឹងហើយដែលខ្ញុំបានធ្វើការស្រាវជ្រាវមួយដោយវិទ្យាស្ថាន CDRI អំពីដើមហេតុឬសគល់នៃទំនាស់នៅក្នុងយន្តការបោះឆ្នោតនៅកម្ពុជា ។ ខ្ញុំបាទក៏បានគូសវាសទ្ធវយន្តការខប់សែលនេះឡើងប៉ុន្តែកាលនោះពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ២០០៣ យើងធ្វើតែថ្នាក់ជាតិ ជំនុំគ្នានៅ CDRI មួយខែម្តង គណបក្សធំៗទាំង៣ រាជរដ្ឋាភិបាល និងក្រសួង៥ ឯកឧត្តម អ៊ឹមសួស្តី ដែលកាលនោះលោកនៅជាអគ្គលេខាធិការនៅឡើយទេ អង្គការសង្គមស៊ីវិលដែលទាក់ទងរឿងបោះឆ្នោត ហើយនិងរឿងអភិបាលកិច្ចល្អ និង អង្គការអន្តជាតិនានា បានចូលមកអង្គុយជុំវិញតុដូចយើងអង្គុយហ្នឹង។ ខ្ញុំបាទបានសង្កេតឃើញថា មិនមែនគ្រាន់តែពីឥឡូវទេ យូរមកការដែលយើងមានមតិនយោបាយខុសគ្នាមិនមែនជារឿងអស្ចារ្យទេ នៅកន្លែងណាក៏យើងមានមតិ អ្នកណាក៏មានមតិ ខុសគ្នាដែរ មនុស្សពីរនាក់មានមតិពីរនាក់ហើយ ប៉ុន្តែមិនត្រូវឱ្យមតិដែលខុសគ្នា ហ្នឹងឈានទៅរកការឈ្លោះទាស់ទែងគ្នា ហើយកាប់សំលាប់គ្នា បានទេ ហើយដើម្បីកុំឱ្យអញ្ចឹងធ្វើម៉េច? ខ្ញុំបាទមើលឃើញមានតែបញ្ហាមួយ គឺការជជែកគ្នាដោយត្រង់ទៅត្រង់មកបញ្ហាដែលមិន ស្តាប់គ្នាយកមកដាក់លើតុមក អញ្ចឹងអាចបែកចេញពីតុទៅដោយមិនត្រូវគ្នា ក៏ប៉ុន្តែយើងអាចយល់ថា ហេតុអីបានជាម្នាក់ទៀតគេមិន ត្រូវនិងយើង? ការដែលជជែកគ្នា ការដែលផ្តល់ឱកាសឱ្យគ្នាទៅវិញទៅមក ដើម្បីបញ្ជាក់ថាហេតុអ្វីបានជាខ្ញុំមិនឯកភាពជាមួយអ្នក? ការដែលនិយាយត្រង់ទៅត្រង់មកធ្វើឱ្យមានការគោរពគ្នាទៅវិញទៅមក ធ្វើឱ្យយើងគោពមតិដែលផ្ទុយពីយើង ការគោពគ្នាហ្នឹង ហើយជាវប្បធម៌នៃការកសាងសន្តិភាព បានជាខ្ញុំបាទធ្វើពេលនោះ គឺធ្វើ ៥០ដង អត់ដែលមានឈប់ទេ ឯកឧត្តមអគ្គលេខាធិការ គជប លោកចូលរួមគ្រប់ទាំង៥០ដងទាំងអស់ ។

យើងបានកត់កំណត់ហេតុនេះ អ្វីដែលអស់លោកអញ្ជើញមានប្រសាសន៍បន្តិចទៀតនេះនឹង បាននិយាយនៅក្នុងមីក្រូហ្នឹង គឺបានថតសំលេងទាំងអស់ហើយនឹងបាន ចូលទៅក្នុងគ្រប់ខេត្តទាំងអស់ កំណត់ហេតុហ្នឹងផ្ញើថ្វាយទៅ ព្រះមហាក្សត្រ ទៅសម្តេចប្រធានសភា រដ្ឋសភា ព្រឹទ្ធសភា ទៅនាយករដ្ឋមន្ត្រី ទៅក្រសួងមន្ទីដែលពាក់ព័ន្ធធំៗ ទៅគណបក្ស នយោបាយទាំងអស់ ទៅសង្គមស៊ីវិលទៅគ្រប់ៗគ្នាទាំងអស់ ។ អញ្ចឹងហើយបានជាយើងចង់បង្កើតបរិយាកាសស្និតស្នាលជាមួយគ្នា គ្មានពិធីការទេមិនចង់ឱ្យ ព្រោះសង្គមយើងជាសង្គមមួយដែលមានពិធីការច្រើនណាស់ គឺជាសង្គមមួយគឺថាត្រង់ធ្លាក់ពីលើចុះក្រោម តែម្តង អ្នកក្រោមពិបាកនិងតស៊ូជាមួយអ្នកលើណាស់ ដូច្នេះហើយបានជាយើងចង់បង្កើតបរិយាកាសហ្នឹងមួយ ឱ្យស្និតស្នាលជាមួយគ្នា មានអ្វីដែល យើងមិនឯកភាពគ្នាយើងយកមកនិយាយដាក់លើតុមកដល់ពេលដែលធ្វើចប់នៅ ឆ្នាំ២០០៣ ខាងវិទ្យាស្ថាន CDRI ហើយនិងខ្ញុំបាទយើងក៏បាន បញ្ចប់កម្មវិធីនេះ។ នៅឆ្នាំ២០០៣កាលនោះមានតែខប់សែលទេ ប៉ុន្តែដល់មកឆ្នាំ២០០៤នេះ អង្គការ UNDP ដែលជាផ្នែកមួយរបស់អង្គការសហប្រជាជាតិ លោកបានមកជួបនឹងលោក ឡារី ស្រ្តេន្ធ និងខ្ញុំបាទ លោកថាកម្មវិធីនេះល្អ ណាស់ជាកម្មវិធីដែលខ្មែរបង្កើតដោយដៃខ្លួនឯង អត់មានបរទេសណាមកដឹកនាំដៃយើងឱ្យធ្វើទេ ហេតុអីក៏យើងមិនបន្តទៅទៀត? គាត់និយាយអញ្ចឹងព្រោះ មានការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់២០០៧ បោះឆ្នោតថ្នាក់ជាតិ២០០៨ ដូច្នេះគួរតែធ្វើបន្តទៅទៀត ។ គាត់ក៏បានផ្តល់ឱ្យថវិការច្រើនណាស់ ខ្ញុំបាទក៏បានដកខ្លួនយកពេល១អាទិត្យទៅពិចារណាមើលថា តើគួរបង្កើតយន្តការនេះបែបម៉េច ? ដើម្បីឆ្លើយតបទៅនិងសភាពការណ៏បែបថ្មី ខ្ញុំបាទទៅនៅម្នាក់ឯង១អាទិត្យដកខ្លួនថយទៅជជែក ជាមួយព្រះសង្ឃស្វាត់ៗ ហើយក៏បានគិតឃើញថាការដែលយើងធ្វើបានជោគជ័យនៅកំរិតថ្នាក់ជាតិជាការមួយល្អ ប៉ុន្តែមិនគ្រប់គ្រាន់ទេ យន្តការហ្នឹងគួរតែយកមកដាក់នៅ ថ្នាក់ខេត្ត ដែលមានការចូលរួមអំពីក្រុមប្រឹក្សាឃុំសង្កាត់តទៅទៀត អញ្ចឹងហើយបានជាបង្កើតមិន ត្រឹមតែខប់សែលទេ គឺចេញខប់សែលប្រ៉ម COPCEL Provincial Meeting។ ឥឡូវហ្នឹងទាំងព្រះមហាក្សត្រ ដែលខ្ញុំបាទបានចូល ទៅថ្វាយបង្គំ ហើយនិងសម្តេចនាយករដ្ឋមន្ត្រី សម្តេចប្រធានសភា សម្តេចប្រធានព្រឹទ្ធសភា គឺថារត់មាត់ណាស់ហៅរឿងខប់សែលៗ ដោយសារ

បានមើលកំណត់ហេតុច្រើន អញ្ចឹងហើយបានជាគំនិតហ្នឹងបានយកមកដាក់ជារៀបចំខប់សែលនៅថ្នាក់ខេត្ត។ ដូចក្នុងថ្ងៃ នេះអញ្ចឹង យើងមិនស្មានថាអញ្ជើញមកប្រជុំច្រើនសន្ធឹកសន្ធាប់ដល់ម្លឹងទេ ហើយយើងសង្ឃឹមថាគណបក្សទាំង៣ មានប្រធានមន្ទីរ មានតំណាង ខេត្ត ដែលចូលរួមនឹងស្តាប់របាយការណ៍របស់បងប្រធាន PEC ហើយនឹងលើកឡើងនូវអ្វីៗដែល លោកស្រី អស់លោក ឃើញថា តើយើងធ្វើម៉េចដើម្បីរៀបចំការបោះឆ្នោតឆ្នាំ២០០៧-២០០៨នៅ ខេត្តស្ទឹងត្រែងយើងនេះ ? ហើយបង្ការទំនាស់ឱ្យបានជា ដាច់ខាត ? អ្វីដែលជាបញ្ហាយើងយកមកដាក់នៅលើតុទៅ ហើយបញ្ហាយើងដោះស្រាយយ៉ាងម៉េចបាន? មានកន្លែងខ្លះយើងដោះ ស្រាយមិន បានទេ ក៏ប៉ុន្តែយើងនឹងប្រឹងដោះស្រាយជាមួយគ្នាតទៅទៀត តែបើសិនយើងមិនទាន់អាចដោះស្រាយបានក៏យើងអាចគ្រប់គ្រងបាន កុំឱ្យឈានទៅដល់មានបញ្ហាមើលមុខគ្នាមិនចំ ។ គោលបំណងសំខាន់បំផុតរបស់យន្តការខប់សែលមាន៣ធំៗ

**ទីមួយ** យុទ្ធនាការណ៍ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨ឆ្នាំបានអត្តសញ្ញាណប័ណ្ណទាំងអស់គ្នា ហើយនេះគឺ យើងធ្វើបាន៤-៥ខែបានជោគជ័យទៅហើយ ។ យើងទៅគ្រប់ខេត្តជួបជាមួយអភិបាលខេត្ត ជួបជាមួយស្នងទាំងអស់ ហើយយើងធ្វើ យុទ្ធនាការហ្នឹង យើងឃើញស្រាប់ហើយថាប្រហែលជា១ខែកន្លះមុន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង បានថ្លែងជាសាធារណៈ ហើយថាបញ្ហាអត្តសញ្ញាណប័ណ្ណនេះ លោកយកជាបញ្ហាអាទិភាពខ្ពស់របស់ក្រសួងហើយដាក់ចេញជាដំណាក់កាល ដើម្បីធ្វើយ៉ាងណា ក្នុង១ឆ្នាំ២០០៦ នេះឱ្យប្រជាពលរដ្ឋខ្មែរដែលមានសុទ្ធិបានទទួលអត្តសញ្ញាណប័ណ្ណចំនួន ១លាន៩សែននាក់ ឱ្យបានទទួលទាំងអស់គ្នា ហើយខាងនគរបាលជាតិប្រញ៊ាប់ជើងសម្បើមណាស់នៅក្នុងរឿងនេះ ដើម្បីដល់ឆ្នាំ២០០៧ឱ្យយើងបានចូលរួមនៅក្នុងការបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ មិនគ្រាន់តែប៉ុណ្ណឹងយើងបានធ្វើការតស៊ូមតិ មតិគ្រប់ខេត្តទៅបានយើងជំរាបជូនទៅ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ថាបើសិនជាទុកតែឱ្យចៅហ្វាយខេត្តជាអ្នកចុះហត្ថលេខា គឺចុះមិនទាន់ទេ ព្រោះអត្តសញ្ញាណប័ណ្ណគឺគរលើតុច្រើន ណាស់លោកក៏ធ្វើសេចក្តីសំរេចមួយទៀតថាត្រូវប្រគល់ប្រតិភូកម្មអំណាច ឱ្យទៅអភិបាលខេត្តរងទីមួយអាចនឹងចុះហត្ថលេខាបាន កាលដែលយើងធ្វើការជជែកគ្នាត្រង់ទៅត្រង់មកបានលទ្ធផលអញ្ចឹង ។ ហើយបានជាទៅកន្លែងណាក៏ដោយក្រសួងមហាផ្ទៃគាំទ្រនូវ យន្តការខប់សែលណាស់ ព្រោះជាយន្តការមួយដែលមិនមានគំនិតនយោបាយនៅពីក្រោយ ។ លោក ឡាវី ស្រ្តេន្ទ និងអង្គការ CDRI អត់មាន Agenda នយោបាយនៅពីក្រោយខ្នងយើងចង់តែធ្វើម៉េចឱ្យយន្តការបោះ ឆ្នោតនៅប្រទេសកម្ពុជាយើង ដែលមានការចូល រួមពីអ្នកដែលមានការពាក់ព័ន្ធផ្ទាល់ ។ ដូចថ្ងៃនេះជុំវិញតុនេះអញ្ចឹងជាអ្នកដោះស្រាយ ជាអ្នកម្ចាស់ការ ដើម្បីកសាងយន្តការនេះឡើង ដោយខ្មែរខ្លួនឯងដើម្បីទៅជំនួសរូបភាពនៅតាមវិទ្យុទូរទស្សន៍នៅតាម CTN នៅតាម CNN ជំនួសរូបភាពកាលជំនាន់៩៧-៩៨ នោះ ដូចខ្ញុំបាទជំរាបជូនអំប្បាញ់មិុញនឹងយករូបភាពដែលយើងកសាងសន្តិភាពជាមួយ គ្នាទៅជំនួសរូបភាពដែលយើងល្បីល្បាញខាង កាប់សំលាប់ អញ្ចឹងហើយបានជា ឯកឧត្តម អស់លោក លោកស្រី ខ្លះបានឃើញហើយ លោក ឡាវី ស្រ្តេន្ទ ហើយនិងខ្ញុំបាទបានចូល ទូរទស្សន៍ CTN ពីរដងរួចមកហើយ ហើយ CTN នេះបងប្អូនយើងដែលរស់នៅ សហរដ្ឋអាមេរិក និងនៅអឺរ៉ុបក៏បានឃើញដែរ យើងមានខប់សែលគឺថា COPCEL MEDIA ដើម្បីផ្សព្វផ្សាយដំណឹងអស់ហ្នឹង ទៅ ប្រទេសក្រៅទៀត ថាកម្ពុជាយើងមិនមែនចេះ តែឈ្លោះគ្នាទេ ហើយឥឡូវយើងចាប់ផ្តើមដោះស្រាយបញ្ហាហ្នឹង ថ្នាក់ដឹកនាំរបស់យើង លោកក៏បានផ្តល់ជា ឧទាហរណ៍ល្អៗមកហើយ ថាបញ្ហាអ្វីធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏លោកឱ្យដោះស្រាយតាមរយៈការជជែកពិភាក្សា គ្នា ពង្រឹងវប្បធម៌នៃការពិភាក្សាគ្នា ។

**ទីពីរ** ធ្វើយ៉ាងណា ដើម្បីប្រើប្រាស់ពេលវេលាចុះឈ្មោះត្រៀមពេល៩ខែនេះ ពីខែមករាដល់ខែកញ្ញា ដើម្បីប្រើប្រាស់ពេល វេលាហ្នឹង ឆ្លងទៅការចុះឈ្មោះបោះឆ្នោតចំនួន២០ថ្ងៃនៅខែតុលាឱ្យបានគ្រប់ៗគ្នា គោលដៅរបស់យើងគឺ១០០%នៃប្រជាពលរដ្ឋ ខ្មែរបានចុះឈ្មោះបោះឆ្នោត ហើយមិនត្រឹមតែមានឈ្មោះទេ យើងនឹងធ្វើយុទ្ធនាការធ្វើជាមួយ គជប ជាមួយនឹងខាង PEC ទាំងអស់

ដើម្បីសម្រិតសម្រាំងគុណភាព ដែលនៅក្នុងបញ្ជីកុំឱ្យមានខុសឈ្មោះ។ ម្សិលមិញនៅខេត្តមណ្ឌលគីរី លោកមេប៉ូលីសសារភាពត្រង់តែម្តង លោកថាដល់បានស្តាប់បងទៅបានស្តាប់អង្គប្រជុំទាំងអស់គ្នាទៅ លោកសារភាពថាកូនចៅរបស់លោក ដែលចុះអត្តសញ្ញាណប័ណ្ណដូរឈ្មោះសរសេរខុសច្រើនណាស់ រួចតែដូរឈ្មោះទៅគុណភាពនៃការចុះបញ្ជីឈ្មោះខុសអស់ ។ ដូចឈ្មោះ ខ្ញុំបាទ ឱក សេរីសោភក្តិ៍ គេមិនសូវហៅទេគេហៅតែឱក សេរីសោភ័ណ្ឌ សរសេរឱកសេរីសោភ័ណ្ឌខុស កាលពាក់មីខ្ញុំបើកឡានក៏គាត់សរសេរសោភ័ណ្ឌដែរ បើប៉ូលីសចាប់ខ្ញុំអត់មានតវ៉ាបានទេត្រូវតែបង់លុយតែម្តងមកពីស្រុកខ្មែរយើងមិនសូវប្រយ័ត្នទេរឿង ខុសឈ្មោះហ្នឹង ដូច្នេះហើយ យើងចង់តែសម្រិតសម្រាំងចុះ១០០%ហើយទាំងគុណភាព ហើយនិងបញ្ជីឈ្មោះឱ្យបានត្រឹមត្រូវទៅខ្ញុំបាទគិតថាយើងគួរតែអត់ធ្មត់មន្ត្រីនៅថ្នាក់ក្រោម គឺលោកខំមិនមែនមិនខំទេខុសតិចតួចហ្នឹង យើងខំអត់ធ្មត់ទៅ ខំកែទាំងអស់គ្នា ដើម្បីឱ្យល្អទៅបាន។ ដូច្នេះយុទ្ធនាការនេះគឺក្នុង ឆ្នាំ២០០៦ ត្រូវចុះឈ្មោះឱ្យបាន១០០% ហើយត្រូវសម្រិតសម្រាំងគុណភាពបញ្ជីឈ្មោះ កុំឱ្យមានខុសច្រើនពេក។

**ទី៣** ធានានូវសន្តិសុខធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពមូលដ្ឋាន ខាង PEC ខាង CEC ជាមួយគណបក្សនយោបាយទាំងអស់ និងជាមួយអង្គការសង្គមស៊ីវិលនានា ដើម្បីធ្វើយ៉ាងណាឱ្យយន្តការបោះឆ្នោតម្តងៗឱ្យលែងមានឮទៅយប់ឡើងឆ្កែព្រូសឱ្យលែងមានទៀតទៅ ឱ្យឈ្នះឆ្នោតជាមួយនឹងការរៀបចំដោយយកចិត្តទុកដាក់ ជាមួយទឹកចិត្ត ស្មារតីរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតដោយការ សន្យាធ្វើអ្វីដែលបានសន្យាជាមួយនិងម្ចាស់ឆ្នោតឱ្យឈ្នះអញ្ចឹងវិញ កុំឱ្យឈ្នះនិងបរិយាកាសគំរាមកំហែងនិងបរិយាកាសដែលមិនសមគួរ។ យើងល្មមដល់ពេលមួយដែលរាជរដ្ឋាភិបាល ម្ចាស់ជំនួយទាំងអស់ខំកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវ ថ្នល់ ដែលឥឡូវ យើងបើកឡានបានដោយស្រួល។ ខេត្តស្ទឹងត្រែងបន្តិចទៀតទៅផ្លូវអាស៊ានតភ្ជាប់គ្នាទាំងអស់ទៀតទៅ បើសិនជាយើងរក្សាសន្តិសុខនៅក្នុងយន្តការបោះឆ្នោតហ្នឹងបាន ឃើញថាការអភិវឌ្ឍន៍សេដ្ឋកិច្ច ការអភិវឌ្ឍន៍សង្គម ការអភិវឌ្ឍន៍នៅតាមជនបទ ឆ្ងាយៗយើង ផ្សារភ្ជាប់គ្នាបានទាំងអស់ យើងលែងវេទនាដូចប្រវត្តិសាស្ត្រខ្មៅដូចលើកមុនបានទៀត ដែរដូច្នេះការបោះឆ្នោតត្រូវតែធានាឱ្យបាន ។ ហើយបញ្ហាដែលយើងរកឃើញថានៅពេលដែលមានការបោះឆ្នោតម្តងៗ ថ្ងៃបោះឆ្នោតនៅជុំវិញស្ថានីយបោះឆ្នោតគឺមានវត្តមានរបស់មន្ត្រីមូលដ្ឋាន មេភូមិ មេឃុំ មេស្រុក យើងបានធ្វើការជាមួយខេត្តឯទៀតៗ ហើយយល់ព្រមថាដល់ពេលឆ្នាំ២០០៧-២០០៨ លែងឱ្យ មានទាំងអស់ ព្រោះមិនចំនេញអីនឹងទៅមានវត្តមានហ្នឹងទេ ព្រោះអ្នកដែលគេរៀបចំអ្នកបោះឆ្នោតមែនទែនគេមិនចំនេញនៅកន្លែង ហ្នឹងទេ ដូច្នេះហើយយើងមិនចំនេញហើយមានតែខាតទៀត ។ អញ្ចឹងហើយបានជាខេត្តគ្រប់គ្នាទទួល យល់ព្រមជាមួយ គជប ថានៅ លើកក្រោយយើងលែងឱ្យមានបញ្ហាហ្នឹងទៀតហើយ យើងនឹងរៀបចំឱ្យការបោះឆ្នោតនឹងបានទៅចូលស្រួលមិនឱ្យលោកអ៊ីចាស់ៗ គាត់ទៅបញ្ច្រៀតជាមួយគេជាមួយឯងពីរបីដងចូលបោះមិនបានទេយើងធ្វើឱ្យមានរបៀបរៀបរយ។ ប៉ុន្តែយើងខ្ញុំមាន កិត្តិយស នឹងត្រង ត្រាប់ស្តាប់ដោយយកចិត្តទុកដាក់ថា តើខេត្តស្ទឹងត្រែងយើងនេះមានបញ្ហាអ្វីជាពិសេស ? ព្រោះខេត្តមួយៗដែលយើងខ្ញុំបានឆ្លងកាត់ សុទ្ធតែមានបញ្ហាពិសេសរៀងៗខ្លួន។

**លោក ពុយ ចាន់ថាឡាក់** ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង

ជាបឋមខ្ញុំបាទ សូមគោរព លោក ឱកសេរីសោភក្តិ៍ លោក ឡារី ស្រ្តេនូ ដែលជាម្ចាស់នៃកម្មវិធី និងសូមគោរព អស់លោកលោកស្រីទាំងអស់ ដែលជាសមាជិក សមាជិកា នៃអង្គប្រជុំទាំងមូល។ យើងឃើញថាការរៀបចំការបោះឆ្នោតរបស់អ៊ុនតាក់ ដែលរៀបចំឡើងនៅឆ្នាំ១៩៩៣នេះ ហើយឈានដល់បន្តបន្ទាប់មកទៀត គឺយើងត្រូវមានការស្វ័យរាប់រងផ្ទាល់របស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ព្រះរាជាណាចក្រកម្ពុជាយើងសំខាន់ក្នុងការលើកកំពស់អាទិភាព ក្នុងឋានៈជាម្ចាស់ប្រទេស ម្ចាស់ប្រជាជនខ្លួនឯង ដើម្បីធ្វើការបោះឆ្នោតដល់ប្រជាជនកម្ពុជាខ្លួនឯង ។ នៅឆ្នាំ១៩៩៨ ឆ្នាំ២០០១-២០០២ សំរាប់ក្រុមប្រឹក្សាឃុំសង្កាត់ និងឆ្នាំ២០០៣ជាបន្តបន្ទាប់

មកនេះសំរាប់បោះឆ្នោតជាសកលជ្រើសរើសតំណាងរាស្ត្រអាណត្តិទីបី ហើយ ចំពោះបញ្ហាទាំងអស់នេះឃើញថាពីមួយអាណត្តិទៅមួយអាណត្តិ យើងបានធ្វើការកត់សំគាល់ឃើញថា ការរីកចំរើនវិវឌ្ឍន៍ខាងផ្នែកលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរបស់យើងខ្ញុំទៅលើផ្នែកមន្ត្រីនោះ គឺបានដកស្រង់បទពិសោធន៍អនុវត្តបានច្រើន តែងតែបានដក់ជាប់នូវអ្វីៗដែលជាបទពិសោធន៍ដែលជាប្រការសំខាន់ៗដែលយើងត្រូវអនុវត្តឱ្យបានល្អប្រសើរឱ្យមានភាពរលូន ដើម្បីធ្វើឱ្យការបោះឆ្នោតក្នុងដំណាក់កាលមួយៗនេះបានប្រព្រឹត្តទៅដោយយុត្តិធមិត្រឹមត្រូវនិងទទួលយកបាន។ ហើយថ្មីៗនេះដែលក្នុងឆ្នាំ២០០៥-២០០៦នេះ លេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្នុងខេត្តស្ទឹងត្រែងយើងបានអនុវត្តភារៈកិច្ចដ៏សំខាន់២ ទន្ទឹមគ្នាគឺការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៥ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ឆ្នាំ២០០៦ ។ ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៥កន្លងទៅនេះ គឺបានប្រព្រឹត្តទៅដោយល្អត្រឹមត្រូវតាមច្បាប់ បទបញ្ជានិងនីតិវិធី និងប្រតិទិនការងារដែល គជប បានដាក់ចុះ។ ដោយឡែកការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រព្រឹត្តទៅនៅថ្ងៃទី២២ខែមករាឆ្នាំ២០០៦ បានប្រព្រឹត្តទៅដោយរលូន ប្រកបដោយលក្ខណៈសេរីត្រឹមត្រូវនិងយុត្តិធមិនិងមានសុវត្ថិភាពពេញលេញជាលទ្ធផលទទួលបាន។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍សង្ខេបខ្លី

**ទី១** យើងពិនិត្យលើសភាពការណ៍រួមក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីប្រចាំឆ្នាំ២០០៥ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ។ ចំពោះចំនុចទីមួយយើងលើកពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ (ក)លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះនៅខេត្តស្ទឹងត្រែងរបស់យើង ដែលមានស្រុកចំនួន៥ ឃុំចំនួន៣៤ និង១២៨ភូមិ យើងមានប្រជាពលរដ្ឋសរុបទាំងអស់ ចំនួន ៩២ ៦៧៩នាក់ ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងសរុបមានចំនួន ៤៩ ៣០៩ នាក់ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីចុងក្រោយ ចំនួន ៤៤ ១១៦នាក់ ប្រជាពលរដ្ឋចុះឈ្មោះថ្មីមានចំនួន ១៦២៨នាក់ប្រជាពលរដ្ឋត្រូវបានលុបឈ្មោះចេញពីបញ្ជីមាន ៥៣៤នាក់ បានសេចក្តីថាក្នុងចំណោមអ្នកដែលបានទទួលមរណៈភាព ផ្លាស់ទីលំនៅ ឬបាត់បង់សិទ្ធិផ្សេងៗ និងប្រជាពលរដ្ឋក្នុងបញ្ជីបច្ចុប្បន្នភាពដែលទទួលកែតំរូវរួចមានសុពលភាពក្នុងឆ្នាំ២០០៥ មានចំនួន ៤៥២១០ នាក់ ស្មើនិង៩១,៦៨%ធៀបទៅនិងចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងក្នុងខេត្តស្ទឹងត្រែងទាំងមូល។ ជាមួយគ្នានេះដែរខ្ញុំសូមបញ្ជាក់បន្ថែមពីចំនុច(ខ) គឺចំពោះអ្នកសង្កេតការភ្នាក់ងារគណបក្សនយោបាយ និងអ្នកង្កេតការជាតិនៅទូទាំងខេត្ត មានអ្នកសង្កេតការគណបក្សនយោបាយរួមក្នុងដំណាក់កាលចុះឈ្មោះនេះ មាន៣៤ឃុំត្រូវជា៦៤នាក់ ក្នុងនោះមានស្រី៨នាក់គណបក្សប្រជាជនពង្រាយបាន ៣៤គ្រប់ឃុំ គឺពេញ ៣៤ និងបំរុង៧៥ គណបក្សហ៊្វុនស៊ិនប៉ិច មានចុះទៅ២៥ឃុំក្នុងចំណោម៣៤ឃុំ ពេញសិទ្ធិ២៥នាក់ និងបំរុង៦៨នាក់ គណបក្សសមរង្ស៊ី បានចុះទៅក្នុងចំនួន៥ឃុំពេញសុទ្ធិ៥នាក់និងបំរុង៨នាក់ អ្នកសង្កេតការជាតិដែលបានចូលរួម គឺមានតែអង្គការនិកហ្វិចមួយទេ ដែលបានចុះទៅក្នុង២ឃុំដែលក្នុងនោះមានបុរសម្នាក់តែម្តង។ ចំនុចទី២ខ្ញុំសូមអនុញ្ញាតជំរាបជូនពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ និងការរាប់សន្លឹកឆ្នោត ជាលទ្ធផលយើងឃើញថាខេត្តស្ទឹងត្រែងមានចំនួនការិយាល័យបោះឆ្នោតតែមួយទេ និងការិយាល័យរាប់សន្លឹកឆ្នោតក៏តែមួយដែរ ដែលមានអ្នកបោះឆ្នោតចំនួន ១៧២នាក់ ក្នុងនោះមានសមាជិកក្រុមប្រឹក្សាឃុំក្នុងតំណែងចំនួន១៧៦នាក់ និងតំណាងរាស្ត្រក្នុងតំណែងចំនួនមួយនាក់។ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ជាលទ្ធផលគណបក្សប្រជាជនទទួលបាន ១១៩សំលេង គណបក្សសមរង្ស៊ី ទទួលបាន ១៥សំលេង គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៤៣សំលេង និងគណបក្សប្រជាធិតេយ្យខ្មែរទទួលបានសូន្យសំលេង។ អំពីអ្នកសង្កេតការគណបក្សនយោបាយមានចំនួនសរុប៩រូប ស្រីនៅក្នុងនោះមាន៤នាក់ ក្នុងនោះឃើញថាគណបក្សប្រជាជនមានចំនួន៣រូប គណបក្សហ៊្វុនស៊ិនប៉ិចមានចំនួន២រូប គណបក្សសមរង្ស៊ីមាន១ រូបនិងគណបក្សប្រជាធិតេយ្យខ្មែរមាន២រូប។

**ទី២** អំពីបទពិសោធន៍ អ្វីដែលជាការបង្ករលក្ខណៈងាយស្រួលឱ្យដល់ដំណើរការរៀបចំការបោះឆ្នោត បានប្រព្រឹត្តទៅបានល្អ និងដោយរលូននោះ។ **ចំនុចទី១** ក្រុមប្រឹក្សានៅក្នុងឃុំសង្កាត់ភាគច្រើន ដោយមានការគាំទ្រនិងបង្កលក្ខណៈល្អដោយអាជ្ញាធរខេត្ត ស្រុកបានបំពេញការងារល្អក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំតាមការធ្វើប្រតិភូកម្មអំណាចជូនដោយ គជប។ **ចំនុចទី២** រាល់ឯកសារពាក់ព័ន្ធនានាត្រូវបានគណបក្សនយោបាយនិងអាជ្ញាធរស្រុក និងខេត្តបានសហការជួយសំរួលបំពេញ និងបញ្ជូនមក គខប បានទាន់ពេលវេលាដោយមិនបានបង្អាក់ ឬ ធ្វើឱ្យមានការរាំងស្ទះឡើយ។ **ចំនុចទី៣** ការជ្រើសរើសមន្ត្រីបោះឆ្នោតត្រូវបានអនុវត្តបានយ៉ាងត្រឹមត្រូវ ដោយឆ្លងកាត់ការឯកភាពពី គណៈកម្មាធិការជ្រើសរើសគ្រប់លំដាប់ថ្នាក់ កំណត់បាននូវមន្ត្រីល្អៗមានសមត្ថភាពនិងបទពិសោធន៍សំរាប់បំរើការងារតាមជំនាញច្បាស់លាស់និងតាមតំរូវការ។ **ចំនុចទី៤** ការធ្វើការបណ្តុះបណ្តាលរួមគ្នាទាំងនៅថ្នាក់ជាតិនិងនៅខេត្តក្រុង រវាងមន្ត្រីរៀបចំការបោះឆ្នោតជាមួយតំណាងគណបក្សនយោបាយ និងតំណាងអ្នកសង្កេតការបោះឆ្នោតបានបង្កើតនូវការយល់ដឹងរួមគ្នា ការយោគយល់គ្នា ការកាត់បន្ថយទំនាស់នានា ។ ក្នុងដំណាក់កាលបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានេះ យើងឃើញថាជាបទពិសោធន៍មួយរបស់ គជប ដែលបានរៀបចំកម្មវិធីនេះឡើង ឃើញថាដោយឡែកនៅខេត្តស្ទឹងត្រែងយើងបានអនុវត្តនូវការបណ្តុះបណ្តាលរួមគ្នា ដើម្បីឱ្យសមត្ថកិច្ចរបស់ការងារបោះឆ្នោត ខាងបច្ចេកទេសគេបានយល់ច្បាស់ដោយឡែកភ្នាក់ងារសង្កេតការរបស់គណបក្សនយោបាយផងដែរ ក៏បានយល់ដឹងទាំងអស់គ្នា នៅពេលបានអនុវត្តការងារជាមួយគ្នាដើម្បីឃើញថាកិច្ចការនេះបានធ្វើឱ្យមានភាពល្អប្រសើរដែលអាចយកជាបទពិសោធន៍ដែរ។ **ចំនុចទី៥** បញ្ហាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មានលក្ខណៈល្អពុំមានអ្វីគួរឱ្យកត់សំគាល់ អាស្រ័យដោយមានកិច្ចសហការរវាង គខប និងអាជ្ញាធរមានសមត្ថកិច្ចនិងអង្គពាក់ព័ន្ធនានា ពិសេសគណៈបញ្ជាការឯកភាព ដែលមានការិយាល័យសន្តិសុខខេត្តជាសេនាធិការ។ **ចំនុចទី៦** ការបង្ការទំនាស់ដោយបង្កើនកិច្ចសហការជាមួយអាជ្ញាធរដែនដី គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល។ ពាក់ព័ន្ធកិច្ចការនេះយើងធ្វើតាមការប្រជុំរួមគ្នាមួយជាប្រចាំនៅតាមថ្នាក់ខេត្ត ថ្នាក់ឃុំ ដើម្បីជូនព័ត៌មានផ្លាស់ប្តូរយោបល់ដោះស្រាយបាននូវលទ្ធផលជាវិជ្ជមាន នេះខ្ញុំចង់និយាយថាជាបទពិសោធន៍ផង ដែលយើងបានធ្វើការជួបជុំគ្នា ដោយមានសមាសភាពជាអាជ្ញាធរដែនដី ជាគណបក្សនយោបាយដែលក្នុងនោះយើងបានបង្ហាញនូវអ្វីៗ ដែលបានយល់ដឹងជានីតិវិធីផ្សេងៗជាមួយនឹងអ្វីដែលជាបាតុភាពផ្សេងៗ ដែលអាចលេចឡើងនៅក្នុងពេលមុនឬក្រោយ ដើម្បីយើងមានវិធានការ ដោះស្រាយរួមគ្នា ដើម្បីអនុវត្តឱ្យបានល្អប្រសើរ។

បន្ទាប់មកទៀតខ្ញុំសូមចូលមកដល់ការលំបាក

**ចំនុចទី១** មានក្រុមប្រឹក្សាឃុំមួយចំនួនពុំទាន់មាន អត្តសញ្ញាណប័ណ្ណនេះជាការពិត ការជំរុញមួយគេបានធ្វើអត្តសញ្ញាណប័ណ្ណបានច្រើន តែដោយឡែកខ្លួនគាត់រវល់ការងារច្រើន គាត់អត់បានចាប់អារម្មណ៍ឬក៏គាត់អត់មានឱកាស ដល់ពេលដែលយើងធ្វើការបោះឆ្នោតព្រឹទ្ធសភាថ្មីៗនេះបញ្ហាចម្រូងចម្រាស់ជាច្រើនដែលចោទឡើង គឺបញ្ហាឈ្មោះរបស់គាត់ ឃើញថាថ្វីត្បិតតែគាត់មានទិន្នន័យនៅក្នុងអត្តសញ្ញាណប័ណ្ណ អ្នកដែលមានមួយចំនួនទៀត ក៏ឃើញថាពុំអាចយកទិន្នន័យនោះឆ្លើយតបទៅសេចក្តីប្រកាសទទួលស្គាល់ពី គជប ឬក៏ការប្រកាសតែងតាំងរបស់ក្រសួងមហាផ្ទៃ ដែល ត្រូវយកជាគោលសំរាប់ការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ចំពោះបញ្ហានេះយើងឃើញថានៅក្នុងដំណាក់កាលទី១ ដែលយើងធ្វើទៅដោយសារយើងមិនបានគិតដល់បញ្ហាដែលពាក់ព័ន្ធ និងអ្វីដែលជាឯកសារពាក់ព័ន្ធ និងឆ្នាំ២០០១ឆ្នាំ២០០២ អញ្ចឹងឯកសារគោលនៅពេលនោះ គឺសមត្ថកិច្ចខាងបោះឆ្នោតបានរៀបចំឈ្មោះជូនក្រសួងមហាផ្ទៃ ហើយក្រសួងមហាផ្ទៃ បានចេញជាប្រកាសតែងតាំងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងជំទប់ទី១ ទី២ ជាផ្លូវការដែលមានឈ្មោះ និងហត្ថលេខារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃច្បាស់លាស់ ដល់ពេលឈ្មោះដែលយើងប្រតិភូកម្មអំណាច

ទៅឱ្យលោកមេឃុំ ទីប្រឹក្សាឃុំជាអ្នកចុះ ព្រោះគាត់មានតួនាទីជាអ្នកចុះ ដល់ពេលគាត់ចុះទៅជាឈ្មោះទៅ យើងអត់បានចាប់អារម្មណ៍ទេស្រាប់តែមកដល់ខាង PEC ក៏មិនបានចាប់អារម្មណ៍ដែរ យើងបញ្ជូនទៅបន្ត ព្រោះយើងឃើញមានត្រាក្រហមត្រឹមត្រូវច្បាស់លាស់ ហើយយើងឃើញថាគំនិតតាំងពីថ្នាក់ឃុំ រហូតថ្នាក់ស្រុក រហូត ថ្នាក់ខេត្ត ឃើញថាវាអាចយកជាការបានហើយ ប៉ុន្តែដល់ទៅដល់ គជប គឺត្រូវមានការផ្ទៀងផ្ទាត់ជាមួយប្រការដែលគាត់ធ្វើជា ការចំលងក្រោយមានលទ្ធផលយ៉ាងសុក្រឹត្យ និងជូនទៅខាងគាត់ពិនិត្យ អញ្ចឹងឃើញថា មានឈ្មោះខ្លះខុសគ្នា ។ ឧទាហរណ៏ ដូចឃុំ តាឡាត ឈ្មោះគាត់ក្នុងបញ្ជីដែល គជប ដាក់ទៅក្រសួងមហាផ្ទៃ ទទួលស្គាល់គឺ ស៊ីឡុន ដល់គាត់ធ្វើការងារបញ្ជាក់នៅក្នុងដំណាក់កាល ដែលគាត់ជាមេឃុំគាត់ឈ្មោះស៊ីសម្លុត ឃើញថាខុសគ្នាហើយ អញ្ចឹងយើងចេះតែមានចំងល់ហួរហែរថាឈ្មោះដែលមាននៅក្រសួងមហាផ្ទៃ ស៊ីប្រាក់ខែរបស់ក្រសួងមហាផ្ទៃរួចទៅហើយ ហើយត្រាឈ្មោះរបស់គាត់ គឺស៊ីសម្លុតដែរ អញ្ចឹងយើងធ្វើតាំងពីឆ្នាំ២០០១មក ហើយយើងឃើញថាការបញ្ជាក់ការដកប្រាក់ពីរតនាគារផ្សេងៗ មានសុពលភាពអស់ហើយ ប៉ុន្តែដល់ពេលដែលយើង បញ្ចេញមកល័ក្ខខ័ណ្ឌនៃឈ្មោះរបស់គាត់ឃើញថាខុសគ្នា។ យើងឃើញថាបញ្ហាទាំងអស់នេះ ការរៀបចំឈ្មោះរបស់គាត់នេះ យើងនិយាយឱ្យត្រង់ទៅអ្នកខ្លះមានឈ្មោះ១ ឈ្មោះ២ មិនដឹងទេ តែឈ្មោះនេះវាហាក់ដូចជាមាន២ មាន៣ ខុសគ្នាទាំងអស់តាំងពីអាយុឡើង នេះដោយឡែកយើងចាំផ្ទៀងផ្ទាត់ជាមួយអត្តសញ្ញាណប័ណ្ណ គាត់អត់មានអត្តសញ្ញាណប័ណ្ណទៀត ដើម្បីយកជាគោល បញ្ហានេះយើងមានការសម្របសម្រួលគ្នាច្រើនដោយរុញទៅ គជប ហើយបកចុះមកវិញ ធ្វើនៅតាមមូលដ្ឋានឃុំត្រឡប់ចុះត្រឡប់ឡើងដើម្បីកែសម្រួលទិន្ន័យឱ្យបានល្អសុក្រឹត្យ ដើម្បីគាត់មានលទ្ធភាពក្នុងការបោះឆ្នោតបាន

**ចំនុចទី២** ក្រុមប្រឹក្សានិងមេឃុំមួយចំនួនតូច មិនទាន់បានយកចិត្តទុកដាក់អនុវត្ត ឬពុំមានពេលវេលាគ្រប់គ្រាន់ នឹងបំពេញការងារនេះនិងម្យ៉ាងដោយយល់ថាការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការងារបោះឆ្នោតជាការងារដោយឡែករបស់ គជប ទៅវិញ។ ចំនុចនេះយើងចង់និយាយថា ដោយសារមានចំនុច២ក្នុងហ្នឹងគឺ ចំនុចទី១ គឺឱកាសសំរាប់គាត់ធ្វើការងារមានតិចតួច មិនគ្រប់គ្រាន់ មិនដឹងថា គជប ជាមួយក្រសួងមហាផ្ទៃបានឯកភាពគ្នាក៏រិតណាទេ ដែលផ្តល់អាទិភាពថា ឱ្យការងារចុះឈ្មោះបោះឆ្នោត ក្នុងរង្វង់តែ២០ថ្ងៃទេ ពីថ្ងៃ១ដល់ថ្ងៃ២០នេះ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ អាចជាមេឃុំឬជំទប់ទី១ ឬទី២ឈរជើងផ្ទាល់ជាមួយស្មៀន ដើម្បីទទួលដឹងឮបញ្ជាក់អ្នកដែលខ្វះអត្តសញ្ញាណ ដូចបញ្ជាក់ទំរង់ ១០១៨ អញ្ចឹងធ្វើជូនគាត់ ដើម្បីឱ្យគាត់បានចុះឈ្មោះពេញលេញក្នុងបញ្ជីបោះឆ្នោត អញ្ចឹងយើងឃើញថាឃុំមិនមែនទាំងអស់ទេ ឃុំមួយចំនួនហាក់ដូចជា មិនមែនថាគាត់គេចវេសទេ ប្រហែលជាការងារជាន់គ្នាច្រើន ទី១ប្រហែលជាកិច្ចការរវល់ខាងសិលាក៏មាន ឬក៏ការងារបើកវគ្គរបស់អង្គការណាផ្សេងៗ ដែលថាគេរើសចំថ្ងៃទី១ ដល់ថ្ងៃ២០តែម្តង ។ ឃើញថាបើសិនជាគិតទាំងថ្ងៃយើងជួបមុខ នៅផ្សារក្តី ឬគាត់ដើរកាត់មុខ PEC ក្តី ឬក៏ជួបនៅកន្លែងរតនាគារក្តី ឬក៏មន្ទីរពេទ្យយើងអត់ដឹងទេ យើងឃើញថាអាចឃើញមាន មុខស្មៀនជួនកាលមេឃុំគាត់មកដែរ នេះយើងសួរថាគាត់មកធ្វើអី? គាត់ថាមកដកលុយ ឬក៏មកការងារផ្សេងៗរបស់គាត់នេះយើង ឃើញថាចំនុចណាដែលខ្ញុំលើកថា នៅដំណាក់កាលដែលយើងចុះឈ្មោះក្នុងរយៈកាល២០ថ្ងៃនេះហាក់ដូចជាមិនមានឱកាសគ្រប់គ្រាន់ សំរាប់ឱ្យស្មៀនឃុំឬក៏ក្រុមប្រឹក្សាឃុំ ដែលត្រូវធ្វើកិច្ចការនេះបានពេញលេញនៅមូលដ្ឋានរបស់គាត់។

**ចំនុចទី៣** ការត្រៀមសំរាប់ការពិនិត្យនិងការចូលរួមបោះឆ្នោត ដែលត្រូវបានអនុវត្តតាមសេចក្តីណែនាំរួមរវាង គជប និងក្រសួងមហាផ្ទៃលើលិខិតលេខ០១១ សណន ចុះថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៥កន្លងមកនេះ យើងឃើញថាលិខិតនេះទោះបីបានចេញជាធរមាននិង អាចពង្រាយអនុវត្តតាមការ បញ្ជូនលិខិតការណែនាំបន្តបន្ទាប់ បានន័យថាភាគី២ខ្សែត្រូវទៅព្រមគ្នា គឺខ្សែខាង គជប ក៏ត្រូវមានណែនាំពីខាងបច្ចេកទេសរួម ដោយឡែកខាងសមត្ថកិច្ច របស់ខាងអាជ្ញាធរក្រសួងមហាផ្ទៃក៏បានមានការណែនាំរួម

អញ្ចឹងទៅតាមខេត្ត ស្រុក ភូមិក៏បានដឹងឮ ដូច្នេះមិនមែនដោយសារនេះទេ តែដោយសារការងាររវល់ច្រើនតែម្តង ដូចខ្ញុំឃើញថា យើងអាណិតដែរឃើញស្មៀនឃុំ មេឃុំ ឃើញគាត់ការងារច្រើនអញ្ចឹង ប៉ុន្តែកិច្ចការនេះដូច បងសេរីសោភក្តិ បានលើកឡើងថាការត្រៀមចុះឈ្មោះលិខិតនេះ គឺកំណត់នូវការត្រៀមចុះឈ្មោះ អញ្ចឹងការត្រៀមចុះឈ្មោះក្នុងដំណាក់កាលនេះមានសារៈសំខាន់ណាស់ ដែលគេប្រើទំរង់១០.២៤ សម្រាប់អនុវត្តកិច្ចការត្រៀមចុះឈ្មោះ បានន័យថាមិនទាន់ចុះឈ្មោះជាផ្លូវការទេ ធម្មតាដំណាក់កាលហ្នឹង គឺឃុំអាចប្រមើលមើលច្បាស់លាស់ថានៅក្នុងឃុំរបស់គាត់ហ្នឹង អ្នកដែលមានអាយុគ្រប់១៨ឆ្នាំមានប៉ុន្មាន? តាមរយៈយើងធ្វើសំភាសន៍ទី១ នៅក្នុងត្រីមាសទី១ប្រចាំឆ្នាំ យើងថាពីខែ១ដល់ខែ៦ តែពេលខ្លះអាចខែ៣ខែ៤ គឺស្ថិតិយើងអាចទទួលបានហើយ នៅពេលនេះយើងអាចដឹងថាអ្នកដែលថ្មីចំឡែក ដែលទើបគ្រប់អាយុ ឬអ្នកផ្លាស់ចូលជាមនុស្សថ្មីរបស់ភូមិឃុំយើង អញ្ចឹងគាត់ដឹងឈ្មោះដឹងចំនួនច្បាស់អស់ហើយ អញ្ចឹងខាងស្មៀនមានភារៈកិច្ច អនុវត្តលិខិតលេខ០១១សណននេះ ដើម្បីឱ្យយុវជនទាំងអស់នោះបានមកត្រៀមលក្ខណៈឱ្យបានល្អ ដើម្បីឱ្យដឹងខ្លួនថាគាត់ដល់ពេល ដល់វេលាដែលគាត់ត្រូវចុះឈ្មោះបាន មានសិទ្ធិអនុវត្តសិទ្ធិគាត់បានគ្រប់គ្រាន់ដើម្បីអនុវត្តបានក្នុងពេលនោះ អញ្ចឹងត្រង់ដែរថាគាត់ ដឹងថាគាត់មានអាយុគ្រប់គ្រាន់អាចចុះឈ្មោះបោះឆ្នោតបាន ក៏ប៉ុន្តែល័ក្ខខ័ណ្ឌដ៏ច្បាស់លាស់សំខាន់មួយ ដែលត្រូវឱ្យគាត់មានឯកសារជាអត្តសញ្ញាណ ដើម្បីទៅបង្ហាញនៅពេលចុះឈ្មោះនោះ ដើម្បីមានអាទិភាពច្បាស់លាស់ថាកុំឱ្យមានការប្តឹងផ្តល់និងសញ្ជាតិនេះ សញ្ជាតិនោះ អត់មានល័ក្ខខ័ណ្ឌច្បាស់លាស់ ។ អញ្ចឹងក្នុងដំណាក់កាលហ្នឹងឱ្យយើងត្រៀម បើខ្វះចំនុចណាមួយៗក្នុងល័ក្ខខ័ណ្ឌទាំង៣ទាំង៤របស់យើងនេះ តាំងពីសញ្ជាតិ អាយុ ទីលំនៅអចិន្ត្រៃយ៍សព្វបែបយ៉ាងខ្វះមួយណាអត្តសញ្ញាណណាមួយរបស់គាត់ គាត់ត្រូវបំពេញក្នុងចន្លោះហ្នឹងឱ្យបានគ្រប់គ្រាន់ ដើម្បីត្រៀមខ្លួនក្នុងពេលចុះមែនទែនអត់មានខាតបង់ពេលវេលាច្រើន។ អញ្ចឹងលោកស្មៀនឃុំ បានបញ្ជាក់ថាលោកឈ្មោះ ក នេះគឺមានគ្រប់ចំនុច ហើយនៅខ្វះតែអត្តសញ្ញាណមួយ បានន័យថាអត្តសញ្ញាណគឺជាឯកសារ ភស្តុតាង ច្បាស់លាស់ ដែលបង្ហាញថាឈ្មោះហ្នឹង គឺមានមុខហ្នឹង គឺមុខណាមុខ ក,ខ មុខហ្នឹងគឺនៅក្នុងហ្នឹងតែម្តង គឺជាម្ចាស់ដែលអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការចុះឈ្មោះមិនអាចមាននរណាមកចូលជំនួសបាន មិនអាចមាននរណាដែលអាចបន្លំឈ្មោះនោះទេ អញ្ចឹងយើងឃើញថាលិខិតនេះយើងអាចអនុវត្តបានប្រហែលជា៧០% ដែលអាចបានល្អតែ ៣០%ទៀតឃើញថានៅមានលក្ខណៈខ្វះខាត ប្រហែលជាមានទាក់ទងនឹងការងារផ្សព្វផ្សាយអប់រំផ្សេងៗ យើងកំពុងស្រាវជ្រាវរកឃើញ អញ្ចឹងមានឃុំមួយចំនួនអនុវត្តបានហើយ ប៉ុន្តែនៅមានឃុំមួយចំនួនមិនទាន់បានយល់។ ប៉ុន្តែនេះជាគំនិតល្អរបស់ គជប ក៏ដូចជាក្រសួងមហាផ្ទៃបានឯកភាពគ្នាថានេះជាចំនុចមួយ ដែលបានពញ្ញាក់ស្មារតីរបស់គាត់ ថាដល់ពេលវេលាហើយ មិនមែនជាការធ្វើដោយបង្ខិតបង្ខំទេ ឱ្យដឹងថានាង ឬក៏ខ្លួនខ្ញុំដឹងថាដល់ពេលវេលា ដែលអាចចុះបានហើយ តែបញ្ចូលបានក្នុងបញ្ជីបោះឆ្នោត ទទួលស្គាល់ជាផ្លូវការបានទាល់តែមានឯកសារច្បាស់លាស់ ។

**ចំនុចទី៤** ការផ្សព្វផ្សាយអប់រំទៅសាធារណៈជន យើងនៅពុំទាន់បានទូលំទូលាយស៊ីជំម្រៅ យើងនិយាយថារូបភាពនៃការអនុវត្តផែនការនេះ យើងអនុវត្តបានត្រឹមតែការបញ្ជូនកាសែត ឬក៏ស្ពតផ្សេងៗតាមរយៈស្មៀនឃុំ ឬក៏នៅទីក្រុងយើងប៉ះប៉ូវថវិការខ្លះដើម្បីឱ្យគាត់បានចាក់មេក្រូផ្សព្វផ្សាយឬក៏ធ្វើការបិទនៅតាមទីសាធារណៈមួយចំនួន ដើម្បីឱ្យការចូលរួមរបស់ប្រជាពលរដ្ឋយើងបាន ប៉ុន្តែលទ្ធផលដែលយើងទទួលបាននៅពុំទាន់បានលទ្ធផលល្អប្រសើរនៅឡើយទេ ដោយសារតែ

**ចំនុចទី៥** ជាចំនុចដែលឆ្លុះបញ្ចាំងមកវិញថា ការចុះឈ្មោះរបស់ប្រជាពលរដ្ឋនៅមានក៏រិតទាប ថ្នាក់ទាបមានន័យថា ចង់ដឹងថាក្នុងក៏រិតមិនលើសពី៥០%ទេ អញ្ចឹងបានន័យថាភាគច្រើននៃការចុះឈ្មោះទាបនេះ គឺនៅទីប្រជុំជនតែម្តង នៅទីប្រជុំជនដែលមានផ្សារមានមនុស្សច្រើន។ ចំនុចនេះជាចំនុចមួយដែលចង់ឱ្យអស់លោក ពិនិត្យពិចារណាថា តើមានវិធានការណ៍បែបណាមួយ? ដែល

មានប្រសិទ្ធិភាព ដើម្បីឱ្យការចុះឈ្មោះនៅតំបន់ទីប្រជុំជន មានអត្រាបានកើនជាងមុនបានខ្ពស់ ដើម្បីរួមចំនែកឱ្យការចុះឈ្មោះរបស់យើងបានល្អប្រសើរថែមទៀត ។

ខ្ញុំបាទសុំចូលចំនុចជាអនុសាសន៍ ដែលយើងខ្ញុំបានពិចារណាឆ្លងកាត់នូវបទពិសោធន៍ ដែលបានបង្ហាញកន្លងមកនេះយើងឃើញថា

**ទី១** យើងគួរតែបង្កើនសន្ទុះ នៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដល់ប្រជាពលរដ្ឋ ដែលមានសារៈសំខាន់ជាម្ចាស់សន្លឹកឆ្នោតទាំងអស់នោះ ព្រោះជាការសម្រួលដល់ប្រជាពលរដ្ឋរបស់យើងទាំងអស់នោះ ដើម្បីប្រើប្រាស់ឯកសារអត្តសញ្ញាណ បានន័យថាយើងមិនចាំបាច់ប្រើទំរង់ ១០១៨ ឱ្យពិបាកបិទរូបថត ថតរូបថែមថយពីរបីសន្លឹកនេះស្មុគ្រស្មាញច្រើនណាស់ ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានចុះឈ្មោះនិងបានបោះឆ្នោតដោយជោគជ័យ ។

**ទី២** ក្រសួងមហាផ្ទៃនិងគ្រប់ស្ថាប័នពាក់ព័ន្ធ គួរផ្តល់ឱកាស២០ថ្ងៃពេញលេញជូនដល់ក្រុមប្រឹក្សាស្មៀនឃុំ ដើម្បីធ្វើការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យ នៅតាមភូមិឃុំរបស់ខ្លួន។ យើងឃើញថាគួរតែមានការលះបង់ ឬការបូជាអ្វីមួយសំរាប់តែ២០ថ្ងៃ បានន័យថាក្នុង៣អាទិត្យដែលគាត់ត្រូវមមាញឹកញាប់ដៃដើម្បីអនុវត្តការងារនេះ អញ្ចឹងទាំងខាងកម្មវិធីសិលា កម្មវិធីរបស់ភូមិឃុំ គួរប្រមើលពីដើមឆ្នាំថាក្នុងរង្វង់ពីថ្ងៃ០១តុលាដល់ថ្ងៃ២០តុលា គឺដល់ដំណាក់ការប្រតិបត្តិការ បើធ្វើមិនទាន់មិនអីមានផលវិបាកមួយ ។ អញ្ចឹងគ្នាមានឱកាសតែប៉ុណ្ណឹងទេបានគ្នាធ្វើ កុំឱ្យថានៅកន្លែងខ្លះបិទការិយាល័យមួយខេត្ត ឬក៏បើកលុយរតនាគារអីផ្សេងៗឬក៏ស៊ីផ្សេងៗបើគាត់មានការឈឺថ្កាត់ នោះជារឿងដោយឡែក តែចំពោះរឿងថាការងារជាន់លើជាន់ ជាបញ្ហាមួយដែលគាត់អាចមានលទ្ធភាពមិនគ្រប់គ្រាន់នៅមូលដ្ឋានរបស់គាត់ ដើម្បីធ្វើកិច្ចការនេះបានពេញលេញ ។ អញ្ចឹងឃើញថាកិច្ចការនេះប្រហែលជាយើងមានការពិចារណា បើសិនជាយើងធ្វើបានពេញលេញនោះលទ្ធផល នៃការចុះឈ្មោះអាចទទួលបានជោគជ័យល្អ។

**ទី៣** គួរតែឱ្យមានគ្រូបង្គោលនៅចាំស្រុក ដើម្បីជួយដល់ស្មៀនឃុំ ជាបទពិសោធន៍កន្លងមក យើងឃើញថាក្នុងឆ្នាំ២០០៣ឆ្នាំ២០០៤ នៅមានអនុវត្ត ការប្រើប្រាស់គ្រូបង្គោលនៅចាំស្រុកមិនមែនជាគ្រូទេ ជាគ្រូបង្ហាត់ដែលទទួលការបណ្តុះបណ្តាលផ្ទាល់ពី គជប ហើយដែលបានដឹងការងារច្រើនបន្ថែម ដើម្បីជួយជាជំនួយបន្ថែមប្រចាំស្រុក ស្រុកណាមួយ ឧទាហរណ៍ ស្រុកស៊ីប៉ាន់ សំរាប់៥ឃុំ ដើម្បីឱ្យគ្រូបង្គោលនេះ យើងកំពុងតែចាំមើល គជប ដែរមិនដឹងជាលទ្ធផលយ៉ាងណានៅឡើយទេ។ បើមានបញ្ហានេះ យើងឃើញថាមានការជួយដល់ឃុំហ្នឹង ដូចជាការរៀបចំឯកសារការផ្ទៀងផ្ទាត់ ការកែតំរូវឈ្មោះកន្លងមក ឃើញថាគេធ្វើបានត្រឹមត្រូវល្អ តែក្រោយមកទៀតយើងឃើញថាបាត់មួយកង់ គឺគ្រូបង្ហាត់របស់ស្រុកមួយ គឺធ្វើឱ្យមានភាពមិនទុកចិត្តខ្លួនឯងនូវពេលចាប់ផ្តើមការងារនេះឡើង។

**ទី៤** រៀងរាល់ការបោះឆ្នោតសកល គួរតែមានជំនួយការចុះឈ្មោះបន្ថែមតាមការចាំបាច់ ឧទាហរណ៍ ឃុំមួយចំនួនតែងតែមានសំនូមពរដោយទទូច គាត់ថាឃុំគាត់ធំមានលើសពី១០ការិយាល័យ ហើយចុះ២០ថ្ងៃដូចគេ អត់មានលើសទេ ថាឃុំធំចុះ៣០ថ្ងៃអត់មានទេ។

**ទី៥** ដោយសារលទ្ធផលនៃការចុះឈ្មោះនៅពេលកន្លងមកនេះទាបមានរយៈពេលខ្លីផង ហើយការងារមមាញឹក ម្យ៉ាងទៀតប្រជាជនខ្លះក៏មិនបានចាប់អារម្មណ៍ ខ្លះយល់តាមការផ្សព្វផ្សាយតាមទូរទស្សន៍មានតិចតួចនៅទីក្រុង តែនៅកន្លែងមួយចំនួនអត់មានវិទ្យុផ្សាយសំលេងស្តាប់ រំពឹងលើការប្រើម៉ូតូមួយចាក់មីក្រូផ្សាយទៅពិបាកណាស់។ យើងអត់បានដាក់ថា អ្នកផ្សាយហ្នឹងពាក់ផ្លាក់ផ្សាយឱ្យ គជប ឬឱ្យនរណាទេ បើឮខ្លឹមសារបានដឹងថាផ្សាយឱ្យស្ថាប័នជំនាញ ឬផ្សាយឱ្យការអប់រំ ឬយុទ្ធនាការចុះឈ្មោះចូលរៀនដល់យើងយុទ្ធនាការសំរាប់ ចុះឈ្មោះក្នុង២០ថ្ងៃផ្សាយតាមទូរទស្សន៍អត់ មានតែស្គាតមានដែរ ខ្លះចាប់អារម្មណ៍ ខ្លះមិនចាប់អារម្មណ៍។

យើងឃើញថាបញ្ហានេះ គឺចង់បង្កើនសកម្មភាពការផ្សព្វផ្សាយ ឱ្យមានការទូលំទូលាយបន្ថែម ដើម្បីថាអ្នកមិនបានដឹង គឺមិនអាចដឹងមែនរវល់ការងារ ហើយក៏មិនសូវរវីរវល់មិនសូវអីអញ្ចឹងទៅ បើបានប្រាប់ផ្ទាល់មាត់ ឬបើបានអ្នកជិតខាងគាត់ចេះបានជួយប្រាប់បានច្រើន។

**ទី៦** សុំឱ្យសង្គមស៊ីវិលចូលរួមឱ្យបានច្រើនជាងនេះ ដើម្បីចូលរួមចំនែកឱ្យការផ្សព្វផ្សាយសាធារណៈជន ពិសេសផ្តល់ស្គូតដល់ប្រជាជនឱ្យបានច្រើន ហើយមានលក្ខណៈបានល្អប្រសើរ និងអាចរួមចំនែកក្នុងកិច្ចការនេះបានល្អប្រសើរថែមទៀត។

**ទី៧** គួរបង្កលក្ខណៈល្អលើកទឹកចិត្តថែមទៀតទាំងពេលវេលា ទាំងសំភារៈ ថវិការ ដល់ក្រុមប្រឹក្សាឃុំនិងស្មៀនឃុំ ដើម្បីអនុវត្តការងារនិងបន្តការផ្សព្វផ្សាយជូនព័ត៌មាន និងអនុវត្តឱ្យមានប្រសិទ្ធិភាពក្នុងការត្រៀមបំរើការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ ខ្ញុំសូមអនុញ្ញាតិចូលមកទិសដៅបន្តរបស់លេខាធិការដ្ឋានរៀបចំការបោះឆ្នោត គឺចំនុចទី១ យើងពង្រឹងអភិបាលកិច្ចល្អក្នុងការអនុវត្តការងារ។ ចំនុចទី២ បង្កើនការយល់ដឹងសមត្ថភាពជំនាញបន្ថែម ។ ចំនុចទី៣ ពង្រឹងកិច្ចសហការណ៍ល្អជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរ ដើម្បីលើកកំពស់ការការពារសន្តិសុខ សុវត្ថិភាពនៃការងារបោះឆ្នោត ពិសេសគឺសុំឱ្យមានការគ្រាំទ្រដល់ក្រុមប្រឹក្សាឃុំនាពេលខាងមុខនេះ។ ចំនុចទី៤ ជំរុញនិងលើកទឹកចិត្ត ឱ្យមានការចូលរួមយ៉ាងសកម្មពីគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល ទាំងថ្នាក់ ជាតិនិងអន្តរជាតិ ក្នុងកិច្ចដំណើរការរៀបចំការបោះឆ្នោត។ ចំនុចទី៥ គឺទិសដៅនឹងត្រៀមលក្ខណៈអនុវត្តកិច្ចការនានាប្រចាំឆ្នាំដែល គជប ដាក់ចុះក្នុងនោះយើងពិនិត្យឃើញចំនុច៣សំខាន់ គឺការប្រមូលទិន្ន័យស្រង់ស្ថិតិប្រជាពលរដ្ឋឆ្នាំ២០០៦ ការត្រៀមរៀបចំការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ និងការត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំនៅឆ្នាំ២០០៧។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមសហការឧបត្ថមគាំទ្រដល់កិច្ច ដំណើរការរៀបចំការបោះឆ្នោតនៅខេត្តស្ទឹងត្រែង ក្នុងការអនុវត្តសិទ្ធិអំណាច ភារៈកិច្ច និងការទទួល ខុសត្រូវរបស់ខ្លួនរហូតទទួលបាន លទ្ធផលគួរជាទីមោទន រួមចំនែកដល់ការពង្រឹងលទ្ធិប្រជាធិតេយ្យនៅកម្ពុជា ។

**លោក ឱក សេរី សោភក្តិ៍**

ខ្ញុំបាទសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ហើយជាពិសេសចំពោះភាពស្មោះត្រង់របស់បងប្រធាន PEC ដែលលើកឡើងទាក់ទងទៅនឹងបញ្ហាទាំងអម្បាលមាណដែលមាន យើងគ្រាន់តែស្តាប់គាត់ភ្លាមយើងឃើញថាបន្ទុករបស់ក្រុមប្រឹក្សាឃុំសង្កាត់ហើយនិងស្មៀនឃុំគឺធ្ងន់ណាស់ នេះជាការអំពាវនាវ ឬការស្រែកហៅនៅជំនួយ នៅការយោគយល់អំពីស្ថាប័នពាក់ព័ន្ធ ដើម្បីនឹងធ្វើយ៉ាងណាជួយសំរួលនិងជាពិសេសក្នុងពេល២០ថ្ងៃនោះ។ កិច្ចការទាំងអស់នេះ ខ្ញុំបាទក៏មិនទាន់បានដឹងថា តើមានវត្តមានរបស់ខាងសិលា ខាងPLAU ហើយនិងខាង SPPA បានចូលរួមនៅក្នុងនេះ ព្រោះយើងបានអញ្ជើញទាំងអស់នៅ គ្រប់ខេត្តទាំងអស់ យើងបានជជែកជាមួយខាង SPPA ហើយខ្ញុំបានជជែកជាមួយលោក Scott Leiper នៅភ្នំពេញដែលគាត់ទទួលខាងសិលាថាស្គូតហ្នឹងយើងទទួលឯកភាពជាមួយបងពេញទីថាក្នុង២០ថ្ងៃ និងសុំកុំឱ្យមានដាក់បេសកម្មទៅក្រុមប្រឹក្សាឃុំសង្កាត់ ហើយនិងស្មៀនឃុំជាពិសេសក្នុងឆ្នាំ២០០៦នេះគឺថាគំរោងទាំងអម្បាលមាណ ហើយយើងក៏ធ្វើការជាមួយក្រសួងមហាផ្ទៃ និងសង្គមស៊ីវិលផងដែរ រាល់សិក្ខាសាលា សន្និសីទ្ធឱ្យជៀសថ្ងៃ២០ខែតុលាហ្នឹង ក្នុង២០ថ្ងៃសុំឱ្យជៀសតែម្តង ដើម្បីជាយុទ្ធនាការគំហុកនៅក្នុងការចុះឈ្មោះបោះឆ្នោតឱ្យបាន១០០% ។

នៅក្នុងរឿងនេះយើងឯកភាពគ្នាពេញទីហើយ យើងនឹងធ្វើដូច្នេះឯង ក៏ប៉ុន្តែខ្ញុំក៏ជឿជាក់ផងដែរថា ហើយខ្ញុំឯកភាពខេត្តដទៃៗទៀត ដូចគ្នាអញ្ចឹងជាទំលាប់ប្រជាពលរដ្ឋរបស់យើង លោកមិនដឹងថាទៅចុះត្រៀមធ្វើស្អីចាំដល់ពេលចុះមែនទែនទៅចុះតែម្តងទៅនេះជាទំលាប់ដែលយើងរស់នៅមិនធ្លាប់មានអត្តសញ្ញាណប័ណ្ណ មិនធ្លាប់មានសំបុត្រស្នាម ម្ល៉ោះហើយម្នាក់ៗមិនមើលឃើញសារៈប្រយោជន៍នៃអញ្ចឹងទេ តែឥឡូវចាប់ផ្តើមមើលឃើញដោយសារត្រូវការទៅធ្វើការ ដោយសារត្រូវការទៅសុំច្បាប់គេ សុទ្ធតែត្រូវការសំបុត្រស្នាមទាំងអស់ ។ ខ្ញុំបាទជឿថានេះជាការធម្មតាទេទំលាប់តែយើងទើបតែចេញពីសង្គ្រាម យើងត្រូវការពេលមួយចំនួន ដើម្បីប្តូរការយល់ឃើញ ហើយនឹងទំលាប់របស់យើងប្រចាំថ្ងៃរបស់យើង ប៉ុន្តែការដែលយើងធ្វើយុទ្ធនាការរួមទាំងអស់គ្នាទៅអាចនឹងកែប្រែរឿងទាំងអស់នេះបាន។ ក្នុងរឿងនេះផងដែរឃើញថានៅមានរឿង២ទៀតដែលខ្ញុំបាទគិតថា ខេត្តឯទៀតៗបានធ្វើមកល្អណាស់ គឺរឿងស្ត្រីដោយខ្ញុំបាទបានឃើញវត្តមានរបស់បងស្រីហើយ និងក្មួយស្រីច្រើនណាស់នៅកន្លែងនេះ ខ្ញុំបាទសង្ឃឹមថាបញ្ហាស្ត្រីនឹងបានលើកឡើង ហើយរឿងយុវជនចលនាដែលយើងជួយយុវជនមានអាយុ១៨ឆ្នាំ និងឱ្យគាត់មានការទទួលខុសត្រូវក្នុងឋានៈជាប្រជាពលរដ្ឋដោយចាប់ផ្តើមឡើងចុះឈ្មោះទៅធ្វើអត្តសញ្ញាណប័ណ្ណ ហើយនិងចុះឈ្មោះបោះឆ្នោត។

**លោក ពុយ ចាន់ថាឡា** អនុប្រធានគណបក្សសមរង្ស៊ីខេត្តស្ទឹងត្រែង

ជាបឋមខ្ញុំបាទសូមគោរព លោក ឡាវី ស្រេង្គន្ធ ជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI សូមគោរពលោក ឱកសេរីសោភក្តិ ជាទីប្រឹក្សានិងជាអ្នកសំរបសំរួលយន្តការខប់សែលនៃវិទ្យាស្ថាន CDRI សូមគោរពលោកពុយ ចាន់ថាឡាក់ជាប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង និងសូមគោរព អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលមានវត្តមាននៅក្នុងពេលនេះ។ ទន្ទឹមនេះខ្ញុំសូមអរគុណចំពោះ លោកពុយចាន់ថាឡាក់ ដែលលោកបានជួយធ្វើការនៅក្នុងយុទ្ធនាការនៅក្នុងការរៀបចំការបោះឆ្នោតតាំងពីការចុះឈ្មោះ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោតទាំងអស់ ឱ្យមានដំណើរការល្អត្រឹមត្រូវ ឃើញថារបាយការណ៍របស់លោកគឺថាមានភាពយុត្តិធម៌ត្រឹមត្រូវ។ មួយទៀតសោធសុំផ្តល់អនុសាសន៍ក៏ដូចជាលើកនូវសំនូមពរខ្លះ ដើម្បីជូនអង្គប្រជុំនៅពេលនេះឱ្យបានជ្រាបពីសភាពការណ៍ជាក់ស្តែងដែលគណបក្សនយោបាយរបស់យើងខ្ញុំបានអនុវត្ត បានឃើញ បានពិនិត្យផ្ទាល់ មានដូចខាងក្រោមនេះ។ **ទី១** បញ្ហាការផ្សព្វផ្សាយ ការចុះឈ្មោះបោះឆ្នោត ការពិនិត្យឈ្មោះ ការឃោសនានៃការបោះ គឺសូមឱ្យទិសដៅទៅអនាគតឱ្យមានភាពទូលំទូលាយ តាំងពីការប្រើប្រាស់មីក្រូ រយៈពេលឱ្យបានសមស្រប។ ដូចលោកប្រធាន PEC បានមានប្រសាសន៍ថាឃុំណាធំហើយការចុះឈ្មោះមិនទាន់អស់សុំឱ្យមានការបន្ថែមពេលវេលា នេះគឺការត្រឹមត្រូវមួយល្អខ្ញុំសូមគាំទ្រគំនិតនេះ។

**ទី២** សុំឱ្យមានការចាប់អារម្មណ៍ លើពាក្យបណ្តឹងផ្សេងៗរបស់គណបក្សនយោបាយ ដែលបានដាក់ជូនទៅទាំងការិយាល័យ CEC PEC រហូតដល់ NEC ឬក៏ក្រុមប្រឹក្សាឃុំផ្សេងៗ ព្រោះកន្លងមកឃើញថា ខាងអាជ្ញាធររៀបចំការបោះឆ្នោត ពិសេសក្រុមដោះស្រាយវិវាទ ខាងក្រុមលេខាធិការដ្ឋាន PEC ដូចជាមិនសូវយកចិត្តទុកដាក់លើពាក្យបណ្តឹងផ្សេងៗដែលពាក់ព័ន្ធដល់គំនិតរបស់ខ្លួនដែលជាគណបក្សកាន់អំណាចផ្សេងៗ គឺគាត់មិនសូវយកចិត្តទុកដាក់ ច្រើនតែពន្យារពេលតិចៗ យឺតហួសពេលតែម្តង គឺអស់សុពលភាពនៃបណ្តឹង។ ឧទាហរណ៍ នៅឃុំស្ទឹងត្រែងនៅការិយាល័យ ផុន ភារុណ លោកម៉ែស៊ីរួត គាត់បានទៅចុះឈ្មោះបោះឆ្នោតទៅបោះឆ្នោតពេលនោះ ក្រុមប្រឹក្សាឃុំគេអត់ទាន់ចែកប័ណ្ណបោះឆ្នោតទេ គៀកថ្ងៃបោះឆ្នោតគេចែកប័ណ្ណ ឈ្មោះម៉ែស៊ីរួតអត់ទាន់បានប័ណ្ណទេ ដល់អត់បានប័ណ្ណនោះគាត់បានរាយការណ៍ប្រាប់គណបក្សនយោបាយដែរ ហើយគណបក្សនយោបាយបានទៅទាក់ទងស្រាប់តែដល់ថ្ងៃបោះឆ្នោតអត់មានប័ណ្ណ គឺលោកគ្រុយប្រធានភូមិ បានយកប័ណ្ណហ្នឹងទៅឱ្យអ្នកដទៃ ប័ណ្ណបោះឆ្នោតរបស់ម៉ែសារួតដល់អញ្ចឹងទៅខាងគណបក្សនយោបាយគេទៅទាមទារឬធ្វើសំណើទំរង់មេឃុំស្ទឹងត្រែង ហើយមេឃុំស្ទឹងត្រែងបានចេញវិញ្ញាបនបត្រ

ឱ្យគាត់ទៅបោះឆ្នោត ដល់ពេលទៅបោះឆ្នោតនោះ គឺឈ្មោះម៉ែសារួតគេគូសបាត់ទៅហើយ អញ្ចឹងទេគណបក្សនយោបាយបានដាក់ពាក្យបណ្តឹងទៅតាមក្រោយ ថាមានពេលតែត្រឹមម៉ោង៣រសៀលគឺចប់ ដូច្នេះអាជ្ញាធររៀបចំការបោះឆ្នោតគឺមិនសូវមានការវីវរល់ច្រើនតែយកលេសអញ្ចេះអញ្ចុះ ព្រោះថាអស់ពេលម៉ោង៣អស់ពេលបោះឆ្នោត ដូច្នេះលោកម៉ែសារួតមិនបានបោះឆ្នោត មានឈ្មោះក្នុងបញ្ជីតែមិនបានបោះឆ្នោត។ ខ្ញុំសំនូមពរទៅថ្ងៃក្រោយទៀត សុំកុំឱ្យមានបញ្ហានេះកើតឡើងម្តងទៀត បើមានបញ្ហាហ្នឹងកើតឡើងទៀតច្បាស់ជាមានភាពរញ៉េរញ៉ៃនៅក្នុងការបោះឆ្នោតហើយ។

**ទី៣** សុំឱ្យមានការបញ្ចូលគណបក្សទាំង៣ ដែលមានអាសនៈសំរាប់សភាចូលជា សមាជិក PEC, NEC, CEC រហូតដល់ PSO ទាំងអស់ទៀតយ៉ាងម៉េច ។ ព្រោះឃើញថាកន្លងមកនៅខេត្តស្ទឹងត្រែង ច្រើនតែជ្រើសរើសយកគ្រូបង្រៀន ពេទ្យផ្សេងៗចូលក្នុងមន្ត្រីការិយាល័យបោះឆ្នោត តាំងពីថ្នាក់លើដល់ក្រោម ប៉ុន្តែខ្ញុំឃើញថានៅក្នុងរដូវពេលបោះឆ្នោតនោះ គ្រូសឹងតែ បិទសាលាស្ទើតែទាំងអស់ សាលាខ្វះគ្រូ កូនសិស្សគ្មានគ្រូបង្រៀន ពេទ្យស្រុកខ្លះខ្វះគ្រូពេទ្យព្យាបាលជំងឺប្រជារាស្ត្រដែលទៅព្យាបាល ដូច្នេះមិនចំនេញដល់បញ្ហាហ្នឹង អញ្ចឹងទេខ្ញុំសូមឱ្យមានការបញ្ចូលជាគណបក្សនយោបាយ នៅក្នុងអាសនៈរដ្ឋសភាចូលទៅក្នុងមន្ត្រី PEC NEC នេះឱ្យមានយុត្តិធម៌ទៅតាមការដែលអាចធ្វើទៅបាន។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ ខ្ញុំសុំលើកពីមេភូមិកោះស្នែងលោកស្រី ម្នាក់គាត់ជាប្រធាន CEC នៅទីនោះដល់គាត់រើសមន្ត្រីការិយាល័យបោះឆ្នោត គាត់រើសកូនគាត់ ហើយនីតិវិធីត្រូវអាយុមិន ក្រោម២២ឆ្នាំទេ ដែលអាចធ្វើជាមន្ត្រីបោះឆ្នោតបាន ប៉ុន្តែកូនគាត់នៅស្ទឹងត្រែងអ្នកមានឈ្មោះត្រូវបោះឆ្នោតនៅខេត្តស្ទឹងត្រែង ទៅធ្វើមន្ត្រីការិយាល័យបោះឆ្នោតនៅឃុំកោះស្នែង សួរថា ទី១ គាត់ខុសមិនគ្រប់អាយុ ទី២ អាសយដ្ឋានគាត់នៅស្ទឹងត្រែង ព្រោះល័ក្ខខ័ណ្ឌគេ គឺថាឈ្មោះនៅឃុំណាយកឈ្មោះនោះធ្វើមន្ត្រីបោះឆ្នោត តែនេះយកពីនេះទៅធ្វើមន្ត្រីបោះឆ្នោត តើគាត់បានទៅបោះឆ្នោតនៅឃុំស្ទឹងត្រែងទេ ? ពីឃុំកោះស្នែងមកឃុំស្ទឹងត្រែង ដូច្នេះខកមួយសន្លឹករបស់គាត់ ហើយដោយសារគាត់ជាប់ទៅធ្វើមន្ត្រីនោះ ដោយពេលវេលាគៀក ឃើញថារាយការណ៍ជូនខាង PEC ដែរ PEC ថារួតអស់ពេលវេលាហើយ ឃើញថាការសំរេចលើកក្រោយគឺសុំឱ្យស្រប ទៅតាមនីតិវិធីផ្សេងៗដែលបទបញ្ជាការបោះឆ្នោតបានចែងឡើងផង។

**ទី៤** បញ្ហាការិយាល័យបោះឆ្នោត នៅខេត្តស្ទឹងត្រែងមានការិយាល័យ២ ដែលមានប៉ះពាល់ដល់នីតិវិធី នៃការិយាល័យបោះឆ្នោតតាមច្បាប់គេមិនឱ្យដាក់ការិយាល័យបោះឆ្នោតនៅផ្ទះមន្ត្រីមានអំណាចទេ ផ្ទះចៅហ្វាយស្រុក ចៅហ្វាយខេត្ត ឬក៏សាលាស្រុកផ្សេងៗទេ ក៏ប៉ុន្តែនៅក្នុងខេត្តស្ទឹងត្រែងគឺមានការិយាល័យ២ មួយការិយាល័យលោកម៉ៅប៊ុនកែវ ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ។ ខ្ញុំសូមឱ្យខាង PEC ពិចារណាឡើងវិញ ព្រោះការិយាល័យ លោកម៉ៅប៊ុនកែវ ជាអភិបាលរងស្រុកថាឡាបរិវ៉ាត់។ មួយវិញទៀតការិយាល័យផ្ទះ លោកឃឹមសារ៉េត នៅឃុំស្រះឬស្សី ការិយាល័យ លេខ០០៥២ គាត់ក៏ជាមន្ត្រីរាជការមានមុខតំណែងជាប្រធានអាកាសចរកម្ពុជា ខេត្តស្ទឹងត្រែងដែលគាត់ជាមន្ត្រីថ្នាក់ដឹកនាំខ្ពស់ដែរ សុំឱ្យខាងអង្គប្រជុំនិងលោកប្រធាន PEC ពិចារណារសំណើរនេះឡើងវិញប្រសិនបើអាចទៅបាន។

**ទី៥** ពាក់ព័ន្ធនឹងបញ្ហាថ្មី ដែលទាក់ទងនឹងការបោះឆ្នោតព្រឹទ្ធសភា ឃើញថាឡានគណបក្សមានអំណាចខ្លះៗ ជូនអ្នកបោះឆ្នោតចូលទៅដល់ក្នុងការិយាល័យបោះឆ្នោតតែម្តង តែបើគិតតាមនីតិវិធី សូម្បីតែក្រៅពីអ្នកបោះឆ្នោត គេមិនឱ្យចូលទៅក្នុងការិយាល័យទាំងបរិវេនក្នុងទាំងក្រៅទេ ។ ដូច្នេះឡានសំនូមពរថាឱ្យចតនៅកន្លែងខាងក្រៅ១០០ម៉ែត្រ ក្រៅបរិវេនការិយាល័យបោះឆ្នោត។ មួយទៀតការចងបដារ ឃើញថានៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតព្រឹទ្ធសភា ការចងបដាររបស់គណបក្សប្រជាជនមានដាក់ទទឹងផ្លូវខ្ញុំទៅសួរ PEC ទាក់ទងនឹងវិស័យច្បាប់ ខ្ញុំសួរថាលោកមានឃើញទេ? គាត់ថាឃើញ ប៉ុន្តែគាត់មិនចាប់អារម្មណ៍ គាត់មិនមាន

វិធានការទាល់តែគ្រប់គណបក្សនយោបាយទៅធ្វើពាក្យបណ្តឹងអញ្ចឹងទៅបានគាត់ធ្វើការ ឧទាហរណ៍ លោកប៉ូលីសឃើញចោរមួយលួចអីវ៉ាន់អញ្ចឹងគាត់អត់គិតទេ ដល់ឃើញគេទៅប្តឹងបានគាត់ធ្វើការ។ សំនូមពរថាឱ្យតែឃើញទង្វើណាខុស សូមឱ្យមន្ត្រី PEC រៀបចំចាត់វិធានការទប់ស្កាត់ភ្លាមៗកុំឱ្យមានបញ្ហាកើតឡើង។ មួយទៀតបញ្ហាធ្វើអត្តសញ្ញាណប័ណ្ណ នៅក្នុងខេត្តស្ទឹងត្រែងក៏មិនខុសពីរតនៈគីរី មណ្ឌលគីរីប៉ុន្មានដែល លោក ឱក សេរីសោភ័ក្ត្រ និយាយខ្ញុំសូមគាំទ្រ កន្លងមកសំនូមពរឱ្យក្រសួងមហាផ្ទៃ ឬក៏លោកស្នងការខេត្ត សូមពិនិត្យលើអ្នកធ្វើអត្តសញ្ញាប័ណ្ណ សញ្ជាតិខ្មែរ ឃើញថាកន្លងមកខ្ញុំព្ហខ្លះ ឃើញថាគ្រាន់តែលុយបីបួនម៉ឺន ក៏បានអត្តសញ្ញាប័ណ្ណបានដែរ ដូច្នេះសូមឱ្យពិនិត្យមើលត្រង់ហ្នឹង មុននឹងចូលសញ្ជាត្តិខ្មែរ ត្រូវមានព្រះរាជក្រឹត្យអីផ្សេងៗឬត្រូវមានថវិការបង់ស្អីច្រើនណាស់ ព្រោះបើយើងអត់គិតពីបញ្ហានេះទេ ជនបរទេសគាត់អាចជ្រៀតចូលមកក្នុងការបោះឆ្នោត ធ្វើសេចក្តីសម្រេចជ្រើសរើសអ្នកដឹកនាំរបស់យើង។ ហើយបន្ទាប់មកទៀតបើ ជនអន្តោប្រវេសនផ្សេងៗមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនោះ គាត់មានសិទ្ធិទិញដី ទិញផ្ទះ ។ ដូច្នេះបើយើងមិនចាប់អារម្មណ៍ពីការធ្វើអត្តសញ្ញាណប័ណ្ណនេះទេ គឺបញ្ហាក្រោយយើងអាចមានផលវិបាកទៅថ្ងៃក្រោយទៀត ។

មួយទៀត បញ្ហាទិញដូរសន្លឹកឆ្នោតក្នុងការបោះឆ្នោតព្រឹទ្ធសភា ឃើញថាមានការទិញដូរសន្លឹកឆ្នោត ពីគណបក្សមួយចំនួននៅលើគណបក្ស សមរង្ស៊ី នេះជាទង្វើមួយដែលមិនគួរគប្បី ។ ដូចលោក ឱកសេរីសោភ័ក្ត្រ លើកឡើងពីបញ្ហាមុននេះអញ្ចឹង ថាសុំកុំឱ្យមានរាត្រីឆ្កែព្រួស ហើយសូមឱ្យការបោះឆ្នោតមានជ័យជំនះ ដោយការអនុវត្តតាមកិច្ចសន្យាជួយប្រជារាស្ត្របានល្អប្រពៃ។ ខ្ញុំសូមសំនូមពរថ្ងៃក្រោយកុំឱ្យមានការទិញដូរសន្លឹកឆ្នោត ព្រោះធ្វើឱ្យលទ្ធផលនៃការបោះឆ្នោតរបស់យើងមិនមានតម្លាភាព។ ម្យ៉ាងវិញទៀតមូលហេតុទំនាស់នៃការបោះឆ្នោតរដ្ឋសភាកន្លងមក ជ្រើសតាំងតំណាងរាស្ត្រ មានភាពរញ៉េរញ៉ៃសម្បើមណាស់ យើងពិនិត្យឃើញថាមូលហេតុអី ? ដែលការបោះឆ្នោតឃុំ មានភាព រលូនល្អ គ្មានទំនាស់ទាំងអស់ ទូទាំងប្រទេសរឿងបែងចែកអាសនៈហើយហេតុអី ? បានជាការបោះឆ្នោតតំណាងរាស្ត្រនោះមានបញ្ហារញ៉េរញ៉ៃច្រើនណាស់ ខ្ញុំឃើញថាច្បាប់បោះឆ្នោតតំណាងរាស្ត្រ ក្នុងច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ ហើយការគ្រប់គ្រងច្បាប់រដ្ឋបាល ការគ្រប់គ្រងរដ្ឋបាលភូមិ សង្កាត់ ខុសគ្នា គឺថាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និង ច្បាប់បោះឆ្នោតឃុំសង្កាត់គឺថាអ្នក ណាជាប់លេខ១ កាន់ស្អី ? លេខ២កាន់ស្អី ? អញ្ចឹងទៅគេចែកគ្នាជាបន្តបន្ទាប់ទៅក្រោយពីការបោះឆ្នោតគេដឹងតួនាទីរួចការបោះឆ្នោតហ្នឹងអត់មានបញ្ហាទំនាស់ទេ។ ដោយឡែកការបោះឆ្នោតតំណាងរាស្ត្រនេះឃើញថាអត់មានចែងរបៀបនេះ គឺគណបក្សណាឈ្នះឆ្នោតកាន់អី ? ប៉ុន្មានភាគរយស្អីៗ មាននាទីកាន់ស្អីៗនោះ គឺអត់មានបែងចែកអាសនៈរួចស្រេចដើម្បីឱ្យដឹងថាក្រោយពីគេបោះឆ្នោតរួចទៅ គាត់ដឹងតួនាទីរបស់គាត់គឺមិនទាស់គ្នាថាអ្នកឯងយកប៉ុននេះភាគរយ នោះប៉ុននេះភាគរយនាំឱ្យមានបញ្ហា។ សុំឱ្យរដ្ឋសភា រៀបចំការបង្កើតច្បាប់ឱ្យបានទូលំទូលាយសុក្រឹត្យ ដូចច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។

បញ្ហាមួយទៀតគឺការផ្លាស់ប្តូរ ក្រុមប្រឹក្សាឃុំរបស់គណបក្សនយោបាយដែលក្រុមប្រឹក្សាឃុំ គាត់អសមត្ថភាព ឬក៏មរណៈភាព ឬក៏អស់សុពលភាពពីគណបក្ស នយោបាយ កន្លងមកគណបក្សនយោបាយបានធ្វើសំណើទៅខាងឃុំ ហើយឃុំជូនសំណើទៅខាង POLA គឺថាឃើញថាតាម ច្បាប់ក្នុង នីតិវិធី ក្រោយពីគណបក្សនយោបាយធ្វើសំណើទៅផ្លាស់ប្តូរនោះ គឺរយៈពេលយ៉ាងយូរ១៤ថ្ងៃ គឺត្រូវធ្លាក់មកជូនទាំងអ្នក ថ្មីចូលកាន់តំណែង ប៉ុន្តែតាមសំណើរបស់ខាងខ្ញុំបាទសមរង្ស៊ី ច្រើនតែហួស១៤ថ្ងៃហួសទៅជាង១០ដងហើយ ឧទាហរណ៍ លោកឃុំនោះធ្វើភាពមិនត្រឹមត្រូវទាំងអស់ ការងារនេះរាំងស្ទះនៅ POLA អញ្ចឹងទេខាងខ្ញុំទៅសួរ គេថាឃុំអត់មានមកអើត ដល់សួរឃុំគេថាគេទៅអើតដែរ ជួនកាលជួប ជួនកាលអត់ជួប ដូច្នេះសុំឱ្យមន្ត្រីហ្នឹង ជួយរៀបចំធ្វើម៉េចស្របទៅតាមនីតិវិធីស្តីពីច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ដែលក្រោយពីគណបក្សនយោបាយ ស្នើទៅនោះសុំឱ្យបានយ៉ាងយូរត្រឹម១៤ថ្ងៃ។ សំនូមពរចុង

ក្រោយសុំឱ្យបង្កើតសៀវភៅមួយគេហៅថាសៀវភៅមគ្គុទេសនៃការងារជាអ្នកបោះឆ្នោត ព្រោះកន្លងមកខ្ញុំឃើញថាសៀវភៅនេះដូចជាបង្កើតកាលពី២អាណត្តិមុនសៀវភៅនោះល្អណាស់ ថាតើអ្នកបោះឆ្នោតត្រូវជ្រើសរើសអ្នកដឹកនាំរបៀបម៉េច ? ដើម្បីអ្នកដឹកនាំនៅទូទាំងភូមិ ឃុំ ស្រុក ខេត្ត នៅទូទាំងប្រទេសឱ្យបានល្អសៀវភៅនោះមាន ប៉ុន្តែកន្លងមកនេះមិនមាន ខ្ញុំសូមឱ្យបានប្រាកដនូវសៀវភៅនឹងឱ្យបានចែកទៅគ្រប់អ្នកបោះឆ្នោតបើមិនបានគ្រប់អ្នកបោះឆ្នោតក៏បានមួយគ្រួសារមួយដែរ ដើម្បីឱ្យគាត់ថ្លឹងថ្លែងថាសន្លឹកឆ្នោតមួយសន្លឹករបស់យើងហ្នឹងឱ្យតំលៃទៅលើអ្នកណា។

**លោក ឱក សេរី សោភ័ក្តិ**

សៀវភៅដែលនិយាយហ្នឹង បានរៀបចំឡើងដោយអង្គការមួយឈ្មោះអង្គការ AC អង្គការច្បាប់សង្គម ខ្ញុំនឹងនាំពាក្យនេះទៅប្រាប់អង្គការនេះ។ កាលដែលបងតំណាងខាងគណបក្សសមរង្ស៊ីមានប្រសាសន៍ធ្វើឱ្យខ្ញុំស្រមៃនឹកឃើញដល់ខប់សែលតំបូង ពេលនោះឯកឧត្តម ម៉េងរីតា គាត់មកចូលរួមគឺក្តៅកគុកតែម្តង ជាមួយគណបក្សប្រជាជន ដល់ពីបីនាទីក្រោយមក គឺថាគៀកកគ្នាតែម្តង ព្រោះថាពេលនោះបង ម៉េងរីតាមានប្រសាសន៍ គឺថាបើសិនជាពេលនាទីហ្នឹងតែបួនប្រាំនាទីគាត់មានប្រសាសន៍ដល់២០នាទី ដល់អញ្ចឹងទៅអ្នកឯទៀត១ដែលចង់មានប្រសាសន៍ដែរនោះគាត់ធុញថប់ តែដល់យូរ១ទៅ ឯកឧត្តមម៉េងរីតា សំឡឹងមើលឃើញគាត់ប្តូរយុទ្ធសាស្ត្រវិញ លោកលើកម្តងតែមួយរឿងពីររឿងហើយឱ្យអ្នកឯទៀតមានប្រតិកម្ម ដល់លោកប្តូរអញ្ចឹងទៅបរិយាកាសស្រួលតែម្តង។ អញ្ចឹងហើយបានខ្ញុំថាបងលើកតែ២ឬ៣ចំនុច រួចហើយឱ្យអ្នកឯទៀតនឹងបានលើកផងដែរ ។

**លោក ពុយចាន់ថាឡា** ខ្ញុំសុំឱ្យមានការប្រជុំខប់សែលប្រ៉ម នៅពេលមុននិងក្រោយការបោះឆ្នោតនីមួយ១។

**លោក ឱក សេរី សោភ័ក្តិ**

ចំនុចលោកលើកឡើងចុងក្រោយ លោក ឡាវី ស្ត្រេន្ទ គាត់នៅទីនេះស្រាប់ហើយខ្ញុំជាអ្នកសម្របសម្រួលយើងក៏ខំប្រឹង ហើយយើងក៏មានគំរោងអញ្ចឹងដែរ ដើម្បីធ្វើឱ្យដូចអ្វីដែលបងមានប្រសាសន៍។

**លោកឈិត នោម** លេខាធិការរង គណបក្សហ្វ៊ុនស៊ិនប៉ិច

ជាបឋមខ្ញុំបាទសូមគោរពលោក ឡាវី ស្ត្រេន្ទ ជានាយក ប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជាលោក ឱក សេរី សោភ័ក្តិ ជាទីប្រឹក្សានិងជាអ្នកសម្របសម្រួលយន្តការខប់សែលនៃវិទ្យាស្ថាន លោកពុយ ចាន់ថាឡាក់ ប្រធានលេខាធិកាដ្ឋានរៀបចំការបោះឆ្នោត ខេត្តស្ទឹងត្រែង និងសូមគោរព អស់លោក លោកស្រីទាំងអស់។ ក្រោយពីបានស្តាប់របាយការណ៍របស់លោកពុយ ចាន់ថាឡាក់ដែលបានបញ្ជាក់ខាងដើមកន្លងមកនេះ ខ្ញុំពិនិត្យឃើញថាមានលក្ខណៈល្អត្រឹមត្រូវណាស់ ទន្ទឹមនិងនេះខ្ញុំមានការចាប់អារម្មណ៍បន្តិចចំពោះបញ្ហាការចុះឈ្មោះបញ្ជី និងបញ្ជីឈ្មោះដែលពាក់ព័ន្ធទៅលើបញ្ហាអត្តសញ្ញាណ។ នៅក្នុងមូលដ្ឋានរបស់យើងខ្ញុំនីមួយ១ ក៏មានការព្រួយបារម្ភដែរថាការ ពិនិត្យបញ្ជីឈ្មោះជួបបញ្ហាលំបាកពិសេស គឺការសរសេរឈ្មោះមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ ចំពោះមុខគឺជួបបញ្ហាលំបាកដល់ពេលការបោះឆ្នោត។ បញ្ហាទី១ បងប្អូនយើងភាគច្រើននៅតាមមូលដ្ឋានមិនសូវយល់ដឹង ពិសេសអត់យល់ដឹងថាខ្លួនមានកាតព្វកិច្ចនៅក្នុងការបោះឆ្នោត ហាក់ដូចជាមិនបានដឹងឮក្នុងការចូលរួមចុះឈ្មោះបោះឆ្នោត ។

ខ្ញុំសូមសំនូមពរឱ្យសមត្ថកិច្ចក៏ដូចជាអាជ្ញាធរធ្វើយ៉ាងណា មេត្តាអប់រំផ្សព្វផ្សាយឱ្យបងប្អូនបានយល់ជ្រាបយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនឱ្យបានចុះឈ្មោះឱ្យបានត្រឹមត្រូវ ហើយទន្ទឹមនឹងនេះទៀត អ្នកដែលមានប័ណ្ណបោះឆ្នោតហើយនោះ ភាគច្រើនគាត់អត់ចាប់អារម្មណ៍ ។ នេះជាបញ្ហាដែលអាចនាំឱ្យពេលបោះឆ្នោត ប្រហែលជាមានបញ្ហាមួយស្មុគ្រស្មាញ បាត់អត្តសញ្ញាណប័ណ្ណ បាត់ប័ណ្ណបោះឆ្នោត។ មួយទៀតរឿងបញ្ហាថ្ងៃ ខែ ឆ្នាំកំណើត បងប្អូនមិនយល់ទេ ភាគច្រើនអ្នកដែលមកចុះថ្ងៃកំណើតគឺយល់ព្រាវ១ ដើម្បីឱ្យ

ងាយចាំដាក់ថ្ងៃ ០១ខែ០១ឆ្នាំ១៩៨៤ អញ្ចឹងទៅអ្នកដែលសួរឆ្លើយប៉ុណ្ណឹងទៅដល់ថ្ងៃក្រោយគាត់ភ្លេចទៅទៀត បញ្ហាហ្នឹងហើយដែលខ្ញុំឃើញថាជួបឧបស័គ្គ ។ មួយទៀតសំនូមពរ លើគោលការណ៍ផ្សព្វផ្សាយ ធ្វើយ៉ាងណាឱ្យបានមុនពេលនិងឱ្យបានយូរបន្តិចជៀសវាងថាកន្លងមកបួនប្រាំថ្ងៃឬមួយអាទិត្យ មានគោលការណ៍ថ្នាក់លើដាក់មកហើយ ដូច្នេះការរៀបចំមានបញ្ហាមួយជួបការលំបាកពិសេសនៅក្នុងខេត្តស្ទឹងត្រែង គឺមធ្យោបាយចុះឡើងចំនាយអស់ថវិការច្រើនណាស់រឿងចំនងពាក់ព័ន្ធតាមបណ្តាឃុំនីមួយៗ។ មួយទៀតរឿងបញ្ហាឈ្មោះនឹងកែសម្រួលនេះ សុំឱ្យស្មៀនឃុំឯកភាពថាធ្វើអ្នកដែលក្នុង២០ថ្ងៃនោះឱ្យស្មៀនឃុំ និងមេឃុំ គឺចេះអចិន្ត្រៃយ៍នៅក្នុងការបោះឆ្នោត ប៉ុន្តែក្នុង២០ថ្ងៃដែលឱ្យជាអចិន្ត្រៃយ៍រៀបចំការបោះឆ្នោតនេះក្រែងមិនបានប្រសិទ្ធិភាព។ ប៉ុន្តែបញ្ហាទី១ស្មៀននៅឯខាងនោះទៅ មេឃុំឯនេះ ដល់ពេលបញ្ជាក់ ដូចជាការកែតំរូវឈ្មោះ ហើយត្រូវការហត្ថលេខាមេឃុំ ហើយនៅខ្វះស្មៀនរកត្រាពីស្មៀនទៀត អញ្ចឹងធ្វើយ៉ាងណាឱ្យការចុះឈ្មោះបានមូលផ្តុំ ដើម្បីឱ្យងាយស្រួលលើបញ្ហាការបោះត្រា និងទទួលស្គាល់អត្តសញ្ញាណប័ណ្ណត្រឹមត្រូវ ។

**លោកស្រី សុនសេរីវណ្ណ** ជំទប់ទី២ឃុំស្ទឹងត្រែងគណបក្សហ៊្វុនស៊ិនប៉ិច

នាងខ្ញុំសូមគោរព លោកឡារី ស្រេដ្ឋ ជានាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ កម្ពុជា លោក ឱក សេរី សោភក្តិ៍ ជាទីប្រឹក្សានិងជាអ្នកសម្របសម្រួលយន្តការខប់សែលនៃវិទ្យាស្ថាន លោកពុយចាន់ថាឡាក់ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង និងសូមគោរព អស់លោក លោកស្រីទាំងអស់ដែល នៅក្នុងពិធីសិក្ខាសាលានេះ ទាំងអស់ ។ នាងខ្ញុំសុំចូលរួមយោបល់បន្តិចរឿងអត្តសញ្ញាណប័ណ្ណឈ្មោះដែលខុសការធ្វើអត្តសញ្ញាណប័ណ្ណនេះ នាងខ្ញុំចុះបញ្ជីបញ្ជាក់អត្តសញ្ញាណកំណើត ឃើញថាអត្តសញ្ញាប័ណ្ណធ្វើខុសច្រើនណាស់បើតាមស្រួលចុះឈ្មោះបោះឆ្នោតហ្នឹង ខ្ញុំយកតាមបញ្ជីបញ្ជាក់កំណើតល្អជាង ព្រោះយើងខ្ញុំដែលចុះបញ្ជីបញ្ជាក់កំណើតគឺស្រង់តាមឈ្មោះដែលអស់លោកប្រើសព្វថ្ងៃ និងតាមការចុះឈ្មោះបោះឆ្នោត។ ខ្ញុំគ្រាន់តែបញ្ជាក់ថាអត្តសញ្ញាប័ណ្ណមានការខុសច្រើន តែចំពោះបញ្ជាក់កំណើតខាងនាងខ្ញុំធ្វើត្រឹមត្រូវណាស់ ឥឡូវនេះបើយើងយកបញ្ជាក់កំណើតយើងអាចយកបាន ព្រោះអីប្រជាពលរដ្ឋខាងឃុំខ្ញុំ ធ្វើតាំងពីឆ្នាំ២០០២រហូតដល់ឆ្នាំ២០០៦នេះ។ ដល់ពេលយុទ្ធនាការចុះឈ្មោះបោះឆ្នោតនេះ យើងអាចយកតាមបញ្ជីបញ្ជាក់កំណើតបានដូចគ្នា កុំយកតាមអត្តសញ្ញាប័ណ្ណនៅតាមបញ្ជីបញ្ជាក់កំណើតឈ្មោះគាត់ប្រើ យ៉ាងម៉េច យើងធ្វើអញ្ចឹង ។

**លោក ឱក សេរី សោភក្តិ៍**

ខ្ញុំសូមបញ្ជាក់ផងដែរទៅបងៗដែលជាក្រុមប្រឹក្សាឃុំ នៅពេលដែលយើងចុះឈ្មោះគឺអាយុ១៨ឆ្នាំ ទៅទល់នឹងថ្ងៃ០១ខែមេសាឆ្នាំ២០០៧ ក៏យើងអាចយកមកឱ្យចុះបានដែរ ព្រោះគិតដល់ថ្ងៃ០១ ខែមេសាឆ្នាំ២០០៧ហ្នឹងបានចេញជាផ្លូវការមកហើយ ។

**លោកជា វណ្ណ** មេឃុំ ស្ទឹងត្រែង

ខ្ញុំសូមលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងការងារចុះឈ្មោះបោះឆ្នោត។ **ទី១** គឺការចុះឈ្មោះបោះឆ្នោតកន្លងមកខ្ញុំឃើញមានការលំបាកច្រើន ជាពិសេសការបញ្ជាក់ពីសាក្សីទទួល មេឃុំបានចេញលិខិតបោះត្រាជូនគាត់ ហើយគាត់មករកសាក្សី ដល់រកមិនបានគាត់ទៅផ្ទះវិញ ប៉ុន្តែខ្ញុំបាទមុននឹងចុះហត្ថលេខាបោះត្រាជូនគាត់ ខ្ញុំជឿជាក់ថាគាត់ជាប្រជាជននៅឃុំហ្នឹងហើយ អញ្ចឹងការលំបាករបស់គាត់គឺត្រូវត្រឡប់ទៅផ្ទះវិញអត់បានចុះឈ្មោះ អញ្ចឹងបាត់យ៉ាងច្រើន ។ **ទី២** បញ្ហាបញ្ជីប៉ោងក្នុងបញ្ជីចុះឈ្មោះបោះឆ្នោត កន្លងមកខ្ញុំឃើញលំបាកសំរាប់ឃុំខ្ញុំណាស់ ព្រោះអីខាង គជប ចង់ឱ្យបញ្ជាក់ទៅលុះត្រាតែមានមរណៈលិខិតដែលមិនត្រឹមត្រូវ ប៉ុន្តែឃុំខ្ញុំ បានចារឱ្យគាត់ថាផ្លាស់ទីលំនៅបាត់ហើយ ទៅរកគាត់មកផ្តិតមេដៃជាការលំបាក ហើយខ្លះទៀតស្លាប់ ដល់ស្លាប់ខ្លះទៀតអត់ធ្វើលិខិតប្តឹងផ្តល់ អញ្ចឹង

ដល់ពេលទៅឱ្យខ្ញុំរកគាត់ជាការលំបាកណាស់។ ខ្ញុំទទួលស្គាល់គាត់ស្លាប់ពិតប្រាកដណាស់បានហ៊ានធ្វើ ដល់អញ្ចឹងទៅបញ្ហាបញ្ជីប៉ោង ឃុំខ្ញុំប៉ោងច្រើនណាស់ បញ្ហាផ្លាស់ទីលំនៅនិងអ្នកស្លាប់នេះ ជាបញ្ហាលំបាករបស់ឃុំខ្ញុំ ក្នុងបញ្ជីដែលពាក់ព័ន្ធនិងការស្លាប់រស់។

ពាក់ព័ន្ធនឹងយន្តការបង្ការទំនាស់និងបោះឆ្នោត កន្លងមកការបោះឆ្នោតមានការលំបាក និងការយុទ្ធនាការក្នុងការឃោសនាបោះឆ្នោតក៏មានការលំបាក ដូចជាយើងបានកំនត់ពេលវេលាសំរាប់គណបក្សនីមួយៗ ឧទាហរណ៍ ក្នុងមួយថ្ងៃ៣ពេល យើងបានកំនត់ដាក់តងអស់ហើយ ប៉ុន្តែពេលឃោសនាគណបក្ស(ក)ទៅ គណបក្ស(ខ)បានឆ្លៀតចូល ទៅជាមួយក្នុងហ្នឹង អញ្ចឹងធ្វើកម្មវិធីហ្នឹងស្មុគ្រស្មាញឡើងវិញ ជួន កាលទៅផ្លូវតែមួយអាចមានជំលោះដាក់គ្នាបាន ។ នេះជាសំនូមពរសុំឱ្យមានពេលច្បាស់លាស់ចែកពេលនិងកម្មវិធីឱ្យដាច់គ្នា។ បញ្ហាមួយទៀតគឺការឃោសនា ព្រោះច្បាប់មានហើយថា ហាមការឃោសនាមិនឱ្យជេរ្យមដាមគ្នា ប៉ុន្តែកន្លងមកឃើញថាមានបញ្ហារហូត ។ បញ្ហាមួយទៀតពាក់ព័ន្ធនឹងការងារដែលយើងធ្វើនេះ គឺការបោះឆ្នោត ខ្មែរយើងទើបនឹងរៀបចំការបោះឆ្នោតបានពីរបីលើកទេ ប៉ុន្តែយើងគិតរហូតការបោះឆ្នោតដល់សព្វថ្ងៃនេះរលូនយ៉ាងល្អ ប៉ុន្តែអ្វីដែលខុសតិចៗនេះ វាមានមិនអាចធ្វើម្តងបានស្អាតតែម្តងនោះទេ ប៉ុន្តែខ្ញុំទទួលស្គាល់ថា យើងរៀបចំបានយ៉ាងល្អបំផុតក្នុងការងារ ឧទាហរណ៍ ការគ្រប់គ្រងមនុស្សពិបាកណាស់មិនមែនងាយស្រួលទេ សូម្បីតែក្នុងគ្រួសារក៏ពិបាកដែរ ទំរាំយើងគ្រប់គ្រងមនុស្សទាំងមូល ។

**លោកស្រី កង សាវ៉ន** ប្រធានការិយាល័យរដ្ឋបាល នៃសាលាគរុកោសល្យភូមិភាគ

នាងខ្ញុំសូមគោរពអង្គប្រជុំ និងអស់លោក លោកស្រី ដែលមានវត្តមាននៅទីនេះ នាងខ្ញុំមានសំនូមពរ ក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ ចំពោះគរុសិស្ស ខ្លះនៅមណ្ឌលគីរី ខ្លះនៅរតនៈគីរី ឯខ្លះទៀតពីខេត្តមណ្ឌលគីរី ទៅទីតាំងដែលខ្លួនត្រូវបោះឆ្នោត ៧០គីឡូ ហើយការបោះឆ្នោតក្រុមប្រឹក្សាឃុំ ទាមទារឱ្យទៅបោះអ្នកណានៅកន្លែងណា ឱ្យទៅបោះនៅកន្លែងហ្នឹង ។ ដូច្នេះគរុសិស្សខ្ញុំទី១សុំច្បាប់ទៅចុះឈ្មោះអស់៣ឬ៤ថ្ងៃ ហើយនៅពេលបោះឆ្នោតទៀត ត្រូវអស់១សប្តាហ៍ទៀត ហើយមធ្យោបាយធ្វើដំណើរទៅមណ្ឌលគីរី ម្នាក់ត្រូវចំណាយប្រហែល២០ម៉ឺន អញ្ចឹងនាងខ្ញុំសំនូមពរថា គរុសិស្សនាងខ្ញុំ ដែលមករៀននៅក្នុងខេត្តស្ទឹងត្រែងនេះ សូមឱ្យបានបោះឆ្នោតនៅក្នុងខេត្តស្ទឹងត្រែងនេះ សំរាប់ជ្រើសរើសក្រុមប្រឹក្សាឃុំ។

**លោក ឱក សេរី សោភក្តិ**

ខ្ញុំសូមអរគុណបងស្រី សាវ៉ន ជាពិសេស ដោយសារតែបញ្ហានេះទាក់ទងសិស្សដែលរៀនចំណាកស្រុក ហើយទាក់ទងនឹងក្មួយស្រីៗយើង ដែលមានចំនួន២៥ម៉ឺននាក់នោះ ដែលគាត់ចំណាកស្រុកទៅធ្វើការនៅរោងចក្រមានបញ្ហាដូចគ្នា ការដែលសុំច្បាប់ពិបាកថៅកែមិនឱ្យមកធ្វើការ ហើយធ្វើដំណើរអស់លុយកាក់ រួមទាំងការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះ និងពេលបោះឆ្នោតក៏ពិបាក។ ខ្ញុំបានលើកសំណើទៅខាង គជប ចំពោះបញ្ជីឈ្មោះករណីអ្នកបោះឆ្នោតពិសេសៗហ្នឹង តើយើងអាចធ្វើការកែប្រែបានខ្លះឬទេទៅតាមនីតិវិធី? ឱ្យគាត់បោះនៅកន្លែងណាដែលគាត់រស់នៅ កុំឱ្យគាត់ពិបាកចាយសាហ៊ុយ ចាយវាយពេលវេលាសុំច្បាប់អ្នកដែលរៀន និងអ្នកធ្វើការ។ យើងកំពុងតែសិក្សានៅក្នុងរឿងហ្នឹង មិនដឹងធ្វើការបានប៉ុន្មានទេ ? ហើយនៅក្នុងកន្លែងនេះ បងប្រធាន PEC ក៏លោកនៅទីនេះដែរ បញ្ហាដែលបងស្រី សុវណ្ណ លើកឡើងនេះជាបញ្ហាជាក់ស្តែងណាស់ ហើយទាក់ទងទៅនិងមនុស្សរាប់សែននាក់ ដូច្នេះយើងនឹងពិភាក្សា រឿងនេះឱ្យបានច្បាស់ជាមួយអ្នកពាក់ព័ន្ធ។

**លោក ថា ផាន់** ជំទប់ទី២ឃុំស្រះឫស្សីមកពីគណបក្សសមរង្ស៊ី

ខ្ញុំបាទសូមសំនូមពរដល់អង្គការធ្វើយ៉ាងណាក្នុងការបោះឆ្នោត ចុះឈ្មោះបោះឆ្នោត ក្នុងការផ្សព្វផ្សាយឃោសនាក្តី សូមឱ្យជៀសផុតមួយរដូវវស្សា ព្រោះរដូវវស្សាប្រជាជនកម្ពុជាភាគច្រើន ប្រកបរបរកសិករ ដូច្នេះលោកនៅឆ្ងាយៗពីកន្លែងចុះឈ្មោះ

បោះឆ្នោតនៅស្រែចំការ មិនដែលនៅទីក្រុងទេ ដូច្នេះមិនដឹងជាអូរ មិនដឹងជាស្ទឹង ទឹកលិចទៀត គាត់ខ្ជិលទៅ ដូច្នេះគាត់នឹកឃើញថាជាកាតព្វកិច្ចរបស់គាត់ដែរ ក៏ប៉ុន្តែវាមានឧបសគ្គមិនដឹងធ្វើម៉េច ។

**លោក ឱក សេរីសោភ័ក្តិ**

នៅមណ្ឌលគីរី និងកំពង់សោមលើកដូចគ្នា ព្រោះជាកន្លែងដែលទាក់ទងទៅនឹងរឿងភ្លៀង នៅមណ្ឌលគីរី ខែ៤ ខេត្តឯទៀត១ គេរាំងមណ្ឌលគីរីភ្លៀង នៅកំពង់សោមភ្លៀងខែ៧នៅកន្លែងឯទៀត១រាំង ដូច្នេះមិនដឹងថា តើជ្រើសរើសថ្ងៃបោះឆ្នោតណាឱ្យត្រូវទាំង ២៤ខេត្តក្រុង។ ប៉ុន្តែការលើកជាសំណើខ្ញុំអរគុណបងណាស់ ព្រោះជាការជាក់ស្តែងនៅតាមមូលដ្ឋានយើងត្រូវតែលើក ពិបាកអញ្ចឹងមែន។ យើងសូមជំរាបផងដែរក្រោយពីខប់សែលប្រ៉ែមម្តង១ យើងមានការជួបប្រជុំ ជាមួយ NEC ជាមួយគណបក្សនយោបាយនៅថ្នាក់ជាតិហើយយើងរាយការណ៍ជូនទាំងអស់ អ្វីដែលជាមតិ បងស្រី បងប្រុស លើកឡើងនៅក្នុងប្រជុំនៅក្នុងខេត្តហ្នឹង ដូច្នេះអ្នកខាងនោះក៏បានស្តាប់ ហើយនៅខេត្តឯទៀត១ក៏យើងលើកឆ្លងគ្នាទៅវិញទៅមកដែរ ដើម្បីឱ្យខេត្តនីមួយ១បានស្គាល់ស្ថានការណ៍ខេត្តផ្សេង១ទៀតទាំងអស់គ្នា ។

**លោក តែន ថន** តំណាងឱ្យគណបក្សសមរង្ស៊ីខេត្តស្ទឹងត្រែង

ជាបឋម ខ្ញុំសូមគោរព លោក ឡារី ស្ត្រេន្ទ ជានាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លោកឱកសេរីសោភ័ក្តិ ជាទីប្រឹក្សានិងជាអ្នកសម្របសម្រួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI និងសូមគោរព សហការីសូមគោរព លោកពុយចាន់ថាឡាក់ ប្រធានលេខាធិកាដ្ឋានរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង ព្រមទាំងអស់លោក លោកស្រីទាំងអស់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំខប់សែលថ្ងៃនេះ។ នៅក្នុងបញ្ហាពាក់ព័ន្ធនឹងទំនាស់នៅក្នុងការបោះឆ្នោតនេះមានច្រើន ប៉ុន្តែគ្រាន់ថាការយោគយល់ចេះដោះស្រាយនោះយើងធ្វើបានល្អណាស់នៅក្នុងខេត្តស្ទឹងត្រែង ហើយបញ្ហាដែលទំនាស់នេះគឺមិនជាធំដុំអ្វីទេ ។ ខ្ញុំតំណាងឱ្យគណបក្សសមរង្ស៊ី សុំសំនូមពរមកខាងគណៈកម្មាធិការបោះឆ្នោត ដូចជាការចុះឈ្មោះបោះឆ្នោតក្នុងរយៈពេលតែ២០ថ្ងៃទេ សុំឱ្យគណៈកម្មារៀបចំការបោះឆ្នោតសហការណ៍ជាមួយអាជ្ញាធរដែនដី ដូចជាខាងឃុំធ្វើយ៉ាងណាជួយផ្សព្វ ផ្សាយព័ត៌មាននេះឱ្យបានជ្រួតជ្រាបដល់ស្រទាប់ប្រជាពលរដ្ឋនៅតាមជនបទ តំបន់ដាច់ស្រយាល ព្រោះកន្លងមកខ្ញុំបានសង្កេតមើលនៅគ្រប់ស្រុក គ្រប់ឃុំទាំងអស់ការផ្តល់ព័ត៌មានទៅឱ្យអ្នកបោះឆ្នោតនោះគឺបានតែនៅទីប្រជុំជនទេ។ ឧទាហរណ៍ នៅក្នុងខេត្តស្ទឹងត្រែងអញ្ចឹង នៅទីរួមស្រុក នៅទីរួមខេត្តតែម្តង ឃើញមានការចងបដារឬមានការឃោសនាតាមឃោសនៈស័ព្ទ ។

ការងារបោះឆ្នោតនេះ គឺចុះឈ្មោះរយៈពេល២០ថ្ងៃ ដូច្នេះសូមឱ្យគណៈកម្មាធិការរៀបចំការបោះឆ្នោតនេះ ធ្វើយ៉ាងណាឱ្យការផ្សព្វផ្សាយបានលឿនបន្តិច ព្រោះការបោះឆ្នោតកន្លងមក ឧទាហរណ៍ជាក់ស្តែង បើសិនជាចុះឈ្មោះថ្ងៃ០១ ទាល់តែមកដល់ថ្ងៃ០២ ឬថ្ងៃ០៣អី បានចាប់ផ្តើមផ្សាយព័ត៌មាន ហេតុដូច្នេះហើយបានមានការយឺតយ៉ាវ យើងចុះឈ្មោះមានរយៈពេលតិចផង ហើយយើងផ្សព្វផ្សាយយឺតទៀតធ្វើឱ្យការងារបោះឆ្នោត គឺថាប្រជាពលរដ្ឋមិនបានមកចូលរួមបោះឆ្នោតច្រើន កាលណាជ្រើសរើសអ្នកដឹកនាំបានប្រជាពលរដ្ឋភាគច្រើនចូលរួមគឺជ្រើសរើសបានល្អ ព្រោះគំនិតច្រើន។ បញ្ហាមួយទៀតនៅពេលឃោសនាខ្ញុំសង្កេត ឃើញថាខាងកំលាំងខាងសមត្ថកិច្ចដូចជាខាងនគរបាល ខ្ញុំសូមកោតសរសើរ រយៈពេលបោះឆ្នោតឃុំឆ្នាំទៅនិងបោះឆ្នោតព្រឹទ្ធសភានេះ ឃើញថាខាងកំលាំងនគរបាលគាត់បានធ្វើការងាររបស់គាត់បានល្អណាស់ ការបោះឆ្នោតឃុំនោះ គាត់បានទៅតាមការពារការដង្ហែរក្បួនរបស់គណបក្សនយោបាយ ។

ខ្ញុំសូមសំនូមពរបន្តទៅទៀតដែរថា នៅក្នុងថ្ងៃបោះឆ្នោត សុំឱ្យអាជ្ញាធរដែនដីទាំងអស់តាំងខ្លួនគាត់ថាជាប្រជាពលរដ្ឋម្នាក់ទេ ព្រោះគាត់ទៅចូលរួមបោះឆ្នោត ក៏ប៉ុន្តែពេលដែលគាត់ចូលរួមបោះឆ្នោត ហើយគាត់អញ្ជើញត្រឡប់ទៅផ្ទះវិញមិនមានបញ្ហាទេ ប៉ុន្តែ មុននឹងចូលទៅបោះឆ្នោតគាត់មានការជជែកឬក៏សួរសុខទុក្ខប្រជាពលរដ្ឋដែលមកចូលរួម ទោះបីថាគាត់មានសិទ្ធិសួរសុខទុក្ខមែន ប៉ុន្តែ គ្រាន់តែបើយើងនិយាយក្នុងផ្លូវនយោបាយ គឺមានការគៀបសង្កត់មួយទៅលើគាត់ដែរ គឺថាគាត់មេស្រុក ឬចៅហ្វាយស្រុក មកចូលរួម បោះឆ្នោតដែលគាត់ថាមេភូមិក៏មកចូលរួមបោះឆ្នោតដែរ អញ្ចឹងគាត់មានការភ័យខ្លាច អញ្ចឹងសូមថាអាជ្ញាធរដែនដី ដូចជា ភូមិ ស្រុក ខេត្តធ្វើយ៉ាងណាក្រោយពេលដែលគាត់បំពេញភារៈកិច្ច ជាប្រជាពលរដ្ឋចូលរួមការបោះឆ្នោតរួចហើយ សុំឱ្យគាត់កុំនៅជិតជំនុំជាមួយ ប្រជាពលរដ្ឋអី ព្រោះខ្ញុំជឿថាការសួរសុខទុក្ខ មិនមានពេលវេលាតែមួយថ្ងៃហ្នឹងទេ។ បញ្ហាមួយទៀតនោះ ខ្ញុំសំនូមពរថា រាល់ការ ផ្សព្វផ្សាយឱ្យដល់ប្រជាពលរដ្ឋឱ្យគាត់មកចូលរួមបោះឆ្នោត ខ្ញុំលើកឡើងវិញគឺសង្កត់ធ្ងន់លើគណៈកម្មាធិការរៀបចំការបោះឆ្នោតនៅ តាមថ្នាក់មូលដ្ឋាន គណបក្សសមរង្ស៊ី អត់មានមន្ត្រីណានៅថ្នាក់ឃុំ ថ្នាក់ភូមិ ថ្នាក់ស្រុកអីទេ ដូច្នេះការទៅជំរាបប្រជាពលរដ្ឋឱ្យគាត់ ទៅចូលរួមបោះឆ្នោតមានតែខាងគណបក្សប្រជាជនមួយទេដែលមាន ថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ដូច្នេះហើយគាត់មានប្រៀបច្រើន មកលើគណបក្ស សមរង្ស៊ី។ ខ្ញុំសំនូមពរថាធ្វើយ៉ាងណាសុំឱ្យអាជ្ញាធរដែនដី ដែលគាត់មានប្រភពចេញមកពីគណបក្សនយោបាយរបស់ ខ្លួនក៏ដោយ ក៏ប៉ុន្តែក្នុងនាមគាត់បំពេញសមត្ថកិច្ចជាអាជ្ញាធរដែនដី សុំឱ្យមានតុល្យភាពគ្នា ប្រជាពលរដ្ឋទាំងអស់សុទ្ធតែជាកូនចៅ របស់គាត់ អត់មានបែងចែកថាជាកូនចៅបក្សណាៗទេ ដើម្បីឱ្យដំណើរការបោះឆ្នោតលើកក្រោយនេះកាត់បន្ថយនូវទំនាស់។ ក្នុងនាមគណបក្សសមរង្ស៊ី ខ្ញុំក៏សុំសំនូមពរខាងខប់សែល ធ្វើយ៉ាងណាដើម្បីកុំឱ្យមានទំនាស់ច្រើន ជួយអន្តរាគមន៍បើសិនជា គណៈកម្មាធិការៀបចំការបោះឆ្នោតរៀបចំឡើងនូវអាណត្តិបោះឆ្នោតឃុំឆ្នាំ២០០៧ ក៏ដូចជា២០០៨នេះ ធ្វើយ៉ាងណាគណៈកម្មាធិកា រៀបចំការបោះឆ្នោតនេះ សុំឱ្យមានតំណាងគណបក្សសមរង្ស៊ីចូលរួមផង ព្រោះខ្ញុំគិតថាសព្វថ្ងៃនេះគណៈកម្មាធិការៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ទាំងអស់ ភាគច្រើនសុទ្ធតែជាសមាជិកគណបក្សប្រជាជន ។ ដូច្នេះសំនូមពរថាបើសិនជាគណៈកម្មាធិការបោះឆ្នោត ជ្រើសរើសដោយមានគណបក្សនយោបាយផ្សេងៗចូលរួម ខ្ញុំជឿថាប្រាកដជាសុក្រឹត្យជាងនេះ។ ហើយជាចុងបញ្ចប់នេះ ខ្ញុំសូមថ្លែង អំណរគុណដល់យន្តការខប់សែល ដែលបានយកចិត្តទុកដាក់ផ្តល់ថវិការឧបត្ថមធ្វើយ៉ាងណាដោះស្រាយ បញ្ហាវិវាទរវាងគណបក្ស នយោបាយនិងគណបក្សនយោបាយក្នុងការបោះឆ្នោត ហើយសង្ឃឹមថាយន្តការខប់សែល នឹងនៅតែបន្តជួយដល់ការដោះស្រាយបញ្ហា នេះបន្តទៅមុខទៀត។

**លោក ឱក សេរី សោភ័ក្តិ**

ខ្ញុំសូមសំដែងនូវការរំភើបដែលបានអង្គុយស្តាប់លោកអ៊ំ ខាងតំណាងគណបក្សហ៊្វុនស៊ិនប៉ិច អស់លោកខាងតំណាងគណបក្ស សមរង្ស៊ី ហើយនិងបងប្រុសអប្បាញ់មិញ តំណាងគណបក្សប្រជាជន ។ កាលដែលបានស្តាប់សំដីប្រកបដោយមានអត្ថន័យ ហើយគួរ សមជាមួយគ្នាទៅវិញទៅមក ពេលដែលយើងលើកប្រធានបទដែលលំបាកយើងតោងទទួលស្គាល់ប្រធានបទ ដែលយើងលើកឡើង សុទ្ធតែលំបាកប៉ុន្តែយើងនៅតែរក្សាសភាពគួរសម សភាពថ្លៃថ្នូរបាន ដូច្នេះគ្មានអ្វីដែលធ្វើឱ្យយើងបាត់ឡើយហាត់បំភ្លេចការដែលខំ ប្រឹងប្រែងជាជាងពាក្យសំដីអស់ នេះជាជាងអាកប្បកិរិយាថ្លៃថ្នូរទាំងអស់នេះទេ ហើយខ្ញុំបាទជឿថាបានតែប៉ុណ្ណេះគឺអស់ចិត្តហើយ គឺមានមោទនភាពណាស់។ ខ្ញុំបាទជឿថាកាលពីប៉ុន្មានឆ្នាំមុនពីតំបូង ដែលខប់សែលមានពាក្យដែលយើងនិយាយថ្ងៃនេះជូនកាលយើង និយាយអត់បានទេពេលហ្នឹង គឺថាសង្រ្គែតធ្មេញដាក់គ្នាទឹកមុខចងចិញ្ចើមដាក់គ្នា ដល់ឥឡូវយើងនិយាយបានដោយញញឹម ខ្ញុំបាទគិតថា គ្មានអ្វីថ្លៃថ្លាជាងការ បានស្តាប់បានសង្កេតឃើញទិដ្ឋភាពបែបនេះទេ លោក ឡារី ស្រ្តេន លោកមានទំនាក់ទំនងច្រើនណាស់ លោកក៏

មានការសប្បាយចិត្ត ដូចខ្ញុំដែរនៅក្នុងរឿងទាំងអស់នេះ។ សូមជំរាបផងដែរថាបងមួយដែលគាត់ថតហ្វីលអំបាញ់មិញហ្នឹង គឺយើងនឹងយកទៅបញ្ចាំងផ្សាយនៅតាមទូរទស្សន៍ CTN យើងនឹងធ្វើជា CD នូវអង្គប្រជុំទាំងប៉ុន្មាន ដើម្បីចែកជូនទៅស្ថានទូត គ្រប់អង្គការនានាទាំងអស់ ដើម្បីឱ្យឃើញថាអាកប្បកិរិយាប្រជាពលរដ្ឋខ្មែរអ្នកដឹកនាំខ្មែរ ទាំងថ្នាក់ជាតិ ទាំងថ្នាក់មូលដ្ឋាន គឺថាកំពុងតែកែប្រែវប្បធមិនៅក្នុងសង្គមរបស់ខ្លួនគ្រប់ជាន់ថ្នាក់ទាំងអស់ឱ្យក្លាយទៅជាវប្បធមិសន្តិភាព ។ ដូច្នេះហើយសូមកុំឱ្យឆ្ងល់ពេលដែលឃើញគាត់ថតកាំមារ៉ាគឺយើងយកទៅផ្សព្វផ្សាយអញ្ចឹង ដើម្បីលើកតំកើនវប្បធមិសន្តិភាពនៅក្នុងសង្គមយើងឱ្យតំបន់និងសកលលោក មើលឃើញនូវការប្តូររូបភាពដែលធ្លាប់មានពីមុនមក។

**លោក ពុយ ចាន់ថាឡាក់**

យើងបានកត់សំគាល់ឃើញថា អ្វីដែលបានបង្ហាញលាតត្រដាងក្នុងអង្គប្រជុំនេះគឺមានសុឆន្ទៈមួយច្បាស់លាស់ក្នុងគោលបំណងចង់ឱ្យការរៀបចំការបោះឆ្នោតបន្តទៅខាងមុខទៀត តាមរយៈការដកស្រង់បទពិសោធន៍នានាក្នុងអង្គប្រជុំនាពេលនេះ ដើម្បីឱ្យមានភាពល្អប្រសើរ។ ឆ្លៀតក្នុងពេលនេះខ្ញុំសូមឆ្លើយបន្ថែមខ្លះៗក្នុងករណីដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ គខប យើងខ្ញុំ។ ឆ្លើយតបទៅលើប្រសាសន៍របស់លោកពុយចាន់ថាឡា ក្នុងនោះ **ទី១** អំពីពាក្យបណ្តឹងផ្សេងៗជាហូរហែរមកយើងឃើញថាបណ្តឹងរបស់គ្រប់គណបក្សនយោបាយទាំងអស់យើងមានមន្ត្រីជំនាញទទួលខុសត្រូវរបស់ PEC គឺយើងមានផ្នែកសេវាកម្មច្បាប់ ដែលជាច្រកទ្វាចូលយ៉ាងសំខាន់ដើម្បីទទួលពាក្យបណ្តឹងនានាមុននឹងចូលមកដល់ការសំរេចរបស់ប្រធាន PEC អញ្ចឹងគេបានបោះត្រាមួយនៅក្នុងពាក្យដែលដាក់ចូលមកហើយជាបន្តបន្ទាប់គេបង្ហាញរូបរាងជាហូរហែរមក ហើយដូច្នេះយើងពិនិត្យលើស្ថានភាពច្បាប់និងគោលការណ៍នៃការអនុវត្តដោះស្រាយពាក្យបណ្តឹងតាមនីតិវិធីរបស់យើង។ អញ្ចឹងឃើញថាជាហូរហែរគឺប្រសាសន៍ដែលគាត់លើក មានកន្លែងខ្លះសមស្រប កន្លែងខ្លះយើងខ្ញុំក៏ច្រានចោលទៅវិញផងដែរ ។ អញ្ចឹងករណីខ្លះបណ្តឹងដែលយើងឆ្លងកាត់នូវវង្វង់សមត្ថកិច្ចនៃការប្រជុំ ដែលយើងដោះស្រាយមិនបានតាមរយៈការប្រជុំមានបណ្តឹងរបស់គណបក្សសមរង្ស៊ី បានធ្លាយចូលទៅដល់ គជប ផងដែរ។ ករណីបណ្តឹងដែលទាក់ទងនិងការរាប់សន្លឹកឆ្នោតប្រហែលជា ក្រុមប្រឹក្សាឃុំ តាំងពីឆ្នាំ២០០១ឆ្នាំ២០០២ នោះ ករណីទាក់ទងនឹងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យឃុំសំអាង និងឃុំស្រះឬស្សី ស្រុកបាឡាវ៉ាក់ យើងឃើញថាក្នុងលក្ខខ័ណ្ឌខ្លះ ដែលនៅច្បាប់យើងពិនិត្យទៅឃើញថា យើងត្រូវយកច្បាប់ជាធំ ហើយនីតិវិធីឬក៏រូបមន្តនានាដែលយើងត្រូវគិត អញ្ចឹងអ្វីដែលយើងមិនអាចសម្របសម្រួលថាអាចរាប់សន្លឹកឆ្នោតឡើងវិញបាន ដូចនៅក្នុងករណីឃុំ សំអាងនិងឃុំស្រះឬស្សី ស្រុកថាឡាបរិវ៉ាក់ ករណីយើងយករូបមន្តមួយលំអៀង០,០៥%មកអនុវត្តដូចនេះនៅពេលយើងចារបដិសេធ មិនដឹងថាសាម៉ីខ្លួនក្នុងដើមបណ្តឹងអាចមានសិទ្ធិបន្តពាក្យបណ្តឹងទៅដល់ គជប។

ខ្ញុំបានហត្ថលេខាទៅ លោក សាន់ប៊ុនធឿន ទៀតដើម្បីឱ្យគាត់ ហើយជំរាបគាត់ជាប្រញាប់ថាជិះអូប័រអីក៏ដោយ ក៏ត្រូវឱ្យទាន់ម៉ោង៥រសៀលនៅល្ងាចនេះ ដើម្បីឱ្យដល់ គជប ដើម្បីឱ្យគេមានសមត្ថកិច្ចក្នុងរង្វង់ថាកុំឱ្យផុតពេលវេលា ដើម្បីការងារតនេះគាត់បានទៅទាន់មែន អញ្ចឹងការដោះស្រាយសមត្ថកិច្ច ខាងលើខ្ញុំអត់បានដឹងទេការសំរេចរបស់គាត់យ៉ាងម៉េចទេ ប៉ុន្តែខ្ញុំបង្ហាញអំពីសុឆន្ទៈរបស់គណៈកម្មាធិការបោះឆ្នោត គឺជារួមអត់មានគំនិតបន្ទុកបង្អាក់អីទេ គ្រាន់តែថាកន្លែងខ្លះយើងមានសិទ្ធិចារតែនីតិវិធីរបស់យើងថាកម្មវត្ថុនៃបណ្តឹងមិនអាចបាន តាមអ្វីដែលត្រឹមត្រូវអ្វីដែលយើងមិនអាចបានយើងចារបដិសេធ តែអ្វីដែលសំខាន់នោះ គឺដើមបណ្តឹងអាចយកពាក្យប្តឹងនោះបន្តតទៅមុខទៀត ។ ដូចខេត្តបន្ទាយមានជ័យអញ្ចឹង គឺដូចព្យុះរឿងពាក្យបណ្តឹងពេលខ្លះខាងនោះប្តឹងនៅ គជប ក៏មានដែរមេគណបក្សធំ របស់គណបក្សសមរង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនក្តី មេធំអាចប្តឹងនៅទីនោះផ្ទាល់

ត្រង់ថាឆ្លងកាត់អ្វីជាសមត្ថកិច្ចរបស់គេទេទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញ នេះជាហេតុផលមួយដែលខ្ញុំជំរាបជូន បើថាចោទប្រកាន់យើងខ្ញុំទាំងស្រុងថាយើងខ្ញុំជាអ្នកបន្ទុកបង្អាក់យើងខ្ញុំអត់ទទួលយកបានទេ។

កន្លងមកថ្មីៗគណបក្សហ៊្វុនស៊ិនប៉ិចលោក កែ សុវណ្ណមុន្នី ជាមួយលោក តែន ថន ដែលយើងប្រជុំមួយ យើងបានថាបើអស់លោកត្រូវការបណ្តឹងអំពីករណីណាមួយ យើងនឹងចារឱ្យទៅប្តឹងនៅ គជប តែលោក តែន ថន គាត់ អត់បានបន្តទេ តែលោក កែ សុវណ្ណមុន្នី បានបន្តទៅទៀត យើងចារឱ្យគាត់នេះជាសុឆន្ទៈមួយដែលយើងចង់បង្ហាញឱ្យឃើញថាអ្វីដែលយើងដោះស្រាយខុសរង្វង់សមត្ថកិច្ចរបស់យើង គខប ធ្វើតាមនីតិវិធីរបស់យើង។ ខ្ញុំបញ្ចប់ភ្ជាប់មកជាមួយការិយាល័យមួយដែលពាក់ព័ន្ធភាពរការកូសខ្លះ ដូចជានៅករណី ម៉ែ សារ៉ូ នេះជាចំនុចដ៏គ្រោះថ្នាក់មួយសំរាប់ PEC នៅខេត្តស្ទឹងត្រែង ប៉ុន្តែអ្វីដែល PEC នៅខេត្តស្ទឹងត្រែងបានរៀបចំស្ថានភាពមួយដើម្បីជំរាបដល់អង្គការ NGO សំខាន់ៗនៅយប់បោះឆ្នោតតែម្តង អ្នកខ្លះអត់បានដឹងទេ ព្រោះការងារនេះមិនបានផ្សព្វផ្សាយ។ អង្គការ EU សហគមន៍អឺរ៉ុប និងអង្គការមួយចំនួន បានចូលជួបខ្ញុំទាំងយប់ ដើម្បីឱ្យយើងខ្ញុំ ស្រាយបំភ្លឺករណី ម៉ែ សារ៉ូ នេះ ដូច្នេះយើងបានមានភស្តុតាងហេតុផលជាច្រើនដើម្បីបង្ហាញ ម៉ែសារ៉ូ នេះឯកសាររបស់គាត់មាន រូបថត តែត្រាក្រហមរបស់គាត់មានដូចកងច្រវ៉ាក់ ទោះបីយើងសុំទោសជាមួយ EU មានការថតរបស់គាត់ទៀតថាយើងសេរេត្រា ក្រហមវៃលើឈ្មោះហ្នឹង សើរើចុះឡើង គឺថាអត់មានចំណ្ណាទេ នេះជាឯកសារដើមនៅលើក្រដាស ហ្នឹងរូបមិនមែនជារូបម៉ែសារ៉ូតែម្តង គឺអាចបកររូបថតពីណាមួយមកបិទតែម្តង នីតិរបស់ខ្ញុំមិនអាចទទួលបានទេ រឿងនេះជារឿងមួយដែលខ្ញុំបានជំរាបគាត់ ដល់គាត់ពិនិត្យមើលជាមួយយើងខ្ញុំគាត់អស់ចិត្តដែរ ក៏ប៉ុន្តែបើគណបក្សហ្នឹងមានការមិនអស់ចិត្ត គាត់អាចប្តឹងតទៅទៀតទោះបីក្រោយក៏ដោយ ដូចនៅព្រៃវែងអញ្ចឹងមាន២ការិយាល័យ។ ការិយាល័យ១ បោះរួចទៅហើយតែមានករណីមានបណ្តឹងបែបនេះគេអាចបោះឆ្នោត ឡើងវិញបាននេះជានីតិវិធីរបស់យើងបើសិនជាការងារមួយនេះ មន្ត្រីបោះឆ្នោតធ្វើ អ្នកណាមួយក៏ដោយធ្វើដោយអំពើអយុត្តិធម៌ ឬដោយរំលោភលើផ្លូវច្បាប់ ឬលំអៀងផ្សេងៗយើងមានសិទ្ធិអាចធ្វើការរាប់ឡើងវិញ។ ដូចករណីនៅខេត្តបន្ទាយមានជ័យ បើសិនត្រាដល់ទៅ២ ខ្ញុំមិនដឹងខុសលើមេឃុំ ដែលគាត់បោះខ្លួនគាត់ខ្ញុំមិនដឹងទេ ព្រោះមានត្រាក្រហមដែរ ទោះបីខ្ញុំយ៉ាងណាក៏ដោយ ឈ្មោះ ម៉ែសារ៉ូ មិនអាចមានត្រាតែមួយគត់ជាន់លើរូបថតគាត់បានទេ។ នេះជាការពិតដល់ថ្នាក់សហភាពអឺរ៉ុបបានមកជាមួយអង្គការអឺមក គេលើកពីគណបក្សហើយយើងឃើញថាគាត់បានពិនិត្យមើលឃើញថាគាត់អស់ចិត្តថាឯកសារហ្នឹងអាចក្លែងក្លាយ អាចមិនមែនជាឯកសារដើមទេ អញ្ចឹងអ្វីដែលយើងមិនបានឱ្យគាត់បោះគឺគាត់អត់មានថាយើងខុសទេ ព្រោះផ្លូវច្បាប់គេអាចបញ្ជាក់អញ្ចឹង ប៉ុន្តែគួរឱ្យសោកស្តាយផងដែរ នៅការិយាល័យលោក ម៉ែសារ៉ូ នៅថ្ងៃនោះ ប៉ុន្តែគួរតែយល់ថាសមត្ថកិច្ចបោះឆ្នោត មានការធ្វើសម្បទានច្រើនណាស់ បើសិនគ្មានការធ្វើសម្បទានទេនោះការសម្របសម្រួលនៅការិយាល័យនោះប្រហែលជាមិនទាន់អាចបោះបានទេ ព្រោះមាន មន្ត្រីថ្នាក់ខ្ពស់ ថាថ្នាក់ខេត្តដូចគណបក្ស សមរង្ស៊ី គឺថាដោយសាររឿងហ្នឹងគាត់មានចាត់មន្ត្រីរបស់គាត់ម្នាក់ ជាភ្នាក់ងាររបស់គណបក្ស សមរង្ស៊ី មានផ្លាកចូល ២នាក់ ៤នាក់ ចេញចូលក្រៃងយើងទុករង្វង់របស់សមត្ថកិច្ចរបស់តំណាងគណបក្សរបស់យើងទុកចិត្តបានឱ្យគេធ្វើការក្នុងហ្នឹង យើងខាងខេត្តយើងមិនបាច់ទៅរញ៉េរញ៉ៃចូលទៅខាងក្នុងអី បើផ្លូវច្បាប់គេឱ្យសន្តិសុខឃាត់សិន មិនអាចឱ្យរំខានគេបានទេ ប៉ុន្តែអ្វីៗដែលយើងធ្វើយ៉ាងណាៗនេះ គឺយើងមានការយោគយល់គ្នា ហើយគណបក្សនេះក៏អត់មានការប្តឹងផ្តល់អី តែបើគាត់ហ៊ានប្តឹង ក៏ជាសមត្ថកិច្ចរបស់ខ្ញុំ។

បើការិយាល័យខ្លះមានបញ្ហាខុសគ្នាតែ១សន្លឹក ក្នុងករណីតែម្នាក់ ឬក៏សរុបលទ្ធផលរបស់គណបក្ស ក.ខ ស្មើគ្នាហើយមួយសន្លឹកហ្នឹងមានបញ្ហា គេត្រូវតែរាប់ឡើងវិញហើយដោយសារម្នាក់ហ្នឹង បើគាត់នៅខាងសមរង្ស៊ី គឺសមរង្ស៊ីឈ្នះទៅ គាត់មិនមែន

គណបក្សប្រជាជន សន្លឹកឆ្នោតស្មើគ្នានេះករណីគេអាចធ្វើអញ្ចឹងបាន អញ្ចឹងផ្លូវច្បាប់ ខ្ញុំសូមឱ្យអស់លោកយោគយល់បញ្ហាទាំងអស់នេះយើងខ្ញុំគិតថា គឺគិតពីនាយមក ដើម្បីបុព្វហេតុរបស់ប្រជាជនយើងផងដែរ។ ចំនុចទី៣ ការច្របាច់បញ្ចូលគ្នាក្នុងមន្ត្រីបោះឆ្នោតជាគោលការណ៏របស់ គជប គេមិនគិតគណបក្សនយោបាយណាទេ ប៉ុន្តែគេគិតថាលក្ខណៈវិនិឆ្ឆ័យសំខាន់នៃការជ្រើសរើសគេចងយើងគឺត្រូវរើសអ្នកមានសមត្ថភាពខ្ពស់ឆ្លងកាត់បទពិសោធន៏ នៃការងារចាប់តាំងពី PSO តាំងពី CEC បន្តបន្ទាប់រហូតដល់ អាចក្លាយជា PEC បានមិនមែនថាដំឡូងមូលអាចចូលមកបានទេ ហើយបទពិសោធន៏នេះទៀត យើងតែងតែចងច្បាស់លាស់នៅរៀងរាល់បំណាច់ឆ្នាំដើម្បីបូកសរុបវាយតំលៃ ។

យើងវាយតំលៃថា ឈ្មោះ(ក) ឧបមាថាលោកស្រី មួង កង អញ្ចឹង CEC ផ្នែកអី ? យើងវាយតំលៃថាគាត់ A,B,C បើយើងវាយយើងគោរពល័ក្ខខ័ណ្ឌណាស់ យើងត្រូវឱ្យ គជប នៅភ្នំពេញដឹងទាំងអស់ អ្នកនោះមកធ្វើ ប្រាកដជា A គឺជាម្ចាស់ខ្សែក្រវ៉ាត់ ហើយការងារយើងទទួលស្គាល់។ ចំនុចមួយទៀត បើសិនជាការច្របាច់បញ្ចូលតាមសំនូមពរនេះ យើងខ្ញុំក៏ចង់បានដែរ ប៉ុន្តែយើងខ្ញុំមិនអាចធ្វើបានផ្ទាល់ទេ អញ្ចឹងត្រូវឆ្លងកាត់វិសោធនកម្មច្បាប់ ដើម្បីថាតើមន្ត្រីបោះឆ្នោតរៀបចំជាកូតាឬយ៉ាងម៉េច ? នេះជាបញ្ហាសំខាន់បើជាកូតាឱ្យដឹងថាជាកូតា បើដឹងថាជាល័ក្ខខ័ណ្ឌណាមួយ ក្នុងជំហរណាមួយត្រឹមត្រូវទាមទារយកបទពិសោធន៏។ ខ្ញុំទទួលស្គាល់ថាខ្ញុំជាមនុស្សដែលត្រឹមត្រូវដែរ ខ្ញុំធ្វើគ្រូកាលពីសង្គមខ្ញុំមិនមែនថាលើកគុណសម្បត្តិទេ ខ្ញុំស្អប់ខ្ពើមដូចគ្មានូវអំពើរអយុត្តិធមិ ខ្ញុំការពាររហូតសិស្សក្រីក្រ អ្នកក្រីក្រខ្ញុំតែងតែគិតទាំងអស់ ប៉ុន្តែយើងមិនចង់បានមនុស្សដែលរើសមកចាប់បង្រៀបកូតាបញ្ចូលគ្នាទាំងអ្នកនោះមិនដឹងស្អីផង ស្រាប់តែមកកាន់តំណែងមួយហើយស្រាប់តែមកធ្វើការងាររបស់យើងមានរយៈពេលខ្លីណាស់ មិនដូចចៅហ្វាយស្រុកចៅហ្វាយខេត្ត ធ្វើការមានអាណត្តិ៥ឆ្នាំទេ ការងារខ្លះធ្វើតែ៣ខែមានពេលខ្លះដូច PSO ធ្វើតែក្នុងទំរង់ប្រមាណ២០០ថ្ងៃការិយាល័យបោះឆ្នោតដូច្នេះយើងទាមទារមានបទពិសោធន៏ នេះជាគំនិតឆន្ទៈដែលខ្ញុំយល់តែបើសិនបើ អ្នកនោះក្រោយពីធ្វើការងារមកមានបញ្ហាប្តឹងផ្តល់របស់គណបក្សនយោបាយណាមួយ គាត់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

មួយទៀតយើងឃើញថារាល់សំណើដែលឡើងពី PEC ទៅមានឈ្មោះក,ខ,គឃើញថាទៅដល់លើយើងឃើញថា គជប ផ្ទាល់មិនមែនមានតែសមាជិកគណបក្សប្រជាជនមួយទេ ឬគណបក្សណាមួយទេ ព្រោះអាណត្តិមុនមានឯកឧត្តមកុយភុរឿង គណបក្សសមរង្ស៊ីនៅ គជប ទៀត គាត់អាចដឹងទេថា បើថាពណិសម្បុលយ៉ាងម៉េចគាត់អាចដឹងហើយ ពេលនោះគាត់ត្រូវការគាំទ្រ ត្រូវនិយាយដាក់អ្នកនេះ ដាក់អ្នកនោះខ្ញុំមិនដឹងទេ ក៏ប៉ុន្តែសុឆន្ទៈយើងចង់បានអ្នកជាម្ចាស់ភូមិ មូលដ្ឋាន ភូមិឃុំ របស់យើងឬក៏ខាងគណបក្សហ៊្វុនស៊ិនប៉ិច ក៏មាន រឿងហ្នឹងដែរ ឯកឧត្តមងៃសារៀង អញ្ចឹងរឿងអ្វីការសំរេចរបស់គាត់គឺគាត់សំរេចពីថ្នាក់ក្រោម ព្រោះមានមន្ត្រី គជប គេរើសគេឆ្លងកាត់ការប្រជុំច្រើន។

ចំនុចមួយទៀត ចំពោះការិយាល័យពាក់ព័ន្ធជាផ្ទះរបស់អ្នកមានអំណាច ខ្ញុំសូមជំរាបផងដែរមិនមែនបកស្រាយ ដើម្បីល្អទេគ្រាន់តែថាជាជំម្រើសរបស់ PEC ចុងក្រោយ ក្រោយពីនៅសារ៉ាវ៉ាត់នេះ យើងឃើញហើយការិយាល័យអូតែលមួយនេះជាការិយាល័យលំបាកតាំងពីណាមកលោកផាន់យុទ្ធក៏ធ្លាប់នៅដែរ គឺផ្លាកគណបក្សប្រជាជនមួយ នៅជាប់និងសាលាឆទានយើងមិនអាចដាក់បានទេ។ សាលាឆទានជាសាលាដែលល្អដូចសាលារៀន ដែលត្រូវការចង់បានតែយើងមិនអាចដាក់បានទេ៥០ម៉ែត្រទៅម៉េចរួចយើងត្រូវជំរើសដោះដូរ តែបើយើងគិតថាយើងយកតែសាលាមួយទៀត សាលាបឋមសិក្សាអូតែលនៅក្រោយទួលឆ្លងកាត់ប្រឡាយទឹកមួយ នៅចន្លោះមានប្រឡាយទឹកមួយ នៅរដូវប្រាំមិនចោតទេអាចដើរឆ្លងវាលស្រែបាន តែបើរដូវវស្សា កន្លែងហ្នឹងគឺត្រូវជិះទូកឆ្លងហើយ ជាផ្លូវរបស់យើងមិនអាចសំឡឹងឃើញថា តើគួរយកកន្លែងណាបានល្អលើសហ្នឹងទេបើផ្ទះប្រជាជនជួនកាលកន្លែង

ខ្លះវាតូចដែរ ហើយមានរោងវីដេអូមួយទៀតរបស់លោកផាន់ភើន របស់គណបក្សសមរង្ស៊ី ចំនិងផ្លាកព្រោះនៅមុខរោងគាត់ចំផ្លាក់មួយនៅពីមុខដែរ អញ្ចឹងគឺថាជម្រើសយើងដាក់ផ្ទះហ្នឹង យើងក៏ឃើញថាយើងសូមទោសយើងដឹងថាផ្ទះហ្នឹងវាអញ្ចឹងដែរ ប៉ុន្តែយើងប្រគល់វិមជ្ឈការអំណាចនេះឱ្យទៅ CEC ធ្វើដើម្បីធ្វើការនៅទីនោះ CEC ធ្វើការជាមួយមេឃុំ ជាមួយជំទប់មានលោកផាន់ភិន លោកជំទប់ទី១ លោកជំទប់ទី២ គណបក្សទាំង២ទាំង៣នៅជាមួយគ្នា ហើយជម្រើសចុងក្រោយគឺអញ្ចឹង។ ខ្ញុំដាក់កន្លែងហ្នឹងមានម្លប់ឈើជ្រក ហើយយើងក៏បានឱ្យមន្ត្រីយើងអ្នកកាន់ច្បាប់២នាក់ចូលទៅស្រាវជ្រាវដែរ យើងគ្មានជំរើសទេ ប៉ុន្តែយើងនឹងព្យាយាមថាពេលខាងមុខនេះ ដោយសារឱកាសល្អសំរាប់ថ្ងៃ០១ខែមេសាឆ្នាំ២០០៧នឹងបោះឆ្នោត យើងនឹងលើកយកទៅដាក់នៅសាលាអូតែលហើយ យើងក៏គាំទ្រប្រសាសន៍របស់លោកជំទប់ទី២ឃុំស្រះឬស្សី ដែលថាចង់ឱ្យផុតពីខែវស្សា ដើម្បីថាវាមានតែរដូវប្រាំងបានយើងដំណើរការបានល្អអញ្ចឹងយើងត្រូវតែមានកំនត់ច្បាស់លាស់ ថាបើសិនសម្រាប់បោះឆ្នោតខាងមុខ ខែមេសាមិនចោលទេទួលសាលាហ្នឹងឆ្លងប្រឡាយជ្រៅ អាចថាខែ០៧ មានប្រធានសក្ត៍មកមួយទុកឆ្លងកាត់ទឹកឡើងលឿនអីអញ្ចឹង យើងមានបញ្ហាយើងនឹងដោះដូរ ។ ដោយឡែកផ្ទះលោកឃឹមសាវ៉េតនេះ យើងឃើញថាហាក់ដូចជាពិបាកឆ្លើយដែរ ដោយសារលោកឃឹមសាវ៉េត ជាអាជ្ញាធរអាកាសចរ អញ្ចឹងហាក់ដូចជាតួនាទីក្នុងរដ្ឋអំណាចអី ដែលឱ្យប្រជាជនឃើញគាត់ខ្លាចគាត់គោរពគាត់ ឃើញគាត់ថាជាមេឃុំអីអត់ទេ អញ្ចឹងគឺគាត់ជាអាកាសចរស៊ីវិល យើងឃើញថាការបរិចាករបស់គាត់ជាភាពថ្លៃថ្លាណាស់សំរាប់យើង យើងអត់មាន លុយជួលជាអាគារទីស្នាក់ការដូចអ៊ុនតាក់ គឺថា១ការិយាល័យប៉ុន្មានដុល្លាសំរាប់ធ្វើ គឺគេសង់ជាស្នួយអីសំរាប់ធ្វើជាការិយាល័យតែម្តង។ ហើយផ្ទះគាត់ជាផ្ទះមួយដែលនៅជាប់ភូមិនុងតាណាប់ហ្នឹងស្រាប់ប្រជាជននៅទីនោះ គ្មានជំម្រើសទេ ព្រោះគ្មានសាលារៀននៅភូមិនុងតាណាប់ បើមកបោះនៅទីនេះនៅសាលាស្រះឬស្សី ឬវិទ្យាល័យហ៊ុនសែន ឆ្ងាយជាងផ្ទះរបស់គាត់ទៀត យើងឃើញថាចំនុច ដែលគាត់លើកមកនេះយើងទទួលតែការបង្ហាញរបស់ខ្ញុំចង់ឱ្យឃើញច្បាស់ថាផ្ទះលោកឃឹមសាវ៉េត មិនមែនប្រធានអាកាសចរទេប៉ះពាល់ដល់បញ្ហារដ្ឋអំណាច បើអង្គប្រជុំយល់ឃើញអញ្ចឹងយើងលើកទៅកន្លែងផ្សេងទៀត ហើយនេះខ្ញុំយល់ថាមិនប៉ះពាល់ដូចនៅសាលាបរិវ៉ាត់ទេ។

មួយទៀត ចំពោះការងារដែលថាការទិញដូរសន្លឹកឆ្នោត ហួសពីរង្វង់សមត្ថកិច្ចរបស់យើងខ្ញុំដែលត្រូវតាមដាន បានន័យថាក្នុង១ដំណាក់កាលយើងមានគ្នាបីបួនប្រាំនាក់ យើងមិនអាចបែងចែកកំលាំង ដូចសន្តិសុខទៅឱនទៅលបស្តាប់ក្រោមផ្ទះអ្នកនេះ ក្រោមផ្ទះអ្នកនោះទេ ថាតើគេទិញដូរប៉ុន្មាន ? យើងអត់អាចដឹងបានទេ ប៉ុន្តែខ្ញុំចង់ជូនយោបល់ទៅវិញថាបើសិនជាគណបក្ស សមរង្ស៊ី យល់ថាឈ្មោះក ឈ្មោះខ របស់ខ្លួននោះបានចាញ់បោកគេ ឬគេទិញទឹកចិត្តបាននោះ ស្តាប់ឱ្យបានច្បាស់នេះជាការប្រសើរ ហើយបើគាត់ជាអ្នកបោកប្រាស់ គណបក្សណាមួយ ដើម្បីយកលុយពីគេមកនោះ គាត់ជាសាក្សីដ៏សំខាន់របស់យើងក្នុងការប្តឹងគណបក្សហ្នឹងឱ្យធ្លាក់ទឹកតាមនីតិវិធីបើគាត់ទិញទឹកចិត្តគេមែន គាត់ត្រូវប្រឈមមុខនឹងច្បាប់ ហើយនេះជាប្រការល្អ ដូច្នេះអ្វីដែលជាការប្តឹងផ្តល់ គឺទាមទារឱ្យមានភស្តុតាងច្បាស់លាស់ មានហេតុ មានផល អង្គហេតុ អង្គច្បាប់ត្រឹមត្រូវ ដើម្បីមានមូលដ្ឋាន អញ្ចឹងគ្រាន់តែឃើញស្រកចុះនៃតួលេខនៃ គណបក្សទីមួយ១ថាបើចំនួន៥០ ហើយនៅសល់៣០នាក់ បាត់២០នាក់ទៅណា នេះជារឿងគណបក្ស របស់យើងមិនដឹងថាក្នុងគណបក្សហ្នឹង ពេលជិតបោះឆ្នោតបានពង្រឹងសមត្ថភាពប៉ុណ្ណាទេ ? ហួសនឹងសមត្ថកិច្ចរបស់ខ្ញុំ មិនដឹងទេគ្រាន់តែថាការទិញសន្លឹកឆ្នោតនេះជារឿងមួយលើកដោយសារបាត់ចំនួនប៉ុណ្ណឹងទេ ប៉ុន្តែយើងអត់មានភស្តុតាងបង្ហាញបញ្ជាក់បាន។

មួយទៀតទាក់ទងនឹងបញ្ហាអាសនៈ ខ្ញុំក៏ហួសសមត្ថភាពដែរព្រោះច្បាប់កំពូលនៅលើ ខ្ញុំសួរ៣ដងហើយគាត់ក៏ពិបាកដែរ អញ្ចឹងការចែកអាសនៈថាអ្នកនេះជាប្រធានច្បាស់លាស់ថាស្អី១ហ្នឹង ហួសសមត្ថភាពខ្ញុំមិនអាចឆ្លើយបានទេ។ ដោយពេលវេលាយើងជិតអស់ ចំពោះបញ្ហាលោកឈិតឆោម និងបងស្រី ព្រមទាំងបញ្ហាដែលទាក់ទងនឹងអត្តសញ្ញាណប័ណ្ណ ខ្ញុំអាចយកច្របាច់ចូលគ្នាបាន

គឺថាយើងបានលើកជាអនុសាសន៍ផងដែរហើយបង ឱកសេរីសោភក្តិ ក៏បានបង្ហាញផងដែរ ថាអ្វីដែលគាត់ចង់បង្ហាញនោះ គឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់ NGO ជាច្រើនក្នុងការជំរុញការធ្វើអត្តសញ្ញាណប័ណ្ណ ប៉ុន្តែអ្វីដែរជាការព្រួយបារម្ភរបស់យើងទាំងខ្ញុំ ទាំងសមត្ថកិច្ច ជំទប់ លេខ១ លេខ២ ខាងគណបក្សក្តី ឈ្មោះគឺខុសច្រើនណាស់ អ្វីដែលយើងពិបាកក្នុងពេលនេះដោយសារទំលាប់មួយគឺថាធ្វើម៉េចនៅតែធ្វើអញ្ចឹង យើងមិនដឹងថាច្បាប់បត់ បែនដល់ណា។ អ្វីដែលជាការព្រួយបារម្ភរបស់ខ្ញុំ គឺនៅពេលដែលដំណាក់កាលបិទបញ្ជី ដើម្បីផ្ទៀងផ្ទាត់បញ្ជីឈ្មោះ យើងឃើញថាប្រជាពលរដ្ឋមកមើលខ្ទង់១០ឬ១៥%តែប៉ុណ្ណោះទេ ឯ៧០%ឬ៨០%អត់សូវមើលទេ ជូនកាលគាត់ផ្តាំតាមគេឱ្យមើល ដឹងថាមានឈ្មោះហើយ ប៉ុន្តែឈ្មោះដែលមានក្នុងបញ្ជីនោះមិនដឹងថាដូចក្នុងអត្តសញ្ញាណប័ណ្ណឬដូចសៀវភៅគ្រួសារនោះទេ ឈ្មោះខ្លះសល់តាំងពីឆ្នាំ១៩៩៨មក។ ឧទាហរណ៍ដូចក្នុងគ្រួសារ បងខាន់សាមៀត គាត់អាចដឹងថាមើលឱ្យតាយីនមើលឱ្យកូនគាត់អាចមើលបាន តែអ្នកដទៃអត់មានមកមើល អត់ដឹងទេ តែអញ្ចឹងសៀវភៅគ្រួសារខ្លះ នរគបាលគាត់ធ្វើប្រសាសន៍របស់លោក ឈិតឆោមលើកខ្ញុំគាំទ្រដែលខ្ញុំទៅឃើញមួយជំនារខាងលិចសាលាចំការលើអន្លង់ផេរ មួយណាក៏ថ្ងៃ ០១មករា មួយណាក៏ថ្ងៃ០១មករា សឹងតែ១បញ្ជីហ្នឹង០១ មករាទាំងអស់ថ្ងៃខែឆ្នាំកំណើត ដូច្នេះប៉ូលីសគេចង់ស្រួលចាំថា អឺបើគេសួរថាអឺថា ០១ខែមករាហើយអឹងឆ្នាំច ឆ្នាំជូត សងទៅ ៣៧ឆ្នាំសងឆ្នាំទៅនិងឥឡូវទៅឃើញហើយ អញ្ចឹងដល់ពេលមែនទែនរបស់គាត់មិនមកអញ្ចឹងផង គាត់មិនបានចាំអីប្រាកដទេគាត់ថាកូនខ្ញុំមួយនេះ កើតតាំងពី១៨-១៩ឆ្នាំមុន កាលខ្ញុំកាប់ចំការនៅទីនេះនៅអូរចារ តើមានស្អីអញ្ចឹងបានថាបញ្ហានេះចោទ ។

ជាសំនូមពររបស់ខ្ញុំយើង យល់បញ្ហាទាំងអស់គ្នាថា យើងខ្ញុំក៏ទទួលស្គាល់ការផ្សព្វផ្សាយជាទូទៅរបស់ គជប ក្តី គឃប ក្តីមិនបានគ្រប់ជ្រុងជ្រោយទេកន្លងមក សូមអរគុណអង្គការនិកហ្វិច ខុមហ្វ្រែល ឬក៏ឧបសែល ដែលបានជួយច្រើនណាស់ក្នុងការអប់រំសាធារណៈជននេះ រហូតដល់និកហ្វិចធ្វើការបញ្ចាំងជាល្ខោនជាតុក្កតា ខ្ញុំបានសរសេរចូលរបាយការណ៍។ ក្នុងការជួយឱ្យប្រជាជនបានដឹងហើយប្រជាជនយើងគិតទៅមានក៏រិតតិចតួចណាស់ដែលក្តាប់បាន ដោយគាត់រវល់ក្នុងការងាររកស៊ីរបស់គាត់ចុះឡើងៗ ទាល់តែដល់ពេលបោះឆ្នោតមកមើលជូនកាលបាត់ឈ្មោះគាត់ ឬក៏ពេលដែលគ្មានឈ្មោះ គាត់មិនបានតវ៉ាពីដើមទីទេ បើតវ៉ាពីដើមទីដឹងថាគាត់បាត់មែនក្នុងថ្ងៃ០១ដល់ថ្ងៃ២០តុលា គឺគាត់ចុះឡើងវិញបានតែក្រោយមក ដល់ពេលបោះស្រាប់តែមានការភ្ញាក់ផ្អើលបាត់ឈ្មោះឬជូនការឈ្មោះច្រឡំឬកំព្យូទ័រទាញខុស គឺថាសិទ្ធិកែតំរូវ និងសិទ្ធិពិនិត្យបញ្ជី គេនៅតែរក្សាថាពិនិត្យបញ្ជីសំខាន់ ចុះឈ្មោះសំខាន់ហើយសំដៅទៅលើថ្មីតែពិនិត្យ បញ្ជីវាជារឿងដឹងខ្លួនហើយថា អាយុត្រូវទេ អាសយដ្ឋានត្រូវទេ អក្ខរាវិរុទ្ធឈ្មោះយើងត្រូវទេ ដែលយើងត្រូវធ្វើឱ្យបានសុក្រិត្យល្អបំផុត បើយកអត្តសញ្ញាណប័ណ្ណទៅបោះទាល់តែឈ្មោះហ្នឹងដូចអត្តសញ្ញាណប័ណ្ណបានមានសុពលភាព អញ្ចឹងបានកន្លងមកយើងឃើញថា ទំរង់ ១០.១៨ យើងសូមអរគុណលើលោកមេឃុំជាច្រើន ដែលឡើយហត់ក្នុងការធ្វើទំរង់១០.១៨ ដែលអាចបង្កលក្ខណៈឱ្យការបោះឆ្នោតបាន។ ចំនុចនេះជាការព្រួយបារម្ភទាល់តែយើងទាំងអស់គ្នាជួយគ្នា ទាំងក្រុមប្រឹក្សាឃុំ ឱ្យតែគេចេញយុទ្ធនាការមួយពិនិត្យបញ្ជី គឺពិនិត្យបញ្ជីចាស់ដែលមានតាំងពីឆ្នាំមុននោះ បញ្ជីចុងក្រោយដែលធ្វើពីឆ្នាំមុននោះ តើមានមែនឬអត់ បើអត់មានយើងចុះថ្មីបាន គេខ្លាចតែចូលទៅវាស្ទួនជាមួយគ្នា ជួនកាលដូចយើងឃើញនៅកន្លែងខ្លះ ឈ្មោះម៉ែនសាគុណស្រាប់តែគាត់ចូលមានឈ្មោះ ម៉ែនសាគុណ ក៏គាត់ ដល់ម៉ែសាគុណក៏គាត់ទៀត អញ្ចឹងមនុស្សតែមួយមានឈ្មោះដល់ទៅ២ ជួនកាលគាត់អត់ចាំអាយុទេអ្នកចុះឈ្មោះខ្លះដាក់ស្មានឱ្យគាត់ ជូនកាលទិន្ន័យខុស អញ្ចឹងពេលខ្លះដូចយើងបានជជែកជាប្រធានបទសំខាន់ពីបញ្ហា ឈ្មោះ និងថ្ងៃខែមិនអាចត្រូវគ្នាបានទេ។ មួយទៀតខ្ញុំសូមឆ្លើយដល់ រឿងសិស្សគរុកោសល្យ ខ្ញុំមិនអាចឆ្លើយបានទេ បើសិនជាផ្លូវច្បាប់មិនអាចបោះបានទេ បើបោះក្រុមប្រឹក្សាឃុំ ខ្ញុំមិនដឹងទេ ក្រែងថាអាចអ្នកសម្របសម្រួលយល់យ៉ាងណាអាចមានបាន។

ចំនុចរបស់ខាង លោក ថាផាន់ ខ្ញុំបានបញ្ជាក់ហើយថាខ្ញុំគាំទ្រថាចង់បានរដូវវស្សាកុំឱ្យប៉ះពាល់ ព្រោះថាបើចុះឈ្មោះក៏យើងឃើញថាខាតធំណាស់បើបោះក៏ខ្វះការចូលរួមហើយ ព្រោះថាពេលខ្លះ គឺគាត់មិនអាចចោលស្រូវ ចោលស្រែគាត់បានទេ នេះស្ទូងកំពុងតែល្អខ្សៀវងងឹតស្រាប់មកទាំងអស់ គោចូលស៊ីអស់ ព្រោះស្រុកនេះគោក្របីលែងពាសវាលពាសកាល គាត់គិតឃើញផលប្រយោជន៍គាត់តែបើមិនប៉ះពាល់រដូវបង្ករបង្កើនផលទេ ឬរដូវវស្សារ ពិតជាការចុះឈ្មោះនិងការបោះឆ្នោតបានល្អប្រសើរ។ ចំនុចរបស់លោកតែនថន ខ្ញុំឃើញថាចំនុចរបស់គាត់ល្អៗច្រើនណាស់ទាក់ទងនឹងការងារគាត់លើកនេះ លើកមានហេតុផលច្បាស់លាស់ អញ្ចឹងយើងឃើញថាបញ្ហាសំខាន់មួយ ដែលគាត់បានសំនូមពរនេះខ្ញុំក៏ចាប់អារម្មណ៍ដែរ បើសិនជាអាជ្ញាធរទាំងអស់ ដែលបានបោះឆ្នោតចប់ភារៈកិច្ចនៃការបោះឆ្នោតត្រឡប់ទៅផ្ទះវិញ ត្រង់ដែលថាមិនគួរហាមឃាត់ ត្រង់ថាសួរគ្នាបន្តិចបន្តួចបានទេ បើសិនជាថាកន្លងមកទឹកមុខធ្លាប់រាប់អានគ្នាស្រាប់តែមុខមាំដាក់គ្នាថ្ងៃនេះ ប៉ុន្តែនិយាយគ្នានេះបើខុសរង្វង់ច្បាប់ ខ្ញុំថា បោះឆ្នោតឱ្យគ្នាអញ្ចេះចាប់ក្រិបតែម្តងទៅ។ ខ្ញុំសង្ឃឹមថាតាមរយៈការប្រជុំខប់សែលនៅពេលនេះ ហើយក៏ខ្ញុំបានចូលរួមលើកទី១ដែល ឃើញថាមានសារៈសំខាន់ដ៏ធំធេងណាស់ដែលផ្តល់ឱកាសឱ្យយើងបានជួបជុំគ្នា យល់ចិត្តយល់ថ្លើមគ្នា ដើម្បីពង្រឹងកិច្ចការងារក្នុងកិច្ចសហការល្អ ដើម្បីឱ្យការងារបោះឆ្នោតខេត្តស្ទឹងត្រែងយើងបានជោគជ័យទាំងអស់គ្នា។

**លោក ឱក សេរី សោភក្តិ**

ខ្ញុំសូមអរគុណបងប្រធាន PEC ដែលលោកឆ្លើយបានកន្លែងណាដែលលោកឆ្លើយបាន ក៏លោកឆ្លើយដោយសមស្របកន្លែងណាដែលលោកខ្វះខាត ក៏លោកទទួលដោយស្មោះ។ ខ្ញុំដើរច្រើនខេត្តហើយ ខ្ញុំសូមសរសើរ គជប ក្នុងលក្ខណៈមួយមានការខ្វះខាតច្រើន ប៉ុន្តែមានលក្ខណៈមួយដែរនីតិវិធីនៃការជ្រើសរើសមន្ត្រីប្រធាន PEC នៅតាមខេត្ត ខ្ញុំមិនដឹងគាត់ជ្រើសរើសយ៉ាងណាទេប៉ុន្តែសុទ្ធតែបានមនុស្សល្អៗទាំងអស់នៅគ្រប់ខេត្តទាំងអស់ យើងបានដើរនៅច្រើនខេត្តហើយ ប៉ុន្តែមិនមានករណីណាមួយដែលយើងមើលហើយថាមិនពេញចិត្ត គេគោរងតែទទួលស្គាល់អញ្ចឹង ហើយឋិតនៅក្នុងករណីមួយដែលថ្មីថ្មោងដែលលំបាកសំពាធនយោបាយក៏ច្រើន ហើយច្បាប់ហ្នឹងចងសំម្បើមណាស់ ច្បាប់បោះឆ្នោតរបស់យើងគោរងតែត្រូវមានវិសោធនកម្មទៅថ្ងៃមុខច្រើនណាស់ព្រោះច្បាប់ប្រគល់ឱ្យ NEC,PEC ដល់ទៅ៣អំណាច ធ្វើនៅក្នុងអង្គការតែមួយ អំណាចនីតិបញ្ញត្តិ ដោយសារធ្វើនីតិវិធី ក្រឹត្យក្រមអីប៉ុន្មាន គឺថា NEC,PEC ហើយ NEC សរសេរមកទាំងអស់ PEC អ្នកអនុវត្តអំណាចនីតិប្រតិបត្តិ សរសេរក្រឹត្យក្រម ហើយអនុវត្តខ្លួនឯងទៀត អំណាចតុលាការ ពេលដែលមានទំនាស់នរណាប្តឹងជាមួយនិង PEC និង CEC ខ្លួនឯងជាអ្នកធ្វើចៅក្រមដោះស្រាយទៀត ។ ទៅថ្ងៃមុខទៅគោរងតែយើងដោះស្រាយបញ្ហាហ្នឹង បើសិនជាយើងធ្វើទៀតសង្កត់គាត់ម្នឹងៗ គាត់មិនអាចបំពេញតួនាទីបានទេ ដូចជារឿងដោះស្រាយទំនាស់ដោះស្រាយពាក្យបណ្តឹង ច្បាប់ចងគាត់មែនទែន ហើយខ្ញុំឯកភាពជាមួយខាងគណបក្សសមរង្ស៊ី យើងបានលើករឿងហ្នឹងច្រើនណាស់ ប៉ុន្តែ គជប គាត់ក៏ឯកភាពជាមួយដែរ ប៉ុន្តែគាត់មិនដឹងធ្វើម៉េចដោយសារច្បាប់សរសេរមកអញ្ចឹង ហើយគាត់ត្រូវធ្វើតាមតួនាទីអញ្ចឹង ប៉ុន្តែទទួលស្គាល់ទាំងអស់គ្នាថា មានការចន្លោះប្រហោងច្រើនណាស់ ដែលយើងត្រូវធ្វើវិសោធនកម្មទៅថ្ងៃមុខតទៅទៀត។

ទាក់ទងនឹងបញ្ហាមួយទៀត គឺសមាសភាពរបស់ គជប តាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម ដូចដែលខ្ញុំបានជំរាបអម្បាញ់មិញគឺបងប្រធាន PEC នៅគ្រប់ខេត្តទាំងអស់ គាត់ធ្វើទៅតាមសម្មតិភាព និងភាពស្មោះត្រង់របស់លោក ហើយសមត្ថភាពយើងអត់ចោទជាបញ្ហាទេ ព្រោះនៅខេត្តនីមួយៗ ខ្ញុំមិនដែលបានឃើញប្រធាន PEC ណាមួយ ដែលអសមត្ថភាពទេ ផ្ទុយទៅវិញមានសមត្ថភាពបរិបូរណ៍ ហើយមានការគោរពពីគ្រប់គណបក្សជំទាស់នៅតាមខេត្តដែលខ្ញុំបាទបានទទួល ហើយនៅថ្ងៃនេះ យើងក៏បាន៣ដែរគណបក្ស

ជំទាស់ បានធ្វើការសរសើរច្រើនណាស់នៅក្នុងរឿងនេះ ប៉ុន្តែសមាសភាព គជប នៅក្រោយពេលរៀបចំការ បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ហើយសមាសភាពរបស់គាត់ត្រូវចប់ ហើយត្រូវធ្វើការជ្រើសរើសថ្មី តាមដែលខ្ញុំបាទបានដឹង គឺខាងក្រសួងមហាផ្ទៃ ដែលច្បាប់បានប្រគល់តួនាទីឱ្យរៀបចំ គជប ថ្មីនោះក្រសួងមហាផ្ទៃ ដោយសារគាំទ្រយន្តការខប់សែលមានបំណង នឹងដាក់នូវគំរោងការជ្រើសរើសសមាសភាព គជប ថ្មីហ្នឹងនៅក្នុងយន្តការខប់សែលដើម្បីឱ្យមានការពិភាក្សាគ្នាថា តើលក្ខណៈណាខ្លះ ដែលយើងគួរតែជ្រើសរើសសមាភាព គជប ថ្មី ? មានចំនួនប៉ុន្មាននាក់ ? មកពីណាខ្លះ ? ឱ្យឆ្លើយតបទៅនឹងភាពអព្យាក្រឹត្យ ឯករាជ្យភាពដែលមតិសាធារណៈជន ទាំងជាតិទាំងអន្តរជាតិអាចទទួលយកបាន យើងគិតមើលនៅក្នុងកាលនេះបន្តិចទៀត គជប នឹងដូរចេញពីទីតាំងរបស់ក្រសួងមហាផ្ទៃទៅនៅគីឡូម៉ែតលេខ៦ហើយ ដើម្បីអី ? ដើម្បីដករូបភាពហ្នឹង រូបភាពដែលថានៅតែជាប់ជាមួយរាជរដ្ឋាភិបាលឱ្យមានតម្លាភាពមួយឱ្យមានលក្ខណៈឯករាជ្យភាពមួយ ។

ដូច្នេះហើយបានជាយើង ធ្វើពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ សុទ្ធតែខំប្រឹងដើរទៅរកអព្យាក្រឹត្យភាព និង ឯករាជ្យភាពជូនកាលមិនបាន១០០%ដូចចិត្តដែលយើងចង់ ប៉ុន្តែអ្វីក៏ដោយ ការដែលធ្វើស្ថាប័នធំៗ តោងតែមានពេលវេលាហើយរាជរដ្ឋាភិបាលនៅក្នុងហ្នឹងក៏ខំប្រឹងដែរ។ ខ្ញុំឮសួរមកថាពី៥នាក់ ឥឡូវកើនដល់ ទៅ៩នាក់ នេះខ្ញុំឮសួរទេកុំកត់យកជាផ្លូវការ ប៉ុន្តែធ្វើយ៉ាងណាក៏ដោយអត់មានលួចធ្វើស្ងាត់ៗ ហើយឱ្យសភាបោះគឺយកយន្តការ ខប់សែល និងអង្គការដែលរាជរដ្ឋាភិបាល និងគណបក្សនយោបាយទាំងអស់ទទួលស្គាល់ថាមានអព្យាក្រឹត្យភាពទៀតយកមកពិភាក្សាគ្នា ដូចយើងធ្វើកិច្ចពិភាក្សាគ្នា ដើម្បីយកថាលក្ខណៈណាមួយដែលចង់បាន គជប មួយដែលយើងអាចទទួលយកបានទាំងអស់គ្នា។ ដូច្នេះហើយខ្ញុំបាទអរគុណណាស់ដែរក្នុងមួយព្រឹកនេះដែលមានការយោគយល់ពីអង្គប្រជុំទាំងអស់ ជាពិសេសគណបក្សទាំង៣ និងក្រុមប្រឹក្សាឃុំសង្កាត់ ដែលលោកមានប្រសាសន៍ឆ្លងឆ្លើយគ្នាយ៉ាងស្មោះត្រង់ និងចំឡើយរបស់បងប្រធាន PEC ក៏ធ្វើឡើងដោយ ភាពស្មោះត្រង់ទៅទៀត ហើយខ្ញុំបាទសូមគោរពយ៉ាងជ្រាលជ្រៅជាទីបំផុត។

**លោក ផាន់យុទ្ធ** តំណាងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តស្ទឹងត្រែង

ជាបឋម ខ្ញុំសូមគោរពតំណាងខាង CDRI ដែលបានមកចូលរួមនៅក្នុងថ្ងៃនេះ ជាថ្ងៃមួយដែរយើងបានចែករំលែកនូវអ្វីមួយដែលយើងបានអនុវត្តនៅក្នុងដំណើរការនៃកាបោះឆ្នោតកន្លងមក ដើម្បីរកដំណោះស្រាយធ្វើយ៉ាងម៉េចឱ្យប្រសើរកាត់បន្ថយទំនាស់ដើម្បីឱ្យយើងកសាងបាននូវវប្បធម៌សន្តិភាព។ ទទ្ទឹមនឹងនេះខ្ញុំសូមចូលរួមទៅលើចំនុច ដែលពាក់ព័ន្ធនឹងអង្គភាពរដ្ឋបាលមូលដ្ឋានដែលយើងបានធ្វើការជាមួយឃុំទាំង៣៤ ក្នុងនេះយើងឃើញថាមានវត្តមានរបស់តំណាងគណបក្ស ក៏ដូចជាក្រុមប្រឹក្សាឃុំ យើងបានចូលមកទីនេះ អញ្ចឹងយើងបានដឹងរឿងច្រើនពាក់ព័ន្ធនឹងការបោះឆ្នោត។ ការងារពាក់ព័ន្ធទី១ ខាង PEC បានលើកជាអនុសាសន៍ក៏ដូចជាការលំបាកមួយ ដែលសុំឱ្យការធ្វើផែនការឬក៏ការបណ្តុះបណ្តាលអ្វីផ្សេងៗ នៅចំពេលចុះបញ្ជីឈ្មោះបោះឆ្នោតកន្លងមកយើងបានទទួលផែនការពីក្រសួងមហាផ្ទៃតាមរយៈ PEC អំពីផែនការនៃការចុះឈ្មោះអ្នកបោះឆ្នោតនោះ ក៏ប៉ុន្តែផែនការនៅខាងកម្មវិធីសិលា ក៏ដូចជាឃុំគឺមានផែនការនៅចុងឆ្នាំនេះមានការមមាញឹកច្រើន ។

**បញ្ហាទីមួយ** គឺការធ្វើផែនការរបស់គាត់ ដើម្បីបានផែនការអភិវឌ្ឍន៍ឃុំគឺយើងធ្វើជារៀងរាល់ឆ្នាំក្នុងអាណត្តិ៥ឆ្នាំនេះគឺគាត់មាន ផែនការរៀងរាល់ឆ្នាំ អញ្ចឹងផែនការមួយៗទំរាំតែធ្វើបានគឺប្រើ រយៈពេល១១ជំហ៊ាន ឃើញថាផែនការខ្លះប្រើរយៈពេលដល់ទៅ ៥ ឬ ៦ខែ ហើយចុងខែហ្នឹងជាចុងខែដែលក្រុមប្រឹក្សាឃុំ ត្រូវធ្វើការអនុម័តពិនិត្យឡើងវិញទៅលើកម្មវិធីវិនិយោគ ដែលបានធ្វើកន្លងមក តាំងពីសិក្ខាសាលា សមាហរណកម្ម ផែនការថ្នាក់ស្រុក តាំងពីផែនការរបស់ឃុំដែលត្រូវប្រជុំថាតើដើម្បីយកថវិការឃុំ

ថវិការវិភាគ ពីថ្នាក់ជាតិសំរាប់ទៅធ្វើអ្វីមួយនៅតាមមូលដ្ឋាននោះ ត្រូវការធ្វើសកម្មភាពច្រើនត្រូវការប្រជុំប្រជាពលរដ្ឋលើកផែនការហ្នឹង ដើម្បីឱ្យ អង្គប្រជុំក្រុមប្រឹក្សាឃុំពិភាក្សាគ្នា អញ្ចឹងមានដំណើរការមានរឿងច្រើនណាស់គ្រាន់តែនៅក្នុងរឿងផែនការហ្នឹងមួយ ។

**បញ្ហាទីពីរ** យុទ្ធនាការការចុះបញ្ជីអត្រានុកូលដ្ឋាន គ្រប់ខេត្តក្រុង ក៏ដូចជាស្រុក ខណ្ឌ ឃុំ មានការជំនុំមួយឆ្នាំ គឺតែងតែឱ្យយុទ្ធនាការហ្នឹងចប់នៅក្នុងខែសីហា នៅក្នុងខែសីហាហ្នឹងឃុំនីមួយៗខំប្រឹងណាស់ ដើម្បីរាយការណ៍ប្រចាំឆ្នាំគាត់ត្រូវការធ្វើរបាយការណ៍បូកសរុប ឃើញថាពេលខ្លះឃុំខ្លះប្រលងប្រណាំងគ្នាណាស់ ដើម្បីឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានទទួលបានជោគជ័យ ប៉ុន្តែឃើញថាឃុំខ្លះទទួលបានរហូតដល់ទៅ៨0 ឬ៩0% ប៉ុន្តែឃុំមួយចំនួនទៀតគាត់ជួបការលំបាកទៅលើការធ្វើដំណើរ ខ្វះធនធានសព្វគ្រប់អញ្ចឹងការចុះបញ្ជីអត្រានុកលូដ្ឋានរបស់គាត់មិនសូវបានទេ ទន្ទឹមនឹងនេះយើងថា មានស្រុក មានអឺចូលរួម ដើម្បីជួយចុះបញ្ជីអត្រានុកូលដ្ឋាន ខ្ញុំទទួលស្គាល់ថា ការងាររបស់ឃុំ គឺមមាញឹកច្រើនណាស់ ។ មួយទៀត ផែនការបណ្ដុះបណ្ដាល សូម្បីក្រសួងមហាផ្ទៃក៏សម្រុកដែររឿងផែនការបណ្ដុះបណ្ដាលចុងឆ្នាំហ្នឹង ផែនការហ្នឹងដាក់មកដល់ពេលចុងឆ្នាំហ្នឹង គឺចង់ឱ្យសម្រេចបានជោគជ័យតាមឆ្នាំនីមួយៗ អញ្ចឹងថ្នាក់លើដាក់មកថ្នាក់ខេត្ត ចេះតែដាក់ផែនការបន្តទៀតទៅ ដើម្បីកុំឱ្យឆ្លងឆ្នាំ ។ នេះឃើញថាមានបញ្ហាស្មុគស្មាញនៅក្នុងការរៀបចំផែនការនេះ ហើយមិនមែនថាក្រសួងមហាផ្ទៃមិនដឹងទេរឿងនេះ គឺដឹង ព្រោះមេតែមួយហើយចំពេលហ្នឹង គឺក្រុមប្រឹក្សាឃុំធ្វើផែនការថវិការចុងឆ្នាំ ដើម្បីបានថវិការអនុវត្តនៅក្នុងឆ្នាំ២០០៦ គឺក្រុមប្រឹក្សាឃុំត្រូវរៀបចំធ្វើផែនការចាប់ពីខែ១០-១១ អញ្ចឹងដំណាក់កាលហ្នឹងចំដំណាក់កាលដែលយើងបើកយុទ្ធនាការ ដល់ពេលអញ្ចឹងយើង ឃើញថាមានផលប៉ះពាល់ ។

ជាមួយគ្នានេះដែរយើងឃើញនៅក្នុងអង្គការ មន្ទីរ ស្ថាប័នមួយចំនួន ក៏គាត់ប្រឹងដែរសកម្មភាពរបស់ គាត់ដែលទៅធ្វើចុងក្រោយចង់ចាយលុយគេអស់ខំធ្វើសកម្មភាព អញ្ចឹងឃុំគឺមានគ្នាតិចចង់បែកភ្នែកហើយ។ បញ្ហាទី២ ខាងគណបក្ស សមរង្ស៊ីបានលើកឡើងដែរអំពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ ដោយមរណៈភាព ជំងឺ ឬដោយបាត់បង់សមត្ថភាពការងារ គឺថាយើងកន្លងមកយើងទទួលស្គាល់ថាមានភាពយឺតយ៉ាវ ក៏ប៉ុន្តែទន្ទឹមនិងនេះកន្លងមកគាត់ចង់ដូរអី គាត់ត្រូវដាក់តែពាក្យ ចង់និយាយថា ខាងគណបក្សហ្នឹងដាក់សំណើសុំដូរ ក៏ប៉ុន្តែច្បាប់ថ្មីមុននឹងដូរបានគេត្រូវតែមានសំបុត្រមរណៈភាព ឧបមាថាបើឈឺអ្នកត្រូវតែមាន សំបុត្របញ្ជាក់អំពីខាងពេទ្យត្រឹមត្រូវ រៀបចំមកតាមរយៈឃុំ ឆ្លងមកស្រុក ហើយស្រុកយកមកដាក់នៅកន្លែងអង្គភាពរដ្ឋបាលមូលដ្ឋាន ហើយអង្គភាពរដ្ឋបាលមូលដ្ឋានពិនិត្យមើលឯកសារគ្រប់គ្រាន់បានបញ្ជូនទៅអភិបាលខេត្តចុះហត្ថលេខាបញ្ជូនទៅក្រសួងមហាផ្ទៃ ហើយទំរាំក្រសួងមហាផ្ទៃសួរព័តិមានសព្វគ្រប់រៀបចំឯកសារត្រឡប់មកវិញ គឺថាមិនមែន១៤ថ្ងៃទេ អាចយូរជាងហ្នឹង ប៉ុន្តែខ្ញុំមិនដឹងថាអាចមានការកែប្រែយ៉ាងណាទៀតទេរឿងហ្នឹងនេះ ខ្ញុំគ្រាន់តែចង់និយាយពីដំណើរការ មិនមែនចង់ឱ្យផ្លាស់ប្តូរភ្លាម បានភ្លាមទេ។ អញ្ចឹងទទួលស្គាល់ថាមានការលំបាក ហើយឯកសារមួយចំនួនដែលមានគ្រប់គ្រាន់យើងអត់ទុកទេ យើងបញ្ជូនទៅក្រសួងមហាផ្ទៃមួយចំនួនហើយព្រោះថាការយើងធ្វើបើយើងមានឯកសារគ្រប់គ្រាន់ពាក់ព័ន្ធទៅហ្នឹងការបើកប្រាក់ឧបត្ថមរបស់គាត់ នោះបើសិន ជាមិនមានឯកសារគ្រប់គ្រាន់ទេ ខាងនោះគេអត់ទំលាក់ឯកសារទទួលស្គាល់អីមក អញ្ចឹងពាក់ព័ន្ធនិងការបើកប្រាក់ខែ របស់គាត់គឺជួបការលំបាក។

**បញ្ហាទីបី** ខ្ញុំក៏សុំចូលរួមយោបល់ដែរពាក់ព័ន្ធនឹងការទិញដូរសន្លឹកឆ្នោតគណបក្សកន្លងមកនេះ ខ្ញុំក៏ធ្លាប់ធ្វើជាមន្ត្រីសេវាកម្មច្បាប់ដោះស្រាយបណ្ដឹងនៅ PEC ដែរ នៅក្នុងអាណត្តិការបោះឆ្នោតក្រុមប្រឹក្សាឃុំលើកទី១ ។ ខ្ញុំធ្លាប់បានប្រជុំជាមួយអង្គការនិកហ្វិច ដែលបានមកធ្វើវេទិការនៅសាលាគរុកោសល្យមួយលើក ដែលក្នុងនោះគណបក្ស សមរង្ស៊ី ក៏ដូចជា ហ៊្វុនស៊ិនប៉ិច អត់ឮគណបក្ស ប្រជាជន លើកឡើងទេ ប៉ុន្តែច្រើននិយាយថាមានការលួចបន្លំឬក៏ទិញសន្លឹកឆ្នោត ឯខ្ញុំនៅកន្លែងគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោតទទួលបណ្ដឹង ប៉ុន្តែខ្ញុំអត់បានឃើញបណ្ដឹងណាមួយនិយាយពីរឿងហ្នឹងទេ ប៉ុន្តែចេះតែឮរឿងនិយាយបរិហារកេរ្តិ៍ ចេះតែ

ថាដើម្បីសំអុយខាងគណបក្សមួយហ្នឹងក៏អាចថាបាន ពីព្រោះយើងអត់មានឯកសារច្បាស់លាស់ ដល់ពេលអញ្ចឹងយើងមិនអាចដោះស្រាយបានទេ ដូចលោកប្រធាន PEC គាត់បានលើកឡើងថាមានការទិញ សុំឱ្យចាប់ឱ្យបានអ្នកណាជាអ្នកទិញ ចាប់ឱ្យបានប្តឹងកសាងសំនុំរឿងយកមកដាក់ប្តឹង ពេលនោះសមត្ថកិច្ចខាងគណៈកម្មាធិការរៀបចំការបោះឆ្នោតធ្វើការដោះស្រាយ បើអត់ដាក់មកហើយចេះតែថាពាសវាលពាសកាលយើង អត់មានឯកសារត្រឹមត្រូវ ឯកសារគតិយុទ្ធ យើងមិនអាចរៀបចំសំនុំធ្វើការដោះស្រាយបានសមស្របទេ គឺថាមុននឹងចោទគេសូមចាប់ឱ្យបានភស្តុតាងច្បាស់លាស់ កុំឱ្យយើងចេះតែនិយាយ ហើយនិយាយទៅអាចមានរឿងប៉ះពាល់ដល់ភាគីម្ខាងៗ អញ្ចឹងសូមថាដើម្បីប្រពៃណីឬក៏វប្បធម៌សន្តិភាព សូមឱ្យរក្សានូវក្រមសីលធម៌របស់គណបក្សនយោបាយនីមួយៗ គឺថាយើងសូមឱ្យមានការថ្លៃថ្នូរ និងគោរពនូវភាពត្រឹមត្រូវផង។

**លោក ឱក សេរី សោភ័ក្តិ**

នៅពេលដែលយើងប្រជុំខប់សែលប្រ៉ូមហ្នឹងនៅតាមខេត្តម្តងៗ គឺការដែលបានទទួលអត្ថាធិប្បាយ ឬមួយក៏មានយោបល់មានមតិអំពីបងប្រធាន PEC ផងនិងតំណាងខាង PLAU ផង ព្រោះខាង PLAU ជាតំណាងខាងក្រសួងមហាផ្ទៃនៅប្រចាំខេត្ត ហើយដូច្នេះការនេះជាការល្អណាស់ ទោះបីការអត្ថាធិប្បាយរបស់យើងឆ្លើយទៅមិនពេញចិត្ត ឬមួយក៏ខ្វះខាតយ៉ាងណា ក៏មានសំលេងអំពីអាជ្ញាធរហ្នឹង ដើម្បីជំម្រាបទៅថ្នាក់ពាក់ព័ន្ធកិច្ចការនេះជាការល្អប្រសើរណាស់ ក្នុងការយើងកសាងវប្បធម៌ជជែកពិភាក្សាគ្នានេះ។ ខ្ញុំបាទសូមអនុញ្ញាតបូកសរុបនូវបញ្ហាដែលយើងបានលើកឡើងទាំងប៉ុន្មាននៅក្នុងពេលនេះ។ មុននឹងបូកសរុបសារជាថ្មីម្តងទៀត ខ្ញុំបាទគិតថានៅខេត្តស្ទឹងត្រែងនេះជាថ្មីយើងបានបង្ហាញឱ្យឃើញនូវរបៀបរបបដូចដែលបងប្រធាន PEC បានលើកអញ្ចឹង ដល់មែនទែនទៅមិនមែនខេត្តស្ទឹងត្រែងចាំបាច់មានខប់សែលហ្នឹងទេ ព្រោះយើងបានធ្វើខប់សែលហ្នឹង មុនខប់សែលបានមកដល់ទៅទៀតបានជួបប្រជុំគ្នារាល់អាទិត្យ ជជែកពិភាក្សាគ្នា ដូច្នេះអ្វីៗទាំងអស់នេះមានរួចទៅហើយ យើងខ្ញុំគ្រាន់តែមកជួយបន្ថែមពីលើហ្នឹងទៅទៀតទេ ។ ហើយអ្វីដែលបានបង្ហាញឱ្យឃើញពីព្រឹកមិញនេះជាតឹកតាងថា យើងមានទំលាប់ជជែកពិភាក្សាគ្នាបានយ៉ាងញឹកញាប់រួចមកហើយ ដូច្នេះហើយបានជាស្ថានការណ៍បោះឆ្នោតនៅខេត្តស្ទឹងត្រែងយើងនេះបានប្រព្រឹត្តទៅល្អបានយ៉ាងនេះ។ អ្វីដែលយើងបានជជែកពិភាក្សាគ្នាពីព្រឹកមិញនេះមាន

**ទី១** យើងបានទទួលស្តាប់នូវអ្វីដែលលោក ឡារី ស្រ្តេន្ទ បានមានប្រសាសន៍អំពីកិច្ចការរបស់វិទ្យាស្ថាន CDRI ដែលទាក់ទងទៅនិងវិស័យអភិវឌ្ឍន៏វិស័យសេដ្ឋកិច្ច ហើយនៅក្នុងនោះមានវិស័យកសាងសន្តិភាព ។ នៅក្នុងនោះក្នុងវិស័យកសាងសន្តិភាពនោះខប់សែលជាកម្មវិធីមួយនៃវិស័យកសាងសន្តិភាពនេះ។

**ទី២** ខ្ញុំបាទក៏បានជំរាបជូនអស់លោក លោកស្រីទាំងអស់នូវប្រវត្តិដើម និងមូលដ្ឋាននូវអ្វីដែលបានផ្តល់កំណើតដល់នូវខប់សែលនៅដំណាក់កាលទី១ ពី១៩៩៩ ដល់២០០៣ និងខប់សែលដំណាក់កាលទី២ ពី២០០៥ រហូតទៅដល់ ២០០៨ បង្កើតការបោះឆ្នោតព្រឹទ្ធសភា ការបោះឆ្នោតឃុំសង្កាត់ នៅថ្ងៃ ទី០១ខែ៤ឆ្នាំ២០០៧ និង២០០៨បោះឆ្នោតថ្នាក់ជាតិ។

**ទី៣** យើងបានស្តាប់នូវប្រសាសន៍របស់បងប្រធាន PEC ពីការសង្កេតការណ៏ស្តីពីយន្តការនៃការបោះឆ្នោតនៅខេត្តស្ទឹងត្រែងរបស់យើងមានការពិនិត្យបញ្ជីការចុះឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំ២០០៥ ។ បងប្រធាន PEC បានទទួលស្គាល់ថាលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត គឺបាន៩១%នៃប្រជាពលរដ្ឋមានអាយុ១៨ឆ្នាំ ដូច្នេះយើងទទួលស្គាល់ថាបើសិនប្រៀបធៀបទៅខេត្តផ្សេងៗ យើងនៅមានចំនួនតិចជាងខេត្តផ្សេងៗទៀត ដូច្នេះត្រូវមានការខំប្រឹងប្រែងច្រើនទៀតនៅក្នុងឆ្នាំនេះដើម្បីឱ្យបានទៅដល់

គោលដៅ។ នៅក្នុងនេះផងដែរវិទ្យាស្ថាននិងយន្តការខប់សែលក៏សុំថ្លែងនូវការកោតសរសើរដោយស្មោះដែរ PEC តែងរៀបចំអង្គប្រជុំយ៉ាងទៀងទាត់ដើម្បីនឹងបង្ការទំនាស់និងបង្កើតកិច្ចពិភាក្សាគ្នានៅជុំវិញយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោត។

ទី៤ នៅថ្នាក់ឃុំសង្កាត់យើងបានឃើញហើយថាមានបញ្ហាជាច្រើន ដែលនៅក្នុងកិច្ចការចុះឈ្មោះបោះឆ្នោតក្តី នៅក្នុងកិច្ចការធ្វើប្រចាំឆ្នាំចុះឈ្មោះត្រៀម៩ខែ២០ថ្ងៃនៅខែ១០ ហើយនៅក្នុងនេះលោកប្អូនខាង POLA បានមានប្រសាសន៍អម្បាញ់មិញច្បាស់លាស់ ហើយបានបញ្ជាក់ថានៅចុងឆ្នាំនេះគឺសង្កត់ជាន់គ្នាតែម្តង ធ្វើឱ្យក្រុមប្រឹក្សាឃុំសង្កាត់នេះលោកពិបាកនិងរវល់ខ្លួនរួចក្នុងការចុះបញ្ជីចុះឈ្មោះបោះឆ្នោតនេះតាំងពីផែនការអភិវឌ្ឍន៍ភូមិ ឃុំ ក្រុម។ ខ្ញុំបាទបានចូលរួមក្នុងកម្មវិធី សមាហរណកម្មផែនការសំរាប់អភិវឌ្ឍន៍ស្រុក ឃើញថាពិបាកមែនស៊ីពេលច្រើនណាស់១១ជំហ៊ានហ្នឹង ដូច្នេះយើងនឹងធ្វើការនេះជាមួយក្រសួងមហាផ្ទៃ ដើម្បីនឹងបញ្ចៀសបញ្ហាអស់នេះ។ រឿងបញ្ហាចុះបញ្ជីបញ្ហាអគ្រានុកូលដ្ឋាន ផែនការបណ្តុះបណ្តាលគោលនិងផែនការថវិការរបស់ក្រុមទាំងអស់នេះសុទ្ធតែជាន់ពេលវេលា២០ថ្ងៃនៅខែតុលារបស់ឃុំសង្កាត់ ដែលទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោតនេះទាំងអស់ ដូច្នេះយើងនឹងធ្វើការនៅថ្នាក់ជាតិជាមួយសាមីក្រសួងពាក់ព័ន្ធ និងអង្គការពាក់ព័ន្ធ ដើម្បីបញ្ចៀសយ៉ាងណាកុំឱ្យចំ២០ថ្ងៃនៃខែតុលានេះ។

ទី៥ អង្គប្រជុំទទួលស្គាល់ថាការផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោត ការធ្វើអត្តសញ្ញាណប័ណ្ណជាតិក្តី គឺនៅមានកំរិត ហើយសុំឱ្យអំពាវនាវឱ្យគណបក្សនយោបាយទាំងអស់និងសង្គមស៊ីវិល មេត្តាជួយធ្វើការជាមួយនិង PEC ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីចែកផ្សព្វផ្សាយព័ត៌មានហ្នឹងឱ្យបានជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋទាំងមូល។

ទី៦ មានការស្នើសុំឱ្យ PEC យកចិត្តទុកដាក់ឱ្យបានខ្លាំងជាងនេះ ទៅក្នុងការដោះស្រាយបណ្តឹង ដែលបានទទួលមកពីគណបក្សផ្សេងៗ ជាពិសេសបញ្ហាពេលវេលាសុំធ្វើឱ្យបានរួសរាន់។

ទី៧ យើងបានស្តាប់នូវប្រសាសន៍របស់ប្រធាន PEC ហើយក្នុងការដែលដាក់ការិយាល័យបោះឆ្នោតនៅក្នុងផ្ទះឯកជន ផ្ទះដែលជាមន្ត្រីរបស់ខាងសាលាស្រុក និងផ្ទះរបស់មន្ត្រីខាងអាកាសចរនោះ ដូច្នេះយើងឃើញថាជាករណីប្រធានសក្តិតាមយោលបល់របស់ខ្ញុំផ្ទាល់ជាអ្នកសម្របសម្រួលខប់សែល យើងទទួលបាននូវហេតុផលរបស់លោកប្រធាន PEC ក៏ប៉ុន្តែយើងយល់ថាតទៅថ្ងៃមុខទៅករណីនេះគួរតែជៀសវាង ព្រោះរូបភាពអព្យាក្រឹត្យ ភាពឯករាជ្យភាព របស់ PEC អាចនឹងមានការប៉ះពាល់បើសិនជាមានករណីបែបនេះទៀត ប៉ុន្តែយើងយល់នូវផលវិបាករបស់ PEC មិនថាតែខេត្តនេះទេ គ្រប់ខេត្តទាំងអស់ក្នុងការខំប្រឹងប្រែងយើងទទួលស្វាគមន៍យ៉ាងកក់ក្តៅនូវប្រសាសន៍របស់បងប្រធាន PEC ថាទៅថ្ងៃមុខនឹងដោះស្រាយបញ្ហា២នេះកុំឱ្យមានទៅថ្ងៃមុខទៀត។

ទី៨ មានបញ្ហាជាច្រើនដែលលើកឡើងដោយអង្គប្រជុំ ហើយដែលខ្ញុំបាទយល់ថាទាក់ទងទៅនឹងការគោរពឱ្យបានម៉ត់ចត់នូវនីតិវិធីនូវក្រឹត្យក្រមដែល គជប បានលើកឡើង ជាពិសេសបញ្ហាដែលលើកឡើងដោយគណបក្សជំទាស់ គឺបើយើងអនុវត្តនូវក្រឹត្យក្រមឬនីតិវិធីដែល គជប បានលើកឡើង យើងអាចបង្ការនូវទំនាស់នៃចំនួនជាច្រើន ដូច្នេះសូមឱ្យមានការចូលរួមគោរពឱ្យបានម៉ត់ចត់នៅក្នុងរឿងនេះ។

ទី៩ អង្គប្រជុំបានលើកឡើងច្រើនដែរនូវបញ្ហាអត្តសញ្ញាណប័ណ្ណ បញ្ហានេះជាការបារម្ភរបស់យើងទាំងអស់គ្នាតាំង ពីបញ្ហាខុសពាក្យពេជ្យ បញ្ហាអ្វីៗជាដើមមានការទិញអត្តសញ្ញាណប័ណ្ណទៀត ដូច្នេះរឿងនេះខាងក្រសួងមានសមត្ថកិច្ច ជាពិសេសខាងប៉ូលីស និងមានការពិនិត្យមើលឱ្យបានច្រើននៅក្នុងរឿងនេះ។

**ទី១០** ទាក់ទងទៅនឹងសមាសភាពតាំងពី គជប តាំងពី PEC, CEC រហូតដល់ PSO ជាដើម បញ្ហាទាំងអស់នេះយើងគិតថានឹងមានការបើកធ្វើកិច្ចពិភាក្សាជាចំហរនៅពេលខាងមុខនេះ ជាពិសេសនៅពេលដែលត្រៀមលក្ខណៈដើម្បីរៀបចំសារជាថ្មីនៅឆ្នាំ២០០៧ សមាសភាពថ្មីរបស់ គជប ដែលក្រសួងមហាផ្ទៃមានគំរោងហើយសុំឱ្យយន្តការខប់សែលនេះជាអ្នករៀបចំធ្វើវេទិការពិភាក្សានៅក្នុងរឿងនេះ ។

**ទី១១** អង្គប្រជុំទទួលស្គាល់ផងដែរថាប្រជាពលរដ្ឋរបស់យើងលោកនៅមានទំលាប់មានក៏រិត ដូច្នេះហើយការអប់រំប្រជាពលរដ្ឋ ដែលជាអ្នកបោះឆ្នោតត្រូវតែចូលរួមគ្នាធ្វើ ដើម្បីអប់រំឱ្យគាត់យល់នូវសារៈសំខាន់នៃការចុះឈ្មោះបោះឆ្នោត នៃការចុះអត្រានុកូលដ្ឋាន នៃការប្រយ័ត្នកុំឱ្យដូរឈ្មោះចុះឡើង សូម្បីតែសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក៏បានដូរឈ្មោះចុះឡើង នាំឱ្យមានផលលំបាកច្រើនណាស់ នៅក្នុងរឿងហ្នឹង ដូច្នេះការអប់រំអ្នកបោះឆ្នោតត្រូវធ្វើបន្តទៅទៀតហើយឱ្យមានក៏រិតទូលំទូលាយ ។

**ទី១២** ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត យើងគិតថាបញ្ហាដែលលើកឡើងទាំងអម្បាលមាណ សុំឱ្យមានការគោរពកម្មវិធីដែលបានព្រមព្រៀងជាមួយគ្នា កុំឱ្យជាន់ពេលវេលា ជាន់ថ្ងៃ ជាន់ទីកន្លែងគ្នា និងសូមឱ្យគណបក្សទាំងអស់គោរពក្រមសីលធមិ ដែលបានព្រមព្រៀងជាមួយគ្នាហើយនៅមុនពេលធ្វើយុទ្ធនាការឃោសនាម្តងៗ ។

**ទី១៣** មានសំណើសុំឱ្យជៀសវាងរដូវភ្លៀង កន្លែងនេះយើងបានទទួលពីខេត្តឯទៀតៗជាច្រើន ប៉ុន្តែយើងមិនដឹងថាធ្វើបានប៉ុណ្ណាទេ ប៉ុន្តែខប់សែលមានការឯកភាពពេញទីនៅក្នុងការដែលពេលមានរដូវភ្លៀងម្តងៗខេត្ត ខ្លះមានការពិបាកណាស់ក្នុងការចលនាឱ្យប្រជាពលរដ្ឋមកបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ។

**ទី១៤** យើងក៏ឯកភាពនៅក្នុងនេះផងដែរ ហើយខេត្តជាច្រើនដែលយើងបានឆ្លងកាត់បានទទួលឯកភាពនឹងខំប្រឹងប្រែង វត្តមានរបស់មន្ត្រីមូលដ្ឋាននៅជុំវិញការិយាល័យបោះឆ្នោត និងសុំកុំឱ្យមានការដែលលើសពីលក្ខណៈគួរសម ក៏ប៉ុន្តែលក្ខណៈអូសបន្លាយនូវវត្តមានទាំងអស់នោះគឺបើអាចធ្វើទៅបានសូមកុំឱ្យមានវត្តមានអូសបន្លាយនៅក្នុងជុំវិញការិយាល័យបោះឆ្នោត ។

ជាចុងក្រោយមិនមែនជាបញ្ហាទេ ប៉ុន្តែជាកិច្ចការដែលខ្ញុំបាទបានសង្កេតឃើញដោយរំភើប គឺបរិយាកាសដ៏ស្និតស្នាល គោរពគ្នាទៅវិញទៅមកនៃអង្គប្រជុំនៃវាគ្មិនទាំងអស់ ដែលធ្វើឱ្យយើងមានជំនឿនិងមោទនភាពនៅក្នុងឋានៈជាប្រជាពលរដ្ឋខ្មែរនោះ នៅពេលដែលឃើញការឆ្លើយឆ្លងគ្នានៅជុំវិញបញ្ហាដែលក្តៅកគុក អាចនិយាយឆ្លើយឆ្លងគ្នាបានដោយសមរម្យដោយគោរពគ្នាទៅ វិញទៅមកបែបនេះ ។

**លោក ឡារី ស្រេន្ទ**

នៅក្នុងការថ្លែងបញ្ចប់របស់ខ្ញុំនេះ ខ្ញុំបាទសូមគោរពអស់លោក លោកស្រី ចំពោះវត្តមាននៅក្នុងទីនេះ និងខ្ញុំសូមសំដែងការរីករាយនិងមោទនភាព ដែលបានវិទ្យាស្ថាន CDRI រៀបចំកម្មវិធីកិច្ចប្រជុំខប់សែលប្រ៉ម នៅក្នុងថ្ងៃនេះ។ ជាតំបូងនេះគឺខ្ញុំគ្រាន់តែសូមបង្ហាញពីការចាប់អារម្មណ៏ទាក់ទងទៅនិងរបាយការណ៏របស់ប្រធាន PEC ដែលបានបង្ហាញយ៉ាងក្បោះក្បាយ និងលំអិតល្អមែនទែន នេះជាចំនុចមួយដែលខ្ញុំសរសើរ និងសូមថ្លែងអំណរគុណណាស់ ។ ហើយចំនុចមួយទៀតដែលខ្ញុំបាទសូមបង្ហាញជូនផងដែរ ក្នុងឋានៈខ្ញុំជាអ្នកអង្គុយទីនេះ ជាអ្នកសង្កេតការណ៏ចំពោះការពិភាក្សាគ្នានេះគឺឃើញថាអស់លោក លោកស្រី ដែលក្នុងនាមជាអ្នកតំណាងមកពីស្ថាប័នផ្សេងៗ ទាំងថ្នាក់ស្រុក ថ្នាក់ឃុំ ទាំងតំណាងគណបក្សនយោបាយ ក៏ដូចជាអង្គការបានលើកឡើងចំនុចទាំងអស់នេះប្រកបទៅដោយការគោរពនិងត្រង់ទៅត្រង់មក ។ ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះលោកខាងតំណាងគណបក្សនយោបាយ ដែលបានលើកឡើងនូវបញ្ហាជាច្រើនដើម្បីពិភាក្សានៅព្រឹកនេះប្រកបទៅដោយការស្មោះត្រង់ទៅវិញទៅមក និងមានលក្ខណៈគោរពគ្នាជាទីបំផុត ។

ដូចដែលខ្ញុំបានលើកពីព្រឹកមិញហើយថា CDRI បានឃើញនៅក្នុងដំណើរការនៅក្នុងបោះឆ្នោតប្រកបទៅដោយភាពត្រឹមត្រូវ និងយុត្តិធមិនិងអភិបាលកិច្ចប្រកបទៅដោយលក្ខណៈប្រជាធិតេយ្យ គឺជាជំហានតំបូងដែលនាំឱ្យមានការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា។ តាមរយៈការពិភាក្សាព្រឹកមិញនេះគឺ អស់លោក លោកស្រី បានលើកឡើងនូវគ្រប់ចំនុចល្អ១ ជាច្រើនដែលជាមូលដ្ឋានមួយសំរាប់ខាងយើងខ្ញុំដើម្បីបង្ហាញជូន ជាពិសេសពាំនាំនូវគំនិតទាំអស់នេះទៅ NEC ក៏ដូចជាទៅកាន់ក្រសួងមហាផ្ទៃផងដែរ។ ឆ្លៀតនៅក្នុងឱកាសនោះខ្ញុំបាទក្នុងនាមវិទ្យាស្ថាន CDRI គឺសូមថ្លែងអំណរគុណចំពោះអស់លោក លោកស្រីដែលបានចូលរួមនៅក្នុងកិច្ចប្រជុំឧប់សែលប្រ៉មនៅក្នុងថ្ងៃនេះ ហើយបានលើកឡើងនូវមតិល្អ១ជាច្រើន និងប្រកបទៅដោយការគោរពគ្នាជាទីបំផុត និងខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោក ឱកសេរីសោភក្តិ៍ ដែលបានសម្របសម្រួលយ៉ាងប៉ិនប្រសប់នៅក្នុងពេលនេះ ព្រមទាំងសូមថ្លែងអំណរគុណចំពោះក្រុមវិទ្យាស្ថាន CDRI ដែលបានរៀបចំនៅក្នុងកិច្ចប្រជុំព្រឹកនេះ។ នៅក្នុងការបិទរបស់ខ្ញុំនេះខ្ញុំគ្រាន់តែបង្ហាញជូននូវការចាប់អារម្មណ៏របស់ខ្ញុំមួយក្នុងនាមខ្ញុំជាជនបរទេស ដែលមកធ្វើការនៅក្នុងប្រទេសកម្ពុជាពីរឆ្នាំកន្លះនេះ ឃើញថាការពិភាក្សាព្រឹកមិញនេះគឺប្រកបទៅដោយលក្ខណៈល្អ ហើយខ្ញុំនេះរៀនសូត្របានច្រើន។ ឆ្លៀតនៅក្នុងឱកាសនេះ ខ្ញុំសូមបួងសួងសូមឱ្យការអនុវត្តន៏នូវវប្បធមិ នៃការពិភាក្សាដ៏ល្អនេះ គឺសូមឱ្យកើតមាននៅក្នុងសហគមន៍របស់យើងជារៀងរហូត ជាពិសេសនៅក្នុងគំនិតមួយដែលថាចង់ឱ្យមានការអភិវឌ្ឍន៏រីកចំរើននៅក្នុងស្រុកទេសរបស់យើងនេះ។